សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យ វិនិយោគសាធារណៈកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **ល.ផន ឆាវ៉ាត់**
**ក. ហំ ស្រីរ័ត្ន**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត ស៊ន សុឃន**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១១ ឆ្នាំសិក្សា (២០១៤-២០១៨) នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវ កត្តញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ៖

ខ្ញុំបាទ **ផន ឆាវ៉ាត់** សូមសម្តែងកត្តាញ្ញូតាធម៌ជូនចំពោះលោកឪពុក **គង់ ផុន** និងអ្នកម្តាយ **អ៊ុំ ម៉ៅ** និងនាងខ្ញុំ **ហាំ ស្រីរ័ត្ន** សូមសម្តែងកត្តាញ្ញូតាធម៌ជូនចំពោះលោកឪពុក **ង៉ែត មៃ** និងអ្នកម្តាយ **អ៊ុំ យេត** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងកូនសព្វគ្រប់បែបយ៉ាង ទាំងសម្ភារៈ ស្មារតី និងថវិកាព្រមទាំងបញ្ជូនឲ្យកូនទៅសិក្សារៀនសូត្រ តាំងពីថ្នាក់មតេយ្យរហូតដល់សាកលវិទ្យាល័យ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ិន សុឃេន** ប្រធាននាយកដ្ឋានត្រួតពិនិត្យ និងគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៃក្រសួងមុខងារសាធារណៈ ដែលជាសាស្ត្រាចារ្យណែនាំដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកក្នុងការងារមកណែនាំដល់ក្រុមយើងខ្ញុំដើម្បីរៀបចំ និងចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

**ក្រសួងអប់រំយុវជន និងកីឡា**ដែលបានផ្តល់អាហារូបករណ៍ឲ្យយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ។

**សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យ**ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ខិតខំបង្កើតធនធានមនុស្សសម្រាប់ជាយាន នាំយកទៅអភិវឌ្ឍប្រទេសកម្ពុជាទាំងពេលបច្ចុប្បន្ន និងអនាគត។

**លោក សំ វង្សី** ជាប្រធាន និង **លោក ឌឹម ម៉ាក់ជារិទ្ធ** អនុប្រធានអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីនៃអង្គភាពនេះទាំងអស់ ដែលបានផ្តល់ជាឯកសារ និងបទសម្ភាស និងផ្តល់ជាគំនិតល្អៗទាក់ទងនិងប្រធានបទស្រាវជ្រាវនេះ ។

**លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** ទាំងអស់ដែលបានបង្រៀនយើងខ្ញុំទាំងពីរ តាំងពីមតេយ្យរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ ដែលបានចំណាយកម្លាំងកាយចិត្ត ក្នុងការអប់រំទូន្មានប្រៀនប្រដៅ ផ្តល់ចំណេះវិជ្ជាដល់យើងខ្ញុំរហូតមកដល់ថ្ងៃនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរសុខសួស្តីជូនដល់លោកឪពុកអ្នកម្តាយ ឯកឧត្តមលោកបណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់ទាំងអស់ សូមឲ្យជួបប្រទះតែជោគជ័យគ្រប់ភារកិច្ច និងសូមប្រកបតែនឹងពុទ្ធិពរទាំង៤ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទឈ្មោះ **ផន ឆាវ៉ាត់** និងនាងខ្ញុំ **ហាំ ស្រីរ័ត្ន** សូមគោរព និងជម្រាបសួរដល់សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍មិត្តសិស្ស និស្សិតអ្នកសិក្សាស្រាវជ្រាវទាំងអស់ជាទីរាប់អាន។

ក្នុងនាមខ្ញុំជានិស្សិតដែលកំពុងធ្វើការសិក្សាផ្នែក រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាឆ្នាំសិក្សាចុងក្រោយនៃថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំទាំងពីរបានមូលមតិគ្នារៀបចំចងក្រង នូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលមានប្រធានបទក្រោមចំណងជើងថា ***"ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា"*** ។ ការសិក្សានូវប្រធានបទនេះដោយ ហេតុថាគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានបណ្តាប្រទេសលើសាកលលោក ជាពិសេសប្រទេសមួយចំនួនក្នុងទ្វីបអាស៊ីបានយកយន្តការភាពជាដៃគូនេះ មកអនុវត្តហើយទទួលបានជោគជ័យគ្រប់ប្រទេស ហើយដោយឃើញពីភាពជោគជ័យនៃគោលនយោបាយភាពជាដៃគូរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកគោលនយោបាយនេះ មកអនុវត្តក្នុងប្រទេសដោយបង្កើតឲ្យមានជាឯកសារគោលនយោបាយជាផ្លូវការនៅឆ្នាំ២០១៦។ ដោយឃើញពីសក្តានុពល និងផលប្រយោជ៍នៃគោលនយោបាយភាពជាដៃគូ ក្រុមយើងខ្ញុំក៏បានបង្កើតប្រធានបទដូចដែលបានពោលខាងលើនេះឡើង ដើម្បីបង្ហាញដល់វិនិយោគិនជាតិ និងអន្តរជាតិថាប្រទេសកម្ពុជាមានគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជននិងរង់ចាំតែអ្នកវិនិយោគមកបណ្តាក់ទុនតែប៉ុណ្ណោះ និងមួយទៀតចង់ចូលរួមជាមួយរាជរដ្ឋាភិបា-លដើម្បីរកដំណោះស្រាយនូវបញ្ហាប្រឈមដែលកើតមានឡើង ក្នុងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ដែលស្ថាប័នទទួលអនុវត្តជួបប្រទះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សានេះ នឹងជួយរួមចំណែកយ៉ាងសំខាន់នៅក្នុងការបង្ហាញដល់វិនិយោគទុនឯកជនពីសក្តានុពល នៃគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជាដើម្បីទាក់ទាញវិនិយោគទុនឯកជនឲ្យមកបណ្តាក់ទុន ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនេះហើយសារណានេះ ក៏ជាឯកសារស្រាវជ្រាវថ្មីមួយ ដែលអាចបំពេញតម្រូវការរបស់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ដែលកំពុងជួបប្រទះនូវកង្វះខាតឯកសារនាពេលបច្ចុប្បន្ន។ យើងខ្ញុំក៏សូមខន្តីអភ័យទោសទុកជាមុនផងដែរ ចំពោះកំហុសឆ្គងទាំងឡាយណាដែល កើតឡើងដោយអចេតនាក្នុងការសរសេរសារណានេះ ហើយយើងខ្ញុំរង់ចាំមតិរិះគន់បែបស្ថាបនាពីសំណាក់មិត្តអ្នកអាន សិស្ស និស្សិត ក៏ដូចជាសាស្ត្រាចារ្យទាំងអស់គ្រប់ពេលវេលា។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន សិស្ស និស្សិត និងសាស្ត្រាចារ្យទាំងអស់ឲ្យជួបប្រទះតែសេចក្តីសុខ សុភមង្គលគ្រប់ពេលវេលារៀងទៅ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| PPP | : ភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| WB | : ធានាគារពិភពលោក |
| ADB | : ធនាគារអភិវឌ្ឍន៍អាស៊ី |
| IMF | : ស្ថាប័នរូបិយវត្ថុអន្តរជាតិ |
| UNESCAP | : គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់របស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ |
| PFI | : គំនិតផ្តួចផ្តើមហិរញ្ញវត្ថុដោយឯកជន |
| RFQ | : Request For Quote ( ស្នើសុំសម្រង់ ) |
| O&M | : Operations and Maintenance ( ប្រតិបត្តិការ និងថែទាំ ) |
| PDF | : មូលនិធិសម្រាប់ការអភិវឌ្ឍន៍គម្រោង |
| VGF | : មូលនិធិបំពេញផលហិរញ្ញវត្ថុ |
| F/S | : ការសិក្សារសមិទ្ធលទ្ធភាព |
| CDC | : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| IPP | : អ្នកផលិតថាមពលឯករាជ្យ |
| EDC | : អគ្គីសនីកម្ពុជា |
| PPA | : កិច្ចព្រមព្រៀងទិញថាមពល |
| BOT | : សាងសង់-អាជីវកម្ម-ផ្ទេរ |
| BOO | : សាងសង់-អាជីវកម្ម-ធ្វើម្ចាស់ |
| BOOT | : សាងសង់-ធ្វើម្ចាស់-អាជីវកម្ម-ផ្ទេរ |
| BTO | : សាងសង់-ផ្ទេរ-អាជីវកម្ម |
| BLT | : សាងសង់-ជួល-ផ្ទេរ |
| CAO | : កិច្ចសន្យា-បន្ថែម-អាជីវកម្ម |
| DOT | : អភិវឌ្ឍន៍-អាជីវកម្ម-ផ្ទេរ |
| ROO | : ស្តារនីតិសម្បទា-ធ្វើម្ចាស់-អាជីវកម្ម |
| ROT | : ស្តារនីតិសម្បទា-អាជីកម្ម-ផ្ទេរ |
| TOT | : ផ្ទេរ-អាជីវកម្ម-ផ្ទេរ |
| DBO | : រចនា-សាងសង់-អាជីវកម្ម |
| DBFOT | : រចនា-សាងសង់-ហិរញ្ញវត្ថុ-អាជីវកម្ម-ផ្ទេរ |

# មាតិកា

ទំព័រ


សេចក្តីផ្តើម ..... ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ៣

៣.គោលបំណងនៃការស្រាវជ្រាវ ..... ៤

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ៤

៥.សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤

៦.វិសាលភាពនៃការស្រាវជ្រាវ ..... ៥

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៦


## ជំពូកទី ១

## សញ្ញាណទូទៅភាពជាដៃគូរវាងរដ្ឋ និងឯកជន


១.១ ប្រវត្តិភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៧

១.២ និយមន័យភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៨

១.៣ ភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់ដៃគូអភិវឌ្ឍន៍ពហុភាគី ..... ៩

១.៣.១ ភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ..... ១០

១.៣.១.១ ភាពខុសគ្នារវាងអភិក្រមគម្រោងសាធារណៈទូទៅ និងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១០

១.៣.១.២ អត្ថប្រយោជន៍នៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១២

១.៣.១.៣ ដែនកំណត់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១៣

១.៣.២ ភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់ធានាគារអភិវឌ្ឍន៍អាស៊ី ..... ១៤

១.៣.២.១ វិស័យដ៏ពេញនិយមដែលកំពុងអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១៥

១.៣.២.២ ទម្រង់នៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ........................................................១៥

១.៣.២.៣ ការផ្តល់ហិរញ្ញប្បទានគម្រោង ........................................................................១៦

១.៤ ច្បាប់ និងបទប្បញ្ញត្តិភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជា ........................................១៧

១.៤.១ ច្បាប់វិនិយោគ........................................................................................១៧

១.៤.២ ច្បាប់សម្បទាន ......................................................................................១៨

១.៤.៣ គោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ: ២០១៦-២០២០ ........................................................១៨

## ជំពូកទី ២

## ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា

២.១ ទិដ្ឋភាពទូទៅភាពជាដៃគូរវាងរដ្ឋ និងឯកជន.............................................................២៣

២.២ ស្ថាប័នទទួលបន្ទុកអនុវត្តន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន.......................... ២៤

២.២.១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ................................................................... ២៤

២.២.១.១ គណៈកម្មការអន្តរក្រសួងដឹកនាំអនុវត្តគោលនយោបាយ .................................. ២៤

២.២.១.២ ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស .........................................២៧

២.២.១.៣ យន្តការគាំទ្រហិរញ្ញវត្ថុ ..............................................................................៣០

២.២.១.៤ តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត .................................................៣១

២.២.២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា .........................................................................៣១

២.២.៣ ស្ថាប័នទទួលបន្ទុកចុះកិច្ចសន្យាសម្បទាន ........................................................៣៤

២.២.៤ ទីប្រឹក្សាប្រតិបត្តិការ .....................................................................................៣៦

២.២.៥ ទីប្រឹក្សាឯករាជ្យ........................................................................................ ៣៧

២.៣ នីតិវិធី និងដំណាក់កាលនៃគម្រោងវិនិយោគភាពជាដៃគូរវាងរដ្ឋ និងឯកជន .......... ៣៧

២.៣.១ ដំណាក់កាលជ្រើសរើសគម្រោង.....................................................................៤០

២.៣.២ ដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង ..................... ៤២

២.៣.៣ ដំណាក់កាលកិច្ចលទ្ធកម្ម និងចុះកិច្ចសន្យា ..................... ៤៣

២.៣.៤ ដំណាក់កាលគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ..................... ៤៨

២.៣.៥ ដំណាក់កាលបញ្ចប់គម្រោង ..................... ៤៩

២.៤ គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលមាននៅកម្ពុជា ..................... ៥០

២.៤.១ គម្រោងភាពជាដៃគូដែលមានពីមុន ..................... ៥០

២.៤.១.១ គម្រោងផ្លូវថ្នល់ ..................... ៥០

២.៤.១.២ គម្រោងថាមពល ..................... ៥១

២.៤.១.៣ សម្បទានក្រុមហ៊ុន ..................... ៥១

២.៤.២ គម្រោងភាពជាដៃគូដែលចាប់កំណើតថ្មីនាពេលបច្ចុប្បន្ន ..................... ៥២

## ជំពូកទី៣

## វិចារណកម្ម នៃគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជា

៣.១ ចំណុចខ្លាំង ..................... ៥៤

៣.២ ចំណុចខ្សោយ ..................... ៥៦

៣.៣ ដំណោះស្រាយ ..................... ៥៧

សេចក្តីសន្និដ្ឋាន ..................... ៦១

អនុសាសន៍ ..................... ៦៣

គន្ថនិទ្ទេស

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ដែលធ្វើឲ្យសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធសង្គមខូចខាតខ្ទេចខ្ទីស្ទើគ្មានសល់។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩២ ប្រទេសកម្ពុជាបានស្គាល់នូវការបង្រួបបង្រួមជាតិមួយ ដែលបានឈានទៅដល់ការបោះឆ្នោតជាតិជាសាកលនៅក្នុងឆ្នាំ១៩៩៣ ដែលរៀបចំដោយទីភ្នាក់ងាររបស់អង្គការសហប្រជាតិ ដែលហៅកាត់ថា UNTAC (អ៊ុនតាក់)។ បន្ទាប់ពីការបោះឆ្នោតប្រទេសកម្ពុជា ទទួលបានរាជរដ្ឋាភិបាលស្របច្បាប់មួយដែលជាផ្លូវនាំកម្ពុជាឲ្យមានសន្តិភាព ស្ថេរភាពនយោបាយ និងមានរដ្ឋធម្មនុញ្ញថ្មីមួយ រដ្ឋធម្មនុញ្ញថ្មីនេះតំរូវឲ្យកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យ សេរីពហុបក្ស និងអនុវត្តយកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី និងមានការគោរពសិទ្ធិមនុស្ស។[1] ក្រោយទទួលបានសន្តិភាពពេញលេញរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ផ្តោតទៅលើការអភិវឌ្ឍន៍ជាតិជាចម្បង ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធសង្គម។ ក្នុងការអភិវឌ្ឍន៍ជាតិ រដ្ឋាភិបាលកម្ពុជាបានគៀងគររកជំនួយពីគ្រប់ទិសទីទាំងកម្ចីបរទេស ដៃគូអភិវឌ្ឍន៍ និងពីវិស័យឯកជនក្នុងបំណងដើម្បីស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងចំណោមដៃគូទាំងអស់មានតែវិស័យឯកជនទេដែលអាចជួយអភិវឌ្ឍកម្ពុជាបានយូរអង្វែង។ ដោយឃើញពីសក្តានុពលពីវិស័យឯកជនរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ គោលនយោបាយ បើកចំហជើងមេឃដែលអនុញ្ញាតឲ្យវិនិយោគិនបរទេសចូលមកវិនិយោគទុនរកស៊ីក្នុងប្រទេស ព្រមទាំងលើកទឹកចិត្តវិនិយោគិនក្នុងស្រុកឲ្យពង្រីកផលទុនបន្ថែម ដោយទទួលបានលក្ខន្តិកៈអំណោយផលជាច្រើន ជាពិសេសរយៈពេលថ្មីៗនេះរដ្ឋាភិបាលបានបង្កើតយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគសាធារណៈ។ រដ្ឋាភិបាលបង្កើតយន្តការភាពជាដៃគូនេះក្នុងចក្ខុវិស័យឲ្យវិស័យឯកជនជួយស្តារ និងអភិវឌ្ឍវិស័យហេដ្ឋាភិបាលកម្ពុជាឲ្យទាន់សម័យ ពីព្រោះបណ្តាប្រទេសលើសកលលោក ជាពិសេសប្រទេសមួយចំនួនក្នុងទ្វីបអាស៊ីបានយកយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនមកអនុវត្តហើយទទួលបានជោគជ័យ និងបានជួយបន្ថយសម្ពាធថវិកាជាតិ ព្រមទាំងជួយកាត់បន្ថយបំណុលសាធារណៈរបស់រដ្ឋបានមួយផ្នែកធំទៀតផង។

យន្តការភាពជាដៃគូ គឺមិនត្រូវបានយកទៅអនុវត្តគ្រប់គម្រោងវិនិយោគសាធារណៈទាំងអស់នោះទេ ភាគច្រើននៃគម្រោងភាពជាដៃគូ យកទៅអនុវត្តក្នុងវិស័យដូចជា ផ្លូវថ្នល់, អាកាសយានដ្ឋាន, ថាមពល, ផ្លូវរថភ្លើង, អប់រំ, ទឹក ឬសុខាភិបាល ជាវិស័យដែលចាំបាច់បំផុត និងមានរយៈពេលយូរ។

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ភាពជាដៃគូរវាងរដ្ឋ និងឯកជន សំដៅដល់កិច្ចព្រមព្រៀងវិនិយោគរវាងរដ្ឋជាមួយដៃគូឯកជនមួយ ឬច្រើនក្នុងការស្ថាបនា, ជួលជុល, ថែទាំ, និង/ឬ គ្រប់គ្រងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬ វិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងៗទៀត ឬ ក្នុងការផ្គត់ផ្គង់សេវាសាធារណៈ ក្នុងរយៈពេលជាកំណត់ដែលភាគីឯកជនត្រូវដាក់ទុនវិនិយោគហើយទទួលរ៉ាប់រងហានិភ័យ និងផលប្រយោជន៍តាមការកំណត់ក្នុងកិច្ចសន្យាសម្បទាន។

ការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានទូទាត់សងវិញតាម ០៣ ទម្រង់ទូទាត់ខាងក្រោម៖

**ការទូទាត់ផ្អែកលើផលចំណូល (Revenue-based Payment)** ៖ ជាទម្រង់ដែលអនុញ្ញាតឲ្យដៃគូឯកជនប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារ-ណៈ ដែលកើតចេញពីគម្រោង។ ទម្រង់នេះអាចអនុវត្តបានចំពោះគម្រោងវិនិយោគសាធារណៈទាំង ឡាយណាដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ។

**ការទូទាត់ផ្អែកលើថវិកាជាតិ (Availability-based Payment)** ៖ ជាទម្រង់ដែលរដ្ឋត្រូវទូទាត់ថ្លៃវិនិយោគ និង/ឬ កម្រៃសេវាពាក់ព័ន្ធជូនដៃគូឯកជនដែលវិនិយោគលើការស្ថាបនា, សាងសង់, ជួសជុល, ធ្វើប្រតិបត្តិការ និង/ឬ ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬ ផ្តល់សេវាសាធារណៈ។ ទម្រង់នេះ អាចអនុវត្តបានចំពោះករណី៖ (១) រដ្ឋជាអ្នកប្រើប្រាស់ ឬ ជាអ្នកទិញសេវាកម្មដោយផ្ទាល់ ឬ(២) គម្រោងវិនិយោគសាធារណៈមានលក្ខណៈសង្គមកិច្ច ដែលពុំមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ។

**ការទូទាត់តាមវិធីចម្រុះ (Hybrid Payment)** ៖ ជាទម្រង់បានមកពីផ្សំគ្នារវាងការទូទាត់ផ្អែកលើផលចំណូល និងការទូទាត់ផ្អែកលើថវិកាជាតិ។ ទម្រង់នៃការទូទាត់ទាំងបីនេះគឺ នឹងយកមកអនុវត្តក្នុងប្រទេសកម្ពុជា ជាដំណាក់កាលបន្តបន្ទាប់ នៃគោលនយោបាយ PPP។[2] គោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជននេះបានល្បីសុះសាយពេញពិភពលោកនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះហើយពេញនិយមបំផុតនៅឆ្នាំ ២០១៤ ដោយដៃគូអភិវឌ្ឍន៍ពហុភាគីសំខាន់ៗ បានចាប់ផ្តើមបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងការជួយអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងការវិនិយោគសាធារ-ណៈដល់ប្រទេសកំពុងអភិវឌ្ឍន៍ ទាំងក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ។ សំរាប់ប្រទេសកម្ពុជារាជរដ្ឋាភិបាល បង្កើតឲ្យមានគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន

[2] ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការPPPសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០

ច្បាស់លាស់នៅឆ្នាំ ២០១៦ ដោយមានការជួយជ្រុំជ្រែងពីធានាគារអភិវឌ្ឍន៍អាស៊ី (ADB) និងគណកម្មការសេដ្ឋកិច្ច និងសង្គមរបស់ អង្គការសហប្រជាជាតិ (UNESCAP) ផ្នែកបច្ចេកទេស និងជំនួយជាថវិកាគាំទ្រឲ្យគោលនយោយ PPP របស់កម្ពុជាកើតមានឡើង។ គោលនយោបាយPPPនឹងរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តជម្រុញ និងលើកទឹកចិត្តការចូលរួមរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុក្នុងការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជា, វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង វិស័យអាទិភាពផ្សេងទៀតប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងស្របតាមឧត្តមានុវត្តជាអន្តជាតិសំដៅពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជាក្នុងតំបន់និងសកលលោក។ ដោយឃើញពីគុណប្រយោជន៍ និងភាពខ្លាំងក្លារបស់គោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដើម្បីរកបញ្ហាប្រឈម និងដំណោះស្រាយ ដើម្បីដាក់ជាអនុសាសន៍ទៅរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយ PPP នេះក្រុមយើងខ្ញុំ ក៏សម្រេចចិត្តបង្កើតប្រធានបទស្រាវជ្រាវ “ **ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា**” ឡើងមក។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ “**ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា**” នេះ យើងនឹងបង្ហាញនូវចម្លើយមួយចំនួន ដែលឆ្លើយតបនឹងសំណួរដូចខាងក្រោមដែលជាគន្លឹះចម្បង និងជាបញ្ហាសំខាន់ៗពាក់ព័ន្ធប្រធានបទ។

១. តើយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនជាអ្វី ?

២. តើភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគសាធារណៈ មាននីតិវិធីយ៉ាងដូចម្តេច បើយោងតាមបទបញ្ញត្តិដែលមានជាធរមានក្នុងប្រទេសកម្ពុជានិងតាមដៃគូអភិវឌ្ឍន៍ពហុភាគី

៣. តើក្នុងការអនុវត្តជាក់ស្តែងរបស់កម្ពុជា ភាពជាដៃគូរវាងរដ្ឋ និងឯកជនមានលក្ខណៈយ៉ាងណា?

៤. តើដៃគូឯកជនប្រភេទណាដែលរដ្ឋជ្រើសរើសឲ្យទទួលអនុវត្តគម្រោងវិនិយោគ PPP ?

៥. តើគម្រោងវិនិយោគភាពជាដៃគូរវាងរដ្ឋ និងឯកជនមានផលវិបាកយ៉ាងណាចំពោះរដ្ឋ និងចំពោះវិនិយោគិនឯកជន។ ហើយផលវិបាកអវិជ្ជមានដែលកើតមានឡើង តើគេមានយន្តការអ្វីខ្លះដើម្បីដោះស្រាយ និងទទួលបានផលយ៉ាងណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ "**ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា** " មានគោលបំណង រកឲ្យឃើញនូវដំណោះស្រាយបញ្ហាសមស្របមួយចំនួន ដែលពាក់ព័ន្ធ និងភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគសាធារណៈកម្ពុជា និងមួយទៀតបង្ហាញដល់វិនិយោគទុនក្នុងស្រុក និងវិនិយោគទុនបរទេសថាប្រទេសកម្ពុជាមានច្បាប់ និងគោលនយោបាយច្បាស់លាស់ទាក់ទងភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេសកម្ពុជាមាននីតិវិធី ព្រមជាមួយយន្តការស្ថាប័នរឹងមាំក្នុងការគាំទ្រ PPP។ គោលបំណងធំនៃប្រធានបទ គឺរកដំណោះស្រាយនៃបញ្ហាដើម្បីជំនួយស្មារតីក្នុងការដាក់អនុសាសន៍ចំពោះការអនុវត្តបទប្បញ្ញត្តិ ស្តីពីភាពជាដៃគូ រវាងរដ្ឋ និងឯកជនក្នុវិស័យវិនិយោគសាធារណៈកម្ពុជា ដល់អ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋានដើម្បីធានាថាគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធចេញមក គឺបម្រើផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋជាធំ ហើយសង្គមទទួលបានផលលាភជាអតិបរមាពីគោលនយោបាយនេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺធ្វើឡើងដោយយោងទៅលើកម្រងឯកសារ គោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា សារាចរជាដើម និងមួយទៀតពីស្ថាប័នរដ្ឋដែលទទួលអនុវត្តគោលនបាយភាពជាដៃរវាងរដ្ឋ និងឯកជន ពីដៃគូអភិវឌ្ឍន៍ពហុភាគី និងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលផ្តួចផ្តើមឲ្យមានគោលនយោបាយ PPP ឡើង។

លើសពីនេះដែនកំណត់ពេលវេលានៃការស្រាវជ្រាវក៏ត្រូវបានកំណត់ផងដែរ គឺកំណត់យកពីឆ្នាំ ២០១៤ ដែលជាឆ្នាំដែលដៃគូអភិវឌ្ឍន៍ពហុភាគីសំខាន់ៗចាប់ផ្តើមបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ ក្នុងការជួយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈដល់ប្រទេសកំពុងអភិវឌ្ឍន៍ជុំវិញសកលលោក រហូតដល់ឆ្នាំ២០១៨ ដែលជាឆ្នាំគោលនយោបាយ PPP របស់កម្ពុជាកំពុងអនុវត្តក្តៅគគុក នឹងត្រៀមអនុវត្តពេញលេញនាឆ្នាំ២០២០។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ "**ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា**" មានអត្ថប្រយោជន៍ដូចតទៅៈ

- ចូលរួមរកបញ្ហា និងដំណោះស្រាយក្នុងការអនុវត្តគោលនយោបាយ ភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ របស់កម្ពុជា
- ពង្រីកចំនេះដឹង និងបំណិនក្នុងការស្រាវជ្រាវ
- ចងក្រងជាស្នាដៃ ដើម្បីទុកប្រើប្រាស់ជាឯកសារជំនួយស្មារតី សម្រាប់អ្នកសិក្សាស្រាវជ្រាវគ្រប់មជ្ឈដ្ឋានសិក្សាបន្ត...។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "**ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា**" ផ្អែកលើប្រភពឯកសារមួយចំនួនដូចជាសៀវភៅក្នុងបណ្ណាល័យនានា ព្រមទាំងធ្វើការប្រមូលទិន្នន័យដែលបានមកពីប្រភពដែលពាក់ព័ន្ធ ស្ថាប័នរដ្ឋ, ដៃគូអភិវឌ្ឍន៍ពហុភាគី និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ហើយយកមកធ្វើការវិភាគវែកញែក យ៉ាងច្បាស់លាស់ទៅលើប្រភពទិន្នន័យទាំងនោះ។ ទិន្នន័យដែលប្រមូលមកចងក្រងជាសារណានេះត្រូវបែងចែកជាពីរប្រភពគឺៈ

**ទិន្នន័យចម្បង**

ចំពោះទិន្នន័យចម្បងនេះ បានមកតាមរយៈការចុះទៅស្រាវជ្រាវនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយផ្ទាល់។ ហើយបានធ្វើការប្រមូលនូវទិន្នន័យឯកសារទាក់ទងភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងសាកសួរ បញ្ហានានាជុំវិញប្រធានបទស្រាវជ្រាវ ទៅកាន់ថ្នាក់ដឹកនាំ និងមន្រ្តីដែលទទួលភារកិច្ចអនុវត្តគោលនយោបាយ អភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ដោយផ្ទាល់ ជាពិសេសអង្គភាពភាពជាដៃគូ រវាងរដ្ឋ និងឯកជនថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ទិន្នន័យបន្ទាប់បន្សំ**

ចំពោះទិន្នន័យបន្ទាប់បន្សំវិញ គឺបានប្រមូលមកពីប្រភពឯកសារនានា ដែលបានសិក្សាក្នុងបណ្ណាល័យច្បាប់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងតាមបណ្ណាល័យសាធារណៈនានា រួមផ្សំពីគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាក់ទងភាពជាដៃគូរវាងរដ្ឋ និងឯកជន (www.ppp.mef.gov.kh), ធានាគារពិភពលោក, ធានាគារអភិវឌ្ឍន៍អាស៊ី និងគណៈកម្មការសេដ្ឋ-កិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (www.unescap.org) ព្រមជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងប្រធានបទស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានបែងចែកជាបីជំពូកធំៗគឺៈ **ជំពូកទី១** សញ្ញាណទូទៅភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងជំពូកនេះយើងបានលើយកនូវបទប្បញ្ញត្តិគោល និងទ្រឹស្តីនានាដែលនិយាយអំពីភាពជាដៃគូរវាងរដ្ឋ និងឯកជនទាំងលក្ខណៈជាតិ និងទាំងលក្ខណៈអន្តរជាតិមកបង្ហាញ។ **រីឯជំពូកទី២** គឺភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា ក្នុងជំពូកនេះយើងនិងបង្ហាញពី ការអនុវត្តជាក់ស្តែងនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជា ព្រមជាមួយយន្តការស្ថាប័ន និងនីតិវិធីគម្រោងហេដ្ឋារចនាសម្ព័ន្ធតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជា។ **ចំណែកជំពូកទី៣** និយាយពីវិចារណកម្ម នៃគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគសាធារណៈកម្ពុជា។ និងជាចុងក្រោយយើងនឹងធ្វើការសន្និដ្ឋាន ព្រមជាមួយការដាក់ជាអនុសាសន៍ ឲ្យអ្នកពាក់ព័ន្ធដែលអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជាយកទៅកែលម្អដើម្បីឲ្យគោលនយោបាយ PPP របស់កម្ពុជាកាន់តែប្រសើរឡើង។

# ជំពូកទី១

# សញ្ញាណទូទៅនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន

## ១.១ ប្រវត្តិភាពជាដៃគូរវាងរដ្ឋ និងឯកជន

ចាប់តាំងពីដើមសម័យទំនើប PPP គឺជាទម្រង់មួយនៃការអនុវត្តការងារសាធារណៈដែលត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងបណ្តាប្រទេសនៅអឺរ៉ុបខាងលិច។ កិច្ចសហប្រតិបត្តិការអន្តរប្រសិទ្ធភាពត្រូវបានអភិវឌ្ឍ នៅក្នុងពិភពលោកចាស់នៅដើមដំបូងសម័យទំនើបហើយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ PPP បានក្លាយជាប្រជាប្រិយភាពនៅប៉ូឡូញ។ ក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចសហប្រតិបត្តិការបែបនេះនៅក្នុងទ្វីបអឺរ៉ុប និងប៉ូឡូញបានបន្តវិវត្តក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។ គោលបំណងនៃអង្គភាពទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ស្ថាប័ន និងការអនុវត្តជាក់ស្តែងនៃ PPP គឺធ្វើឲ្យPPPស្មើនឹងវិធីសាស្ត្របែបប្រពៃណីនៃការផ្តល់ហិរញ្ញប្បទាននិងការអនុវត្តភារកិច្ចសាធារណៈ។

ប្រភព PPP អាចរកបាននៅក្នុងកិច្ចសន្យាសម្បទានទាំងអស់ក្នុងពិភពលោក ពីព្រោះសម្បទានជាផ្នែកមួយនៃ PPP។ ក្រុមអ្នកស្រាវជ្រាវប្រវត្តិសាស្ត្របានបង្ហាញថានៅដើមឆ្នាំ១៤៣៨ ឧត្តមសេនីយ៍បារាំងលោកល្វីសដឺប៊ែរណាមបានផ្តល់ដីសម្បទាន ដើម្បីយកកម្រៃសម្រាប់ទំនិញដឹកជញ្ជូនតាមដងទន្លេ។ សម្បទានប្រភេទនេះដែរ ត្រូវបានផ្តល់ឲ្យម្តងទៀតនៅឆ្នាំ១៧៩២ នៅបារាំងទៅបងប្រុសភីរីរ៍សម្រាប់ការចែកចាយទឹកនៅប៉ារីស។ មិនយូរប៉ុន្មានការអនុវត្តផ្នែកច្បាប់របស់បារាំងបានបង្កើតឡើងនូវច្បាប់មួយគឺសម្បទានដីសាធារណៈ។ ការចូលរួមយ៉ាងទូលំទូលាយនៃដើមទុនឯកជននៅក្នុងការ វិនិយោគសាធារណៈបានរកឃើញការប្រើប្រាស់ជាទូទៅក្នុងកំឡុងពេលចាប់ពីសតវត្សទីដប់ប្រាំពីរ ដល់ចុងសតវត្សទីដប់ប្រាំបួន នៅពេលដែលការកសាងហេដ្ឋារចនាសម្ព័ន្ធ បណ្តាញទឹក, ផ្លូវថ្នល់ និងផ្លូវដែកនៅទ្វីបអឺរ៉ុប និងក្រោយមកនៅអាមេរិក ចិន និងជប៉ុនត្រូវបានផ្តល់មូលនិធិដោយប្រភពឯកជនក្រោមកិច្ចសន្យាសម្បទាន។ បន្ទាប់ពីរយៈពេលនៃការរីករាលដាលរបស់រដ្ឋាភិបាលនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងអំឡុងពេលចាប់ពីចុងសតវត្សទី១៩ ដល់ចុងទសវត្សរ៍ទី២០ នៃសតវត្សទី២០ ការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធទៅជាទីផ្សារតម្រង់ទិសទីផ្សារ បានក្លាយជាប្រជាប្រិយភាពយ៉ាងខ្លាំងនៅទសវត្សរ៍ ១៩៨០ និង១៩៩០។ នៅឆ្នាំ១៩៩២ចក្រភពអង់គ្លេសបានចាប់ផ្តើមអនុវត្តគម្រោងហិរញ្ញវត្ថុ PFI ជាកម្មវិធីដ៏ទូលំទូលាយមួយរបស់រដ្ឋាភិបាលដែលគ្របដណ្តប់សហគ្រាសរដ្ឋ។ នៅក្រោម PFI វិស័យសាធារណៈបានក្លាយជាអ្នកទិញសេវាកម្មដែលផ្តល់ជូនដោយសហគ្រិន ខណៈពេលដែលក្រុមហ៊ុនបានផ្តល់ទ្រព្យសម្បត្តិថេរចាំបាច់សម្រាប់ការអនុវត្តរបស់ពួកគេ។ គំរូមួយក្នុងចំណោមគំរូឈានមុខគេនៃការគ្រប់គ្រង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្រោម PFI បានក្លាយទៅជាកិច្ចសន្យាដែលពាក់ព័ន្ធនឹងការផ្ទេរទៅឲ្យភាគីឯកជននូវកាតព្វកិច្ចអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬការផ្តល់សេវាសាធារណៈរួមគ្នា

ជាមួយការផ្ទេររាល់ ហានិភ័យជាក់លាក់ទៅលើសហគ្រិន។ ជាការឆ្លើយតបវិនិយោគិននឹងទទួលបានសិទ្ធិប្រើប្រាស់ បណ្ដោះអាសន្ន (ជាធម្មតាពី១៥ ទៅ ៣០ឆ្នាំ) ដើម្បីប្រើប្រាស់សេវាកម្មដោយមានលទ្ធភាពគិតថ្លៃចំពោះអ្នកប្រើខាងក្រៅ ឬការបង់ប្រាក់ជាបន្តបន្ទាប់ពីថវិការបស់អង្គភាពសាធារណៈ។ គម្រោងធំៗ ដែលត្រូវបានអនុវត្តក្រោមគម្រោងនេះគឺផ្លូវក្រោមដី, ផ្លូវរថភ្លើង និងរូងក្រោមដី។ នៅក្រោមគម្រោង PFI ភារកិច្ចក្នុងតំបន់ដូចជាផ្លូវថ្នល់, ផ្លូវក្រោមដី, ពន្ធនាគារ, ការការពារជាតិ, ការថែទាំសុខភាពលំនៅដ្ឋានសម្រាប់រដ្ឋបាល និងកុំព្យូទ័រត្រូវបានអនុវត្តយ៉ាងជោគជ័យ។ នៅប្រទេសបារាំងគំរូដ៏ពេញនិយមមួយ សម្រាប់ការបង្កើតកិច្ចសហប្រតិបត្តិការរវាងអង្គភាពសាធារណៈ និងដៃគូឯកជនបានក្លាយទៅជាស្ថាប័នសាធារណៈនៃគណៈប្រតិភូនៅឆ្នាំ១៩៩០។ សម្បទាន និង PPP បានរួមបញ្ចូលជាបន្តបន្ទាប់ទៅក្នុងប្រព័ន្ធច្បាប់នៃបណ្ដាប្រទេសសហភាពអឺរ៉ុបផ្សេងៗទៀត។ ភាគច្រើនបំផុតនៃការអនុវត្តស្រដៀងគ្នាគឺគំរូអង់គ្លេស និងបារាំង។ កិច្ចសន្យាប្រភេទនេះសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសដូចជាប្រទេសអ៊ីតាលី, អេស្ប៉ាញ, ព័រទុយហ្គាល់, ហូឡង់និងបណ្ដាប្រទេសស្កឹនដាណាវ, អៀរឡង់, ក្រិក, សាធារណរដ្ឋឆែក,ប៊ុលហ្គារី, រ៉ូម៉ានី និងហុងគ្រីដែលបានឈានដល់រាប់រយលានអឺរ៉ូ ប៉ុន្តែជាញឹកញាប់ក៏មានទាក់ទងនឹងគម្រោងក្នុងស្រុកតូចៗផងដែរ។

កិច្ចសហប្រតិបត្តិការសាធារណៈ និងឯកជននៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធក៏មាននៅក្នុងទឹកដីនៃប្រទេសប៉ូឡូញផងដែរ ដែលមានតាំងពីសម័យភាគប៉ូឡូញ។ ផ្លូវរថភ្លើងដែលសំខាន់បំផុតត្រូវបានសាងសង់ក្រោមសម្បទាន។ បន្ទាប់ពីទទួលបានឯករាជ្យវិញ អាជ្ញាធរប៉ូឡូញបានព្យាយាមទាញយករដ្ឋាភិបាលមូលដ្ឋាន និងមូលធនឯកជនដើម្បីអភិវឌ្ឍបន្ទាត់មូលដ្ឋាន។ ដោយការអនុវត្តមានមូលដ្ឋាននៅលើច្បាប់ថ្ងៃទី១៤ ខែ តុលា ឆ្នាំ១៩២១ ស្ដីពីការផ្ដល់សម្បទានដល់ផ្លូវដែកឯកជនកំណត់ទំនាក់ទំនងរបស់រតនាគាររដ្ឋជាមួយម្ចាស់នាពេលអនាគត។ឱកាសមួយទៀតនៃការស្ដាបនានៃគម្រោងសាធារណៈ បានលេចឡើងនៅក្នុងប្រទេសប៉ូឡូញបន្ទាប់ពីឆ្នាំ១៩៨៩។

## ១.២ និយមន័យភាពជាដៃគូរវាងរដ្ឋ និងឯកជន

ភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានផ្ដល់និយមន័យដោយស្ថាប័នអន្តរជាតិជាច្រើនលើសកលលោក។ ចំណែកឯក្របខ័ណ្ឌច្បាប់ប្រទេសកម្ពុជាក៏បានផ្ដល់និយមន័យភាពជាដៃគូនេះដែរ ដែលនិយមន័យទាំងអស់នេះមានខ្លឹមសារដូចតទៅ៖

រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៥ នៃរដ្ឋសភាបានបង្កើតគោលនយោបាយភាពជាដៃគូ រវាងរដ្ឋ និងឯកជនច្បាស់លាស់ក្នុងឆ្នាំ ២០១៦ ដែលបានឲ្យនិយមន័យភាពជាដៃគូរវាងរដ្ឋ និង ឯកជនថាសំដៅដល់កិច្ចព្រមព្រៀងវិនិយោគរវាងរដ្ឋជាមួយដៃគូឯកជនមួយ ឬច្រើនក្នុងការស្ដារ, ជួលជុល, ថែទាំ និង/ឬ គ្រប់គ្រងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងៗ

ទៀត ឬក្នុងការផ្គត់ផ្គង់សេវាសាធារណៈក្នុងរយៈពេលជាកំណត់ដែលភាគី ឯកជនត្រូវដាក់ទុនវិនិយោគ ហើយទទួលរ៉ាប់រងហានិភ័យ និងផលប្រយោជន៍តាមការកំណត់ក្នុងកិច្ចសន្យាសម្បទាន។[3]

ធានាគារអភិវឌ្ឍន៍អាស៊ី ក៏បានផ្តល់និយមន័យភាពជាដៃគូផងដែរថា ជាការរៀបចំកិច្ចសន្យារវាង បុគ្គលសាធារណៈ (រដ្ឋ, ថ្នាក់ជាតិ, ថ្នាក់ខេត្ត ឬមូលដ្ឋាន) និងអង្គភាពឯកជនដែលតាមរយៈជំនាញ ហិរញ្ញវត្ថុ។ ទ្រព្យសម្បត្តិ និងធនធានហិរញ្ញវត្ថុរបស់វិស័យសាធារណៈ និងឯកជននីមួយៗត្រូវបាន បម្រុងទុកដោយការបំពេញបន្ថែមនូវហានិភ័យ និងអត្ថប្រយោជន៍ ដើម្បីស្វែងរកការផ្តល់សេវាល្អ ប្រសើរ និងតម្លៃល្អដល់ប្រជាពលរដ្ឋ។ នៅក្នុង PPP វិស័យសាធារណៈនៅតែទទួលខុសត្រូវខ្ពស់បំផុត សម្រាប់ការផ្តល់សេវា បើទោះជាវិស័យឯកជនផ្តល់សេវាកម្មសម្រាប់រយៈពេលយូរក៏ដោយ។ ក្នុង ប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីកិច្ចសន្យាទាំងអស់ដូចជាកិច្ចសន្យាការងារ ( កិច្ចសន្យា និង ការគ្រប់គ្រងកិច្ចសន្យា ) ការជួល - ប្រតិបត្តិការ - ផ្ទេរ, សាងសង់- ធ្វើម្ចាស់ - ប្រតិបត្តិការ - ផ្ទេរ, រចនា- សាងសង់ - ហិរញ្ញវត្ថុ -ប្រតិបត្តិការ និងសម្បទានត្រូវបានចាត់ទុកថាជាទម្រង់ផ្សេងៗគ្នា នៃ PPP។[4]

គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (UNESCAP) បានផ្តល់និយមន័យដែលថា ភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺជាកិច្ចសន្យារយៈពេលវែង ហើយជាទូទៅមានរយៈពេលច្រើនជាង២០ ឆ្នាំរវាងស្ថាប័នរដ្ឋ និងឯកជន ដើម្បីផ្តល់សេវាសាធារណៈ និង/ឬ ជាការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលក្នុងនោះការទទួលខុសត្រូវ និងប្រាក់កម្រៃ ត្រូវបានចែករំលែកគ្នា។ PPP អនុវត្តក្នុងវិស័យជាច្រើនដូចជា ផ្លូវថ្នាល់, ថាមពល, ផ្លូវរថភ្លើង, អប់រំ, ទឹក ឬសុខាភិបាលជាដើម។[5]

ចំណែកធានាគារពិភពលោកបានផ្តល់និយមន័យភាពជាដៃគូ គឺជាកិច្ចសន្យារយៈពេលវែងមួយ រវាងភាគីឯកជន និងអង្គភាពរដ្ឋាភិបាលសម្រាប់ការផ្តល់ទ្រព្យសម្បត្តិ ឬ សេវាកម្មសាធារណៈដែលក្នុង នោះខាង វិស័យឯកជនមានហានិភ័យខ្ពស់ និងការទទួលខុសត្រូវគ្រប់គ្រងនិងការទូទាត់ត្រូវបានផ្សារ ភ្ជាប់ទៅនឹងការអនុវត្ត។ កិច្ចសន្យា ឬគម្រោង PPP ភាគច្រើនបង្ហាញពីកិច្ចសន្យារយៈពេលចន្លោះពី ២០ ទៅ ៣០ ឆ្នាំ។[6]

## ១.៣ យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់ដៃគូអភិវឌ្ឍន៍ពហុភាគី

[3] ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ។

[4] PUBLIC–PRIVATE PARTNERSHIP MONITOR(www.adb.org)

[5] www.unescap.org(PPP Training)

[6] www.wb.org(The PPP Knowledge Lab)

ភាពជាដៃគូរវាងរដ្ឋនិងឯកជនបានផ្ដួចផ្ដើមឡើងជាច្រើនស្ថាប័នទាំងដៃគូអភិវឌ្ឍន៍ពហុភាគី និងទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ តែនូវពេលនេះយើងយកតែពីរស្ថាប័នមកបង្ហាញប៉ុណ្ណោះគឺៈ

**១.៣.១ គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក**

ទាក់ទងនឹង PPP គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) បានបង្កើតជាវីដេអូសិក្សាអំពីភាពជាដៃគូរវាងរដ្ឋ និងឯកជនតាមប្រព័ន្ធអ៊ិនធឺណេតដែលនិយាយជាភាសាអង់គ្លេស។ វីដេអូសិក្សាអំពី PPP នេះបានបែងចែកការសិក្សា PPP ជាប្រាំមួយម៉ូឌុល ដើម្បីឲ្យវិស័យឯកជន និងវិស័យសាធារណៈស្វែងយល់អំពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងវិស័យវិនិយោគសាធារណៈ យល់ដឹងអំពីអត្ថប្រយោជន៍ ហានិភ័យ និងភាពខុសគ្នារវាងលទ្ធកម្មតាម PPP និងលទ្ធកម្មសាធារណៈទូទៅ និងជាពិសេសបង្ហាញថាគម្រោងវិនិយោគសាធារណៈប្រភេទណា ដែលអាចវិនិយោគតាមគម្រោង PPP ហើយក្នុងការពន្យល់អំពីPPP ស្ថាប័ននេះក៏បានបង្កើតជាកូនសៀវភៅដែលបានបកប្រែជាភាសាខ្មែរផងដែរ។

នៅក្នុងចំណុចនេះយើងមិនបានលើកយកម៉ូឌុលទាំងប្រាំមួយមកសិក្សាលម្អិតទេ ប៉ុន្តែយើងនឹងធ្វើការបង្ហាញដោយសង្ខេបអំពី PPP ដោយយកតែចំណុចសំខាន់បំផុតនៃគោលនយោបាយPPP ដែលអាចឲ្យមិត្តអ្នកអានចាប់អារម្មណ៍ និងងាយយល់អំពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) របស់ស្ថាប័ន UNESCAP ដែលចំណុចទាំងនោះមានដូចតទៅៈ

**១.៣.១.១ ភាពខុសគ្នារវាងអភិក្រមគម្រោងសាធារណៈទូទៅ និងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន**

អភិក្រមគម្រោងសាធារណៈទូទៅ និងគម្រោង PPP ខុសគ្នាចំណុច ៤ សំខាន់ៗ គឺ ៖

**ទី១ គឺប្រភពធនធានហិរញ្ញប្បទាន** គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈទូទៅ គឺហិរញ្ញប្បទានដោយថវិកាជាតិរបស់ប្រទេស។ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ បែបនេះ រដ្ឋាភិបាលនឹងធ្វើការជ្រើសរើសអ្នកទទួលកិច្ចសន្យានិងបង់ថវិកាឲ្យអ្នកទទួលកិច្ចសន្យតាមវឌ្ឍនភាពនៃការងារ សម្រាប់គម្រោងសាងសង់។ នេះមានន័យថាការទូទាត់ថវិកា គឺត្រូវធ្វើឡើងទុកជាមុនដំណាក់កាលសាង សង់។ នៅក្នុងគម្រោង PPP វិនិយោគិនឯកជន គឺជាអ្នកផ្ដល់ហិរញ្ញប្បទានដល់គម្រោង ប៉ុន្តែអ្នកវិនិយោគទុនមិនមែនធ្វើកិច្ចការនេះដោយមិនគិតថ្លៃ ឬផលប្រយោជន៍អ្វីនោះទេ ភាគីឯកជនសង្ឃឹមថានឹងបង្កើតប្រាក់ចំណេញពីការវិនិយោគទុនរបស់ពួកគេដោយមានន័យថា អ្នកវិនិយោគត្រូវតែបានទទួលប្រាក់ចំណេញពីការបណ្ដាក់ទុនរបស់ពួកគាត់។ ជាទូទៅគឺមានមធ្យោបាយ ០២ ដែលអ្នកវិនិយោគទុនក្នុងគម្រោង PPP អាចរកប្រាក់ចំណេញពីការបណ្ដាក់ទុននេះបាន។ **ទី១** ដៃគូឯកជននឹងបានទទួលបានសិទ្ធិ ក្នុងការ

ប្រមូលកម្រៃសេវាពីការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដូចជាការបង់ប្រាក់សំរាប់ការប្រើផ្លូវ និង**ទី២** រដ្ឋាភិបាលអាចបង់ថវិកាទៅឲ្យដៃគូឯកជនតាមវិធីដែលហៅថា **"ការទូទាត់ផ្អែកលើថវិកាជាតិ"** នៅក្នុងករណីការបង់ថវិកាបែបនេះប្រតិបត្តិការីឯកជន នឹងបានទទួលថវិកាដោយផ្អែកលើលទ្ធផលការងារ ទៅតាមពេលវេលាកំណត់ទុក។ ឧទាហរណ៍៖ គម្រោងស្ថាបនាផ្លូវរដ្ឋាភិបាលអាចពិនិត្យតាមដាន នៅក្នុងរយៈពេលទៀងទាត់ ប្រសិនបើផ្លូវនោះត្រូវបានសាង់សង់រួចវាមានន័យថាផ្លូវថ្នល់នោះ គឺអាចបើកឲ្យប្រើប្រាស់បាន ហើយបើសិនផ្លូវនោះមានគុណភាពតាមស្តង់ដារ ដូចបានកំណត់ក្នុងកិច្ចសន្យា វាមានន័យថាគុណភាពផ្លូវថ្នល់អាចទទួលយកបាន។ បើសិនលក្ខខណ្ឌនៃការសាងសង់ត្រូវបានបំពេញរដ្ឋាភិបាលអាចបង់កម្រៃសេវាថេរទៅឲ្យប្រតិបត្តិការីឯកជន។ បើសិនដល់ពេលណាមួយផ្លូវនោះពុំមានគុណភាពត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យានៅពេលនោះ ការបង់ថវិការបស់រដ្ឋាភិបាលនឹងត្រូវកាត់បន្ថយ ការអនុវត្តបែបនេះជាការ លើកទឹកចិត្តដល់ដៃគូឯកជនដើម្បីរក្សាផ្លូវនោះឲ្យ អាចប្រើប្រាស់បានក្នុងយៈពេលដែលបានកំណត់ទុក។ សរុបមកសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទូទៅការបង់ថវិកាគឺត្រូវបង់ជាមុន ប៉ុន្តែគម្រោង PPP ពុំមានការបង់ថវិការដ្ឋជាមុនទេនៅក្នុងដំណាក់កាលនៃការសាងសង់ ការបង់ថវិកាឲ្យដៃគូឯកជនគឺបង់តាមការកំណត់ រហូតទៅតាមរយៈពេលវេលានៃគម្រោងបន្ទាប់ពីគម្រោងនោះត្រូវបើកដាក់ឲ្យដំណើរការ។

**ភាពខុសប្លែកទី២** រវាងគម្រោង PPP និងគម្រោងសាធារណៈទូទៅគឺទាក់ទងទៅនឹងរយៈ ពេល។ នៅក្នុងគម្រោងលទ្ធកម្មជាប្រពៃណី ឬគម្រោងសាធារណៈទូទៅ ទំនាក់ទំនង រវាងរដ្ឋ និងដៃគូឯកជនត្រូវបញ្ចប់សព្វគ្រប់នៅពេលការកសាងបានសម្រេច។ ប៉ុន្តែសម្រាប់គម្រោង PPP ទំនាក់ទំនងនៅតែបន្តទៅមុខហួសរយៈពេលឆ្ងាយក្រោយពីការបញ្ចប់ការសាងសង់ ដោយដៃគូឯកជននៅតែទទួលខុសត្រូវមិនត្រឹមតែការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការងារប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទៅមុខជាច្រើនឆ្នាំតាមកំណត់ទុកជាទូទៅគឺច្រើនជាង២០ ឆ្នាំ។ ទន្ទឹមនឹងនេះអាជ្ញាធរសាធារណៈត្រូវតែពិនិត្យតាមដានទៅលើការអនុវត្តការងាររបស់ ប្រតិបត្តិការីឯកជនពេញមួយរយៈពេល នៃកិច្ចសន្យា។ នៅទីបញ្ចប់នៃកិច្ចសន្យាគម្រោង PPP កម្មសិទ្ធិលើទ្រព្យសម្បត្តិគឺត្រូវប្រគល់ឲ្យអាជ្ញាធរសាធារណៈ នេះគឺជាភាពខុសគ្នារវាងគម្រោង PPP និងការធ្វើឯកជនូបនីយកម្មទ្រព្យសមត្តិសាធារណៈទាំងស្រុង ។

**ចំណុចទី៣** នៃភាពខុសគ្នារវាងគម្រោង PPP ពីគម្រោងទូទៅ គឺតម្រូវឲ្យមានការកំណត់បញ្ជាក់សមិទ្ធិផលការងារ អ្វីដែលយើងចង់បាន នៅពេលលទ្ធកម្មបែបប្រពៃណី ផ្តោតលើធាតុចូល ថាតើយើងអាចសម្រេចអ្វីដែលយើងចង់បានដូចម្តេច។ ក្នុងករណីគម្រោងសាងសង់ផ្លូវ មានន័យថាយថាប្រភេទនៃគម្រោងក្នុងទ្រង់ទ្រាយ PPP អាចសំដៅទៅដល់សូចនាករនៃ "គុណភាពនៃផ្លូវថ្នល់" ច្រើនជាងការ

បញ្ជាក់អំពីរាយលំអិតនៃការសាងសង់ផ្លូវថ្នល់នោះ។ ចំពោះគម្រោងព្រលានយន្តហោះសមិទ្ធិផលវាអាចមានសមត្ថភាពទទួលអ្នកធ្វើដំណើរ១០ លាននាក់ក្នុងមួយឆ្នាំដែលធាតុចូលអាចជា "អាគារចំណតយន្តហោះ២ ខ្នង" អាគារនីមួយៗ មានផ្ទៃ២៥០,០០០ ម៉ែត្រក្រឡា ។ល។ ការប្រើប្រាស់សមិទ្ធិផលយថាប្រភេទផ្តល់ឲ្យវិស័យឯកជននូវឱកាសក្នុងការបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ សម្រាប់ការផ្តល់សេវាសាធារណៈដែលនឹងអាចបង្កឲ្យសន្សំសំចៃថវិកាបានច្រើន។ ការផ្តោតលើសមិទ្ធិផលយថាប្រភេទទាមទារឲ្យមានមូលដ្ឋានការគិតគូរខុសប្លែកពីធម្មតា និងអាចមានការទាមទារឲ្យមានការកែសម្រួលពីដៃគូរដ្ឋ ដែលធ្លាប់តែស៊ាំនឹងការអនុវត្តគម្រោងទូទៅ ដែលប្រើប្រាស់អភិក្រមធាតុចូល។

**លក្ខណៈសំខាន់ចុងក្រោយទី៤** ដែលធ្វើឲ្យគម្រោង PPP ខុសពីគម្រោងទូទៅគឺទាក់ទងនិងការចែករំលែកហានិភ័យ។ សម្រាប់គម្រោងលទ្ធកម្មសាធារណៈ ជាទូទៅហានិភ័យគឺទទួលខុសត្រូវទាំងស្រុងដោយរដ្ឋ ប៉ុន្តែក្នុងគម្រោង PPP ហានិភ័យគឺត្រូវចែករំលែករវាងរដ្ឋ និងឯកជន។ ឧទាហរណ៍ៈ ក្នុងគម្រោង PPP វិស័យឯកជនជាធម្មតាទទួលខុសត្រូវលើការសាងសង់និងហានិភ័យពីការប្រតិបត្តិការគម្រោង។ ប៉ុន្តែហានិភ័យទាំងនោះគឺជាអ្វី? ជាមួយនឹងគម្រោងណាក៏ដោយគឺតែងតែមានហានិភ័យដែលចំណាយសម្រាប់ការសាងសង់ និងប្រតិបត្តិការ អាចនឹងលើសពីថវិកាដែលបានកំណត់ទុក។ នៅក្នុងម៉ូឌែលលទ្ធកម្មសាធារណៈទូទៅ ហានិភ័យហិរញ្ញវត្ថុគឺទទួលខុសត្រូវទាំងស្រុងដោយស្ថាប័នរដ្ឋ។ ប៉ុន្តែម៉ូឌែលនៃគម្រោង PPP ហានិភ័យគឺត្រូវប្រគល់ទៅឲ្យដៃគូឯកជន ដែលជាអ្នកទទួលខុសត្រូវទាំងការសាងសង់ និងការអនុវត្តគម្រោង។ មានន័យថាក្នុងគម្រោង PPP វិស័យសាធារណៈមិនចាំបាច់ប្រឈមនឹងហានិភ័យពីចំណាយហួសប្រមាណនោះទេ។ ក្នុងគម្រោង PPP ហានិភ័យតែងតែបានពិនិត្យមើលតាំងពីដំបូងហើយគម្រោងត្រូវបានរៀបចំ ដើម្បីចែករំលែកហានិភ័យទៅដល់ដៃគូ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងហានិភ័យ។

ទាំង៤ ចំណុចដែលបានរៀបរាប់ខាងលើ គឺគ្រប់ដណ្តប់ភាពខុសប្លែកគ្នារវាងគម្រោង PPP និងម៉ូឌែលលទ្ធកម្មសាធារណៈទូទៅ ឬអភិក្រមគម្រោងសាធារណៈទូទៅ។

### ១.៣.១.២ អត្ថប្រយោជន៍នៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

អត្ថប្រយោជន៍គន្លឹះមួយចំនួននៃគម្រោងតាមបែបភាពជាដៃគូរវាងរដ្ឋ និងឯកជនៈ

**អត្ថប្រយោជន៍ទី១** និងជាហេតុផលដ៏សំខាន់ដែលរដ្ឋាភិបាល បានចាប់ផ្តើមធ្វើការពិចារណាការអនុវត្តតាមបែប PPP គឺដើម្បីទាក់ទាញមូលធនឯកជន។ PPP ត្រូវមើលឃើញថាជាមធ្យោបាយមួយសម្រាប់ហិរញ្ញប្បទានគម្រោង ដែលគម្រោងផ្សេងមិនអាចធ្វើទៅបាន ដោយសារសម្ពាធថវិកាជាតិ។ ទោះជាយ៉ាងនេះក៏ដោយគម្រោង PPP ក៏មិនមែនផ្តល់ឲ្យដោយមិនគិតថ្លៃនោះទេវិស័យឯកជនត្រូវតែទទួលប្រាក់កម្រៃពីការបណ្តាក់ទុនរបស់ខ្លួន។

ក្រៅពីចំណូលពីថ្លៃប្រើប្រាស់សេវា វិស័យឯកជនក៏អាចរកប្រាក់ចំណូលបន្ថែមបានដែរ ជាអាទិ៍ គំរូគម្រោងព្រលានយន្តហោះ ការយល់ដឹងពីសាធារណៈជនព្រ លានយន្តហោះត្រូវយល់ថាជាមធ្យោបាយមួយដើម្បីផ្តល់សេវាដឹកជញ្ជូន ជូនដល់អ្នកធ្វើដំណើរ និងក្រុមហ៊ុនអាកាសចរណ៍។ វិស័យឯកជនអាចមានសមត្ថភាពកំណត់ និងអភិវឌ្ឍប្រភពប្រាក់ចំណូលដទៃទៀត ដែលមានប្រសិទ្ធភាពពីព្រលានយន្តហោះនេះដូចជា ហាង សណ្ឋាគារ ចំណតរថយន្ត។ល។ ប្រភពប្រាក់ចំណូលទាំងនេះអាចយកមកប្រើប្រាស់ជាថវិកាមួយផ្នែកនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ។

**អត្ថប្រយោជន៍ទី២** និងការលើកទឹកចិត្តគន្លឹះសម្រាប់ ការប្រើប្រាស់ម៉ូឌែល PPP គឺការយល់ដឹងអំពីផលចំណេញដែលមានប្រសិទ្ធិភាព តាមរយៈការលើកកម្ពស់ការប្រគល់គម្រោងប្រតិបត្តិការ និងការគ្រប់គ្រង និងប្រើប្រាស់បច្ចេកទេសទំនើប។ គោលដៅគឺការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈដោយការប្រើប្រាស់នូវប្រសិទ្ធភាពរបស់វិស័យឯកជន។

**អត្ថប្រយោជន៍ទី៣** យល់ដឹងពីគំរូ PPP ទាក់ទងនឹងការបង្កើតឲ្យមានការដោះស្រាយបញ្ហា រយៈពេលយូរអង្វែង ដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ តាមរយៈការដោះស្រាយបញ្ហាដូចជាគុណភាព ការសាងសង់មានគុណភាពទាប និងការថែទាំពុំបានគ្រប់គ្រាន់។ តាមពិតបើសិនអ្នកជាអ្នកទទួលខុសត្រូវ ចំពោះការធ្វើប្រតិបត្តិការទ្រព្យសម្បត្តិរយៈពេល ២០ ឆ្នាំ អ្នកនឹងធ្វើយ៉ាងណាឲ្យទ្រព្យសម្បត្តិនោះត្រូវបានកសាងយ៉ាងត្រឹមត្រូវ និងមានគុណភាព។ ដូចគ្នានេះដែរ បើការទូទាត់ថវិកាឲ្យអ្នក ក៏ត្រូវផ្អាកប្រសិនបើទ្រព្យសម្បត្តិនោះពុំមានគុណភាពតាមស្តង់ដារ ដែលបានកំណត់ ដូច្នេះអ្នកនឹងច្បាស់ថាត្រូវការធនធានប៉ុន្មាន ដើម្បីបែងចែកធនធាននោះឲ្យបានគ្រប់គ្រាន់ ដើម្បីការថែរក្សាទ្រព្យសម្បត្តិនោះ។ ហេដ្ឋារចនាសម្ព័ន្ធ PPP ធ្វើឲ្យមានការលើកទឹកចិត្ត ដើម្បីកាត់បន្ថយចំណាយវដ្តជីវិតនៃទ្រព្យសម្បត្តិ។

**អត្ថប្រយោជន៍ទី៤** និងជាទីចុងក្រោយនៃម៉ូឌែល PPP ទាក់ទងនឹងការផ្ទេរហានិភ័យទៅឲ្យវិស័យឯកជន។ ដោយការផ្ទេរហានិភ័យទៅអោយវិស័យឯកជនថវិការបស់រដ្ឋាភិបាលគឺត្រូវបានការពារទប់ទល់ និងបញ្ហាទុនវិនិយោគដែលអាចកើនឡើងដែលជាទូទៅវាជារឿងសំខាន់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

### ១.៣.១.៣ ដែនកំណត់នៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

គម្រោង PPP មានដែនកំណត់មួយចំនួន ទីមួយគឺ PPP ពុំអាចប្រើប្រាស់បានគ្រប់ប្រភេទគម្រោងទេទោះជានៅប្រទេសដែល PPP ត្រូវបានអនុវត្តយ៉ាងសកម្មក៏ដោយ ក៏មានតែគម្រោងសាធារណៈមួយចំនួនប៉ុណ្ណោះដែលបានយកទៅអនុវត្តតាមម៉ូឌែលនេះ។ PPP មិនអាចអនុវត្តបាននៅក្នុងវិស័យដែលមានការផ្លាស់ប្តូរឆាប់រហ័សទេ ដូចជាវិស័យពត៌មានវិទ្យា (IT) ប៉ុន្តែអាចអនុវត្តបានល្អនៅពេលដែល

មានរយៈពេលវែង ក្នុងការប្រមើលពីភាពចាំបាច់សម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធ។ សំណួរគន្លឹះក្នុងចំណុចនេះ ថាតើយើងត្រូវការហេដ្ឋារចនាសម្ព័ន្ធដែលអាចប្រើប្រាស់បាន រយៈពេល២០ ឆ្នាំឬទេ? ប្រសិនចម្លើយវិជ្ជមាន នោះម៉ូដែល PPP អាចជាជម្រើសមួយដ៏ល្អ។

**ដែនកំណត់ទី២** ទម្រង់ដ៏ស្មុគស្មាញនៃគម្រោង PPP អាចធ្វើឲ្យមានការចំណាយប្រតិបត្តិការខ្ពស់។ គម្រោងត្រូវតែមានទំហំធំល្មម ដើម្បីសម្របសម្រួលជាមួយកិច្ចលទ្ធកម្ម។ សូមបញ្ជាក់ថាមានប្រទេសខ្លះយកគំរូ PPP ទៅអនុវត្តសម្រាប់គម្រោងដែលមានកម្រិតថវិកាខ្ពស់ជាងការកំណត់ទុក។ ឧទាហរណ៍៖ ២០លានដុល្លាអាមេរិក។

**ដែនកំណត់ទី៣ គឺសមត្ថភាព៖** ការអនុវត្តគម្រោងបែប PPP អាចធ្វើអោយវិស័យឯកជនក្នុងប្រទេសមិនអាចទទួលបានគម្រោងមូលហេតុបណ្ដាលមកពីការខ្វះសមត្ថភាព របស់ក្រុមហ៊ុនក្នុងស្រុកដើម្បីទទួលគម្រោងបែបនេះ។ ជាក់ស្ដែងក្រុមហ៊ុនក្នុងស្រុកអាចពុំមានសមត្ថភាពគ្រប់គ្រាន់សម្រាប់គ្រប់គ្រង ការរ៉ាប់រងហានិភ័យទាក់ទងនឹងគម្រោង PPP និយាយឲ្យចំគម្រោង PPP ត្រូវការធនធានមនុស្ស និងទុនវិនិយោគច្រើន។

**ដែនកំណត់ទី៤** តាមទស្សនៈនយោបាយ PPP ក៏ជាបញ្ហារសើបមួយផងដែរ។ សាធារណៈជនអាចមានអារម្មណ៍ថារដ្ឋាភិបាលកំពុងតែប្រគល់ឲ្យច្រើន ឬចិត្តល្អហួសហេតុពេកចំពោះដៃគូឯកជន។ លើសពីនេះការបង្កើត PPP អាចជាន់ និងការណែនាំបង្ហាញពី "គោលការណ៍អ្នកប្រើប្រាស់ត្រូវបង់ថ្លៃ" ដែលអាចធ្វើឲ្យសាធារណៈជនមិនពេញចិត្តនឹងរដ្ឋការ ឬអ្នកដឹកនាំ។ ដើម្បីជៀសវាងនឹងបញ្ហាទាំងនេះ ការគាំទ្រ គោលនយោបាយយ៉ាងពេញទំហឹងមានសារៈសំខាន់ណាស់ សម្រាប់ភាពជោគជ័យនៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន។

**ដែនកំណត់ចុងក្រោយ** រចនាសម្ព័ន្ធ PPP មានលក្ខណៈមិនងាយអាចបត់បែន និងពិបាកនៅក្នុងការសម្របសម្រួលការផ្លាស់ប្ដូរ។ ជាឧទាហរណ៍៖ វាអាចមានតម្លៃថ្លៃសម្រាប់អង្គភាពរដ្ឋ ដើម្បីកែគម្រោងយថាប្រភេទនៅពេលដែលគម្រោងត្រូវបានប្រគល់ឲ្យដៃគូឯកជន។

**១.៣.២ ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB)

ADB គឺជាធនាគារអភិវឌ្ឍន៍តំបន់មួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ ១៩៦៦ ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៃបណ្ដាប្រទេសនៅអាស៊ី។ ធនាគារនេះទទួលស្គាល់ដោយសមាជិកនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ( UNESCAP )ចំនួន ៣១ ប្រទេស នៅក្នុងការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ីនាដំណាក់កាលដំបូង។ បច្ចុប្បន្នធានាគារនេះមានសមាជិកចំនួន៦៧ ប្រទេសដែលក្នុងនោះ៤៨ប្រទេសស្ថិតក្នុងអាស៊ី និងប៉ាស៊ីហ្វិក និង១៩ ប្រទេសនៅខាងក្រៅតំបន់។ ក្នុងបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីប្ដេជ្ញា

កាត់បន្ថយភាពក្រីក្រនៅអាស៊ី និងប៉ាស៊ីហ្វិកតាមរយៈ កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្នភាព កំណើនដែលធានាដល់ចីរភាពបរិស្ថាន និងសមាហរណកម្មតំបន់។

បច្ចុប្បន្ន ADB ដើម្បីសម្រួល និងជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃបណ្តាប្រទេសជាសមាជិក ADB បានបង្កើតយន្តការមួយដែលមានឈ្មោះថា យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនយន្តការនេះនឹងអាចជួយបន្ថយសម្ពាធថវិកាជាតិ សម្រួលនូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឲ្យមានភាពទំនើប នាំឲ្យការផ្តល់សេវាសាធារណៈមានប្រសិទ្ធិភាព និងមានតម្លៃសមរម្យដែលប្រជាពលរដ្ឋអាចទទួលយកបាននឹងពេញចិត្ត។ នៅក្នុងគោលនយោបាយ PPP ធានាគារអភិវឌ្ឍន៍អាស៊ី គឺជាអ្នកផ្តួចផ្តើមឲ្យប្រទេសជាសមាជិកយកយន្តការ PPP មកអនុវត្តដោយស្ថាប័ននេះជាអ្នកផ្តល់បច្ចេកទេស និងប្រាក់កម្ចី។ ដើម្បីបង្ហាញនិងបង្រៀនដល់ឯកជននិងស្ថាប័នសាធារណៈអំពីយន្តការ PPP ធានាគារអភិវឌ្ឍន៍អាស៊ីបានដាក់កម្រងពត៌មាន និង ឯកសារទាក់ទងភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគេហទំព័ររបស់ស្ថាប័ន និងបង្កើតជាសៀវភៅណែនាំអំពី PPP និងបានបង្ហាញពីគម្រោង PPP នៃបណ្តាប្រទេសមួយចំនួននៅអាស៊ី ដែលអនុវត្តហើយទទួលបានជោគជ័យដែលសៀវភៅទាំងនោះមានជាអាទិ៍ PPP Handbook និង PPP Monitor។

**១.៣.២.១ វិស័យដ៏ពេញនិយមដែលកំពុងអនុវត្តតាមយន្តការ** PPP

នៅក្នុងវិស័យវិនិយោគសាធារណៈវិស័យដែលពេញនិយមនឹងអាចទទួលយកយន្តការ PPPមកអនុវត្តបានល្អ និងអាចទាក់ទាញវិស័យឯកជនមកចូលរួមវិនិយោគក្នុងវិស័យសាធារណៈបាន គឺវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមានដូចជា៖ ថាមពល, ប្រព័ន្ធទឹកស្អាត ឬទឹកសម្អុយ, វិស័យដឹកជញ្ជូន (ផ្លូវថ្នល់, ផ្លូវដែក,អាកាសយានដ្ឋាន), អប់រំនិងសុខាភិបាលជាដើមពីព្រោះ វិស័យទាំងនេះមានរយៈពេលផ្តល់សេវាយូរអាចឲ្យវិស័យឯកជន រកប្រាក់ចំណេញពីវិស័យនេះបានច្រើនជាពិសេស វិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងនេះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍កំពុងត្រូវការជាចាំបាច់ មិនអាចខ្វះបាន ជាក់ស្តែងដូចប្រទេសកម្ពុជាតម្រូវការវិស័យដឹកជញ្ជូនគ្រប់ប្រភេទជាពិសេសដឹកជញ្ជូនទំនិញសង្គម និងសេដ្ឋកិច្ចកម្ពុជាកំពុងតែមានតម្រូវការខ្លាំង ដោយសារតែការរីកចម្រើននៃសេដ្ឋកិច្ចជាតិពីមួយថ្ងៃទៅមួយថ្ងៃ។

**១.៣.២.២ ទម្រង់នៃគម្រោង** PPP

ទម្រង់នៃកិច្ចសន្យា PPP ឬគម្រោង PPP មានភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយអាស្រ័យទៅលើច្បាប់ឬស្ថានភាពសង្គមនិមួយៗ។ ប្រភេទកិច្ចសន្យា PPP ដែលជាមូលដ្ឋាននៃយន្តការ PPP មាន៖ កិច្ចសន្យាសេវាកម្ម, កិច្ចសន្យាការគ្រប់គ្រង, និងកិច្ចសន្យាជួល, សាងសង់-អាជីវកម្ម-ផ្ទេរ (BOT) និងការរៀបចំស្រដៀងគ្នា, សម្បទាន, ការបណ្តាក់ទុនរួមគ្នា និងការរៀបចំបែបចំរុះ ឬកូនកាត់។

ក្រៅពីទម្រង់ទាំងនេះក៏មានទម្រង់មួយចំនួនធំទៀតដែលកំពុងមានភាពពេញនិយមក្នុងទ្វីបអាស៊ី តាមការបង្ហាញរបស់ធានាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងសៀវភៅ PPP Handbook និង PPP Monitor ដែលទម្រង់ទាំងនេះមាន៖ build-operate-transfer (BOT), build-own-operate-transfer (BOOT), build-operate-own (BOO), build-lease-transfer (BLT), build-transfer-operate (BTO), contract-add-operate (CAO), design-build-finance-operate-transfer (DBFOT), develop-operate-transfer (DOT), rehabilitate-own-operate (ROO), rehabilitate-operate-transfer (ROT), transfer-operate-transfer (TOT), design-build-operate (DBO)។ ក្នុងចំណោមទម្រង់ដែលបានរៀបរាប់ទាំងអស់ខាងលើទម្រង់ដែលពេញនិយមជាងគេសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ គឺកិច្ចសន្យាសេវាកម្ម(៣៣.៣៣%),ទម្រង់ BOT ( ២៦.៦៧%), និងសម្បទាន (១៧.១៤%)ដែលបង្ហាញដោយ ADB ។

**១.៣.២.៣ ការផ្តល់ហិរញ្ញប្បទានគម្រោង**

ហិរញ្ញប្បទានគម្រោង គឺជារឿងសំខាន់នៃយន្តការ PPP ប្រសិនបើគម្រោងវិនិយោគមិនមានការទាក់ទាញការផ្តល់ហិរញ្ញប្បទានពីធានាគារនោះទេគម្រោង ក៏មិនអាចដំណើរការបាន ពីព្រោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ PPP ជាធម្មតា គឺត្រូវការការផ្តល់ហិរញ្ញប្បទាន។ ប្រភពហិរញ្ញប្បទាននៃគម្រោងPPP អាចមកពីវិស័យឯកជន ឬវិស័យសាធារណៈប៉ុន្តែភាពជាក់ស្តែងប្រទេសកំពុងអភិវឌ្ឍន៍មិនមានលទ្ធភាពផ្តល់ហិរញ្ញប្បទានច្រើនសម្រាប់គម្រោង PPP បានទេ គឺវិស័យឯកជនត្រូវពឹងផ្អែកកម្ចីពីធនាគារ។ ក្នុងចំណុចនេះដើម្បីទទួលបានកម្ចី គម្រោងវិនិយោគត្រូវតែមានភាពទាក់ទាញផ្នែកហិរញ្ញវត្ថុ។ គម្រោងដែលទាក់ទាញផ្នែកហិរញ្ញវត្ថុជាគម្រោងដែលមានការបង្ហាញ ឬមានការបែងចែកហានិភ័យគម្រោង ឬហានិភ័យផ្សេងៗដែលជាប់ទាក់ទង នឹងគម្រោងច្បាស់លាស់ និងអាចទទួលយកបាន។ ស្ថាប័នហិរញ្ញវត្ថុនឹងផ្តល់ហិរញ្ញប្បទានដល់គម្រោងនូវពេលដែលខ្លួនសិក្សាពីហានិភ័យ និងលទ្ធភាពសងត្រលប់ពីកូនបំណុល (ចំណូល និងចំណាយរបស់គម្រោង, ចំណូលបន្ថែមនៃគម្រោង) និងកត្តាផ្សេងៗទៀតនៃគម្រោងដែលអាចឲ្យស្ថាប័នហិរញ្ញវត្ថុទទួលបានការសងត្រលប់ ពីកូនបំណុលទាន់ពេលវេលា ទើបស្ថាប័នយល់ព្រមផ្តល់កម្ចី។ ស្ថាប័នហិរញ្ញវត្ថុក៏អាចបញ្ឈប់ការផ្តល់កម្ចីបានផងដែរ ប្រសិនបើការស្នើសុំឲ្យកែប្រែលក្ខខណ្ឌណាមួយរបស់ខ្លួនក្នុងការព្រមព្រៀង ឬចុះកិច្ចសន្យាអនុវត្តគម្រោង PPP របស់វិនិយោគិននិងវិស័យសាធារណៈមិនមានការយល់ព្រមពីភាគី។ នៅមានវិធីសាស្ត្រកៀងគរហិរញ្ញប្បទានមួយបែបទៀត ដើម្បីដោះស្រាយ ហានិភ័យហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាជីវកម្មជាជាងការខ្ចីដើមទុនដោយផ្ទាល់។ សម្រាប់ហិរញ្ញវត្ថុគម្រោង ក្នុងន័យនេះគេត្រូវបង្កើតក្រុមហ៊ុនមួយសម្រាប់គម្រោងដែលគេស្គាល់ថាជា "សហគ្រាសគម្រោង" ឬ SPV ដើម្បីទទួលបានហិរញ្ញប្បទាន និងដើម្បីអនុវត្តសកម្មភាពគម្រោង។ ជាគោលការណ៍ច្បាប់ការធ្វើបែបនេះជួយ អង្គភាពអាណាព្យាបាលបញ្ចៀសនូវហានិភ័យហិរញ្ញវត្ថុដោយផ្ទាល់ ដែលទាក់ទងនឹងគម្រោង។ ម្ចាស់បំណុលអាចពឹងផ្អែកទៅលើ

ចំណូលរបស់គម្រោងសម្រាប់ធានាកម្ចីឥណទាន ដែលជាហានិភ័យកម្រិតខ្ពស់ហើយទាមទាការពិនិត្យពិច័យខ្លាំង។ ហិរញ្ញវត្ថុគម្រោង គឺជាដំណោះស្រាយដ៏ល្អសម្រាប់ PPP នៅក្នុងរចនាសម្ព័ន្ធគម្រោងភាគច្រើននៃទំនាក់ទំនងកិច្ចសន្យា គឺស្ថិតនៅជាមួយសហគ្រាសគម្រោង ហើយជាអ្វីដែលសំខាន់បំផុតនោះគឺ កិច្ចសន្យា PPP ដែលចុះហត្ថលេខារវាងអង្គភាពរដ្ឋាភិបាល និងសហគ្រាសគម្រោង។ ដើម្បីអនុវត្តគម្រោងសហគ្រាសគម្រោង នឹងធ្វើអនុកិច្ចសន្យាសកម្មភាពគម្រោង ជាមួយក្រុមហ៊ុនផ្សេង។ ឧទាហរណ៍៖ គម្រោងសំណង់ គឺជាការចុះអនុកិច្ចសន្យាលើ "វិស្វកម្ម លទ្ធកម្ម និងសំណង់" ឬ អ្នកម៉ៅការ EPC កិច្ចសន្យា ហើយការធ្វើប្រតិបត្តិការ និងការថែទាំក៏ផ្តល់ឲ្យអ្នកម៉ៅការ O&M។

## ១.៤ ច្បាប់ និងបទប្បញ្ញត្តិភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់ប្រទេសកម្ពុជា

សញ្ញាណភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជាមានតាំងពីការដាក់ឲ្យអនុវត្តច្បាប់វិនិយោគឆ្នាំ ១៩៩៤ មកម្ល៉េះហើយច្បាប់នេះបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៣ នឹងមានសញ្ញាណកាន់តែច្បាស់ គឺច្បាប់សម្បទានឆ្នាំ២០០៧ ពីព្រោះសម្បទាន គឺជាផ្នែកមួយនៃ PPP។ ចុងឆ្នាំ២០១៦ កម្ពុជាមានគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនពិតប្រកដ ដោយមានការជួយជ្រុំជ្រែងពី ADB និង UNESCAP ដែលគោលនយោបាយនេះឈ្មោះថា ការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាង និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ:២០១៦-២០២០។

### ១.៤.១ ច្បាប់វិនិយោគ

ច្បាប់វិនិយោគបង្កើតមក ដើម្បីគ្រប់គ្រងទំនាក់ទំនងវិនិយោគកម្ពុជា និងជាពិសេសដើម្បីទាក់ទាញវិនិយោគិនបរទេសឲ្យចូលមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជា។ ច្បាប់នេះមានវិសាលភាព ចំពោះគម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ និងកំណត់ពីនីតិវិធីនៃការបង្កើតគម្រោងមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយក្នុងដែនដីកម្ពុជា។

មានតែគម្រោងវិនិយោគ មានលក្ខណ:សម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបានផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌច្បាប់នេះ។ គម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់គឺ ជាគម្រោងវិនិយោគ ដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអ្នកវិនិយោគមានវិញ្ញាបនបត្រនេះទើបមានសិទ្ធិអាចធ្វើសម្បទានដែលផ្តល់ដោយរដ្ឋ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នតែមួយគត់ដែលអាចចេញវិញ្ញាបនបត្រចុះបញ្ជីវិនិយោគដល់អ្នកស្នើសុំ វិនិយោគក្នុងដែនដីកម្ពុជា។ បើយើងពិនិត្យមើលច្បាប់វិនិយោគទាំងពីរ គឺច្បាប់វិនិយោគឆ្នាំ១៩៩៤ និងច្បាប់វិសោធនកម្មច្បាប់វិនិយោគឆ្នាំ២០០៣ គឺបានផ្តល់ផលប្រយោជន៍ដល់ វិស័យឯកជនច្រើនដែលអាចទាក់ទាញវិនិយោគិនឯកជនឲ្យចូល មកវិនិយោគក្នុងប្រទេសកម្ពុជាច្រើនគួរអោយគត់សម្គាស់ ជាក់ស្តែងរោងចក្រកាត់ដេរសម្លៀកបំពាក់ រោងចក្រវារីអគ្គិសនី វិស័យអចលនទ្រព្យ និងសម្បទានដីសេដ្ឋកិច្ចជាដើម។

ច្បាប់វិនិយោគកម្ពុជា គឺផ្នែកមួយនៃភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងប្រទេសកម្ពុជា ពីព្រោះច្បាប់នេះបានផ្តល់ផលប្រយោជន៍ដល់វិស័យឯកជនច្រើន ហើយច្បាប់នេះក៏បានសម្រួលនីតិវិធីស្នើសុំវិនិយោគឲ្យមានភាពងាយស្រួល ដែលបានចង្អុលបង្ហាញទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកមានតួនាទីទទួលបន្ទុកចុះបញ្ជីវិនិយោគផងដែរ។

### **១.៤.២ ច្បាប់សម្បទាន**

ច្បាប់សម្បទានត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលចែកចេញជា៦ជំពូក និង៥៣ មាត្រា។ ច្បាប់នេះមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយហិរញ្ញប្បទានឯកជននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងបំពេញសេចក្តីត្រូវការរបស់សង្គម និងសេដ្ឋកិច្ចជាតិ។[7] សម្បទានសំដៅដល់ទង្វើណាមួយជារបស់រដ្ឋ ដែលស្ថាប័នមានសមត្ថកិច្ចផ្តល់ទង្វើនោះ ទៅឲ្យឯកជននូវផ្នែកណាមួយ ឬទាំងស្រុងនៃការ អនុវត្តគម្រោងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធណាមួយ ដែលជាធម្មតាស្ថាប័នមានសមត្ថកិច្ចនោះជាអ្នកទទួលខុសត្រូវ ហើយដែលឯកជននោះ ទទួលភារកិច្ចមួយផ្នែកធំលើការ សាងសង់ និង/ឬហានិភ័យ ឬទទួលបាននូវផលចំណេញតាមរយៈការទូទាត់សងវិញពីរដ្ឋាភិបាលនូវប្រាក់ចំណូល ឬកម្រៃ និងការយកថ្លៃឈ្នួលដែលបានប្រមូលយកពីអ្នកប្រើប្រាស់ ឬពីអតិថិជន។ ទង្វើរបស់រដ្ឋទាំងនោះចាប់ពីពេលនេះតទៅនឹងត្រូវកំណត់ថា "សម្បទាន" នៅក្រោមច្បាប់នេះដោយមិនគិតពីឈ្មោះស្របច្បាប់ដែលបានប្រើប្រាស់សម្រាប់ទង្វើនោះឡើយ។[8]

ច្បាប់សម្បទានបានកំណត់ពីនីតិវិធីសម្បទាន, ទម្រង់នៃសម្បទាន ស្ថាប័នមានសមត្ថកិច្ចធ្វើសម្បទាន និងវិស័យដែលរដ្ឋធ្វើសម្បទាន ដើម្បីទាក់ទាញអ្នកវិនិយោគិនឲ្យចូលមកវិនិយោគវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជាដោយហិរញ្ញប្បទានឯកជន ដោយរដ្ឋាភិបាលសង្ឃឹមថាវិស័យឯកជន និងធ្វើឲ្យវិស័យហេដ្ឋានរចនាសម្ព័ន្ធសាធារណៈកម្ពុជា មានភាពទំនើបទាន់សម័យព្រមទាំងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា សង្គម និងសេដ្ឋកិច្ចជាតិបានគ្រប់គ្រាន់។ សរុមមកច្បាប់សម្បទានឆ្នាំ២០០៧ គឺជាបទប្បញ្ញត្តិដែលបើកផ្លូវឲ្យវិនិយោគិនឯកជនចូលមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជាតាមយន្តការ PPP ជាក់ស្តែងសម្បទានថែទាំ និងសេវាកម្មផ្លូវជាតិលេខ៤។

### **១.៤.៣ ឯកសារគោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០**

[7] មាត្រា១ ច្បាប់សម្បទាន២០០៧

[8] មាត្រា៣ ច្បាប់សម្បទាន២០០៧

រាជរដ្ឋាភិបាលកម្ពុជា បានខិតខំវិនិយោគយ៉ាងគំហុក និងប្រកបដោយវិចារណកម្មខ្ពស់លើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដោយប្រើប្រាស់ប្រភពទុនហិរញ្ញប្បទាន ជាប្រពៃណីផ្អែកលើលទ្ធភាពថវិកាជាតិដែលខ្លួនមាន និងក៏ដូចជាប្រភពធនធានហិរញ្ញប្បទាន ដែលកៀងគរបានពីដៃគូអភិវឌ្ឍន៍នានា ក្នុងការអភិវឌ្ឍន៍ប្រទេសជាច្រើនអាណត្តិមកហើយ។ បើទោះជាយ៉ាងនេះក្តីក៏នៅតែមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណ និងប្រសិទ្ធភាពចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន ក៏ដូចជាប្រភពធនធានហិរញ្ញប្បទានដែលកៀងគរបានពីដៃគូអភិវឌ្ឍន៍នានានៅឡើយ ដែលតម្រូវឲ្យកម្ពុជានៅតែត្រូវបន្ត ខិតខំកៀងគរការចូលរួមវិនិយោគពីវិស័យឯកជនលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈបន្ថែមទៀត។ ការចូលរួមវិនិយោគពីវិស័យឯកជន មិនត្រឹមតែនាំមកនូវប្រភពហិញ្ញប្បទានបន្ថែមប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវ ចំណេះដឹង-ចំណេះធ្វើ ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំ និងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុនទៀតផង។

ក្នុងក្របខ័ណ្ឌនេះ ច្បាប់សម្បទាន ក៏ត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៧ ដែលមានគោលបំណងជម្រុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្អែកឯកជន។ បើទោះបីជាយ៉ាងនេះក្តី អនុក្រឹត្យ, លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្តច្បាប់នេះ នៅមិនទាន់បានរៀបចំ និងដាក់ឲ្យអនុវត្តនៅឡើយ ជាហេតុធ្វើឲ្យយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមិនទាន់អាចអនុវត្តបានទាំងស្រុងនិងមានប្រសិទ្ធភាពពេញលេញ ពោលកន្លងមកការរៀបចំ, ការចរចា និងការគ្រប់គ្រងអនុវត្តគម្រោង មានភាពរប៉ាត់រប៉ាយ, ប្រើប្រាស់យន្តការចំពោះកិច្ច និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុគម្រោងដែលមិនទាន់អនុលោមទាំងស្រុង តាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយ ជាហេតុដែលតម្រូវឲ្យមានគោលនយោបាយថ្មីមួយដើម្បីគាំទ្រក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មីនេះ។

ក្នុងដំណាក់កាលអភិវឌ្ឍថ្មីនេះ កម្ពុជាត្រូវប្រឈមចំពោះបញ្ហាធំៗចំនួន០២ រួមមាន៖ (១)ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសាកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗនិង(២)ការធ្លាក់ចុះនៃឥណទានសម្បទានកម្រិតខ្ពស់ នៅពេលដែលកម្ពុជាទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ស្របពេលជាមួយគ្នានេះ ចំពោះមុខស្ថានភាពដែលប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅលើសកលលោកកំពុងរងសម្ពាធនៃការកើនឡើងនូវបន្ទុកសេវាបំណុលសាធារណៈ ដែលបណ្តាល មកពីការប្រើប្រាស់យ៉ាងច្រើនលើសលុបនូវឥណទានពីប្រភពនានាសម្រាប់វិនិយោគ ដៃគូអភិវឌ្ឍន៍ពហុភាគី

បានប្រកាសដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មី គឺប្រើប្រាស់ **"យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គម្រោងវិនិយោគសាធារណៈ"** និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការរៀបចំយន្តការនេះ ទាំងក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ ។

បើទោះបីស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា មានចីរភាពក្នុងរយៈពេលវែងខុសពីស្ថានភាពបំណុលសាធារណៈរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍មួយចំនួនក្តី ផ្អែកតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជានៅតែត្រូវការយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលសម្រេចរៀបចំ និងដាក់អោយអនុវត្តនូវ **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០"** ប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដែលនឹងជួយកែលម្អនិងលើកកម្ពស់បរិស្ថានអំណោយផលសម្រាប់បន្តជម្រុញការចូលរួមរបស់វិស័យឯកជនលើការវិនិយោគសាធារណៈ, បង្កើតជាប្រភពហិរញ្ញប្បទានថ្មីសម្រាប់បំពេញបន្ថែមលើប្រភពទុនវិនិយោគសាធារណៈជាប្រពៃណីរបស់រដ្ឋ និងរួមចំណែកដល់ការពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុរបស់កម្ពុជា។ ឯកសារគោលនយោបាយនេះដាក់ចេញនូវវិធានការគោលនយោបាយ ដែលជាផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដាក់វិស័យអាទិភាពនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន រួមមាន៖ (១) វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និង (២) វិធានការគោលនយោបាយរយៈពេលមធ្យមនិងវែង។ ទន្ទឹមនេះឯកសារគោលនយោបាយនេះ ក៏បានដាក់ចេញផងដែរនូវផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីរាជការ ពាក់ព័ន្ធនឹងវដ្តគម្រោងវិនិយោគសាធរណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ។

ឯកសារគោលនយោបាយនេះ មានគោលបំណងជម្រុញ និងលើទឹកចិត្តការវិនិយោគរបស់ វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការចូលរួមស្តារ, កសាង, ប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈព្រមទាំងវិសយបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងៗទៀត ប្រកបដោយនវានុវត្តភាពខ្ពស់ស្របតាមឧត្តមានុវត្ត ជាអន្តរជាតិសំដៅរួមចំណែកទ្រទ្រង់ចីរភាព នៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក។ ដើម្បីឲ្យគោលនយោបាយ PPP អនុវត្តបានជោគជ័យរាជរដ្ឋាភិបាលបានដាក់យុទ្ធសាស្ត្រគន្លឹះ គឺការរៀបចំ និងដាក់ចេញនូវ **វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និងសម្រាប់រយៈពេលមធ្យម និងវែង** ដោយនឹងត្រូវអនុវត្តតាមអភិក្រម ជាជំហានៗរួមមាន៖

១. ការចាប់ផ្តើមចេញពីការពិនិត្យ និងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្ត, ការដាក់ឲ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ការបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ និងការកំណត់យន្តការស្ថាប័ន ព្រមទាំងបង្កើតគណៈកម្មការអន្តរក្រសួង ជាស្ថាប័នបណ្តោះអាសន្នសម្រាប់គ្រប់គ្រង និងសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រនេះ។

២. អភិក្រម "**រៀនផង-ធ្វើផង**"

៣. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស តាមក្រសួង ស្ថាប័នពាក់ព័ន្ធ។

**វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ**

១. បង្កើតគណៈកម្មការអន្តរក្រសួងបណ្តោះអាសន្ន ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងធ្វើសំណើសុំធ្វើវិសោធនកម្ម ឬសំណើសុំរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីយន្តការ PPP តាមការចាំបាច់ ។

- រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, នីតិវិធីគ្រប់គ្រងកិច្ចលទ្ធកម្ម និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុ។ល។

- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាពតាមយន្តការ PPP និងលទ្ធភាពនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពតាមគោលការណ៍ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព, តម្លាភាព យុត្តិធម៌ និងដោយមានការផ្សព្វផ្សាយជាសាធារណៈ។

មុខងារ និងភារកិច្ចទាំងនេះនឹងត្រូវផ្ទេរជូនយន្តការអចិន្ត្រៃយ៍ដែលនឹងត្រូវពិនិត្យ និងសម្រេចដោយរាជរដ្ឋាភិបាល។ គណៈកម្មការអន្តរក្រសួងនេះ មានក្រុមការងារបច្ចេកទេសសម្របសម្រួលការអនុវត្តគោលនយោបាយ PPP ជាលេខាធិការដ្ឋាន។

២. បង្កើត និងដាក់ឲ្យអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility-PDF) សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការរៀបចំគម្រោង ដោយគិតចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពបឋម រហូតដល់ដំណាក់កាលប្រគល់កិច្ចសន្យាសម្បទាន។

៣. រៀបចំ និងកំណត់យន្តការស្ថាប័នដោយ៖

- ធ្វើសមហរណកម្មមុខងារនៃអង្គភាព PPP ថ្នាក់កណ្តាល និងអង្គភាពគ្រប់គ្រងហានិភ័យទៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បង្កើត ឬធ្វើសមាហរណកម្មមុខងារនៃអង្គភាព PPP នៅតាមក្រសួងស្ថាប័នតាមវិស័យ។

៤. ត្រូវផ្តោតលើគម្រោងអាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចខ្ពស់មួយចំនួនសិនដោយត្រូវអនុវត្តតាមទម្រង់ "**ការទូទាត់ផ្អែកលើផលចំណូល**"

៥. រៀបចំ និងដាក់ឲ្យអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

**វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង**

១. បន្តពិនិត្យ និងកែសម្រួលឡើងវិញ តាមការចាំបាច់នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ, យន្តការស្ថាប័ន, នីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុ និងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP។

២. ពិនិត្យលទ្ធភាពលើការរៀបចំបង្កើត និងដាក់ឲ្យអនុវត្តនូវមូលនិធិបំពេញហិរញ្ញវត្ថុ (Viability Gap Fund-VGF)។

៣. ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

៤. ពិនិត្យលទ្ធភាពបង្កើនចំនួនគម្រោង និងពិចារណាលើការអនុវត្តទម្រង់ទូទាត់ផ្សេងទៀតដូចជា "**ការទូទាត់ផ្អែកលើថវិកាជាតិ**" និង "**ការទូទាត់តាមវិធីចម្រុះ**"។

ជាមួយគ្នានេះ ត្រូវធ្វើបច្ចុប្បន្នកម្មលើបញ្ជីគម្រោងអាទិភាព ដោយនឹងពិនិត្យលទ្ធភាពឈានទៅបន្ថែមវិស័យអាទិភាពមួយចំនួនទៀត រួមមាន៖

- ✓ ហេដ្ឋារចនាសម្ព័ន្ធឧស្ម័ន និងប្រេងកាត
- ✓ វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន
- ✓ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្រ្ត និងកសិកម្ម និង
- ✓ វិស័យអាទិភាពដទៃទៀត។

សម្រាប់រយៈពេលវែង អាចនឹងឈានទៅពិនិត្យលទ្ធភាពលើការវិនិយោគក្នុងវិស័យសង្គមកិច្ចបន្ថែមទៀតដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធសេវាសុខភាពសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធអប់រំ និងកីឡាជាដើម។

# ជំពូកទី២
# ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យវិនិយោគសាធារណៈកម្ពុជា

## ២.១ ទិដ្ឋភាពទូទៅភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជា

នៅឆ្នាំ ២០០៧ កម្ពុជាមានច្បាប់សម្បទានដែលច្បាប់នេះបើកផ្លូវឲ្យវិស័យឯកជនចូលមកវិនិយោគវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅកម្ពុជា ដែលហិរញ្ញប្បទានជារបស់វិស័យឯកជន។ ក្នុងក្របខ័ណ្ឌច្បាប់សម្បទាននេះកម្ពុជាមិនទាន់បានដាក់ចេញនូវ អនុក្រឹត្យ, លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្តច្បាប់នេះ នៅមិនទាន់បានរៀបចំ និងដាក់ឲ្យអនុវត្តនៅឡើយ ជាហេតុធ្វើឲ្យយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមិនទាន់អាចអនុវត្តបានទាំងស្រុង និងមានប្រសិទ្ធភាពពេញលេញ ពោលកន្លងមកការរៀបចំ, ការចរចា និងការគ្រប់គ្រងអនុវត្តគម្រោងមានភាពរប៉ាត់រប៉ាយប្រើប្រាស់យន្តការចំពោះកិច្ច និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុគម្រោងដែលមិនទាន់អនុលោម ទាំងស្រុងតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយ។ អនុឡោមតាមច្បាប់សម្បទានគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈធំៗ មួយចំនួនត្រូវបានបង្កើតឡើងដែលគម្រោងទាំងនេះមានគម្រោងសម្បទានសម្រាប់ការថែទាំ និងសេវាកម្មលើផ្លូវជាតិលេខ៤ គម្រោងវារីអគ្គិសនីនៅស្ទឹងឬស្សីជ្រុំមានថាមពល៣៣៨ មេហ្គាវ៉ាត់ និងសម្បាទានឲ្យក្រុមហ៊ុនឯកជន Cambodia Airports គ្រប់គ្រងប្រលានយន្តហោះទាំង៣ កន្លែងនៅប្រទេសកម្ពុជាក្រោមកិច្ចសន្យាសម្បទានរយៈពេលវែង។ ដែលប្រលានយយន្តហោះទាំង៣ នោះមួយកន្លែងនៅរាជធានីភ្នំពេញ មួយកន្លែងនៅខេត្តសៀមរាប និងមួយកន្លែងទៀតនៅឆ្នេរសមុទ្រក្រុងព្រះសីហនុជាដើម។ ដោយឃើញពីភាពមិនទាន់គ្រប់ជ្រុងជ្រោយនៃច្បាប់សម្បទាន និងការអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឲ្យមានគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ឡើងដោយមានការជួយពីធានាគារអភិវឌ្ឍន៍អាស៊ី។ គោលនយោបាយនេះបានកំណត់ជំហានដែលអង្គភាពសាធារណៈត្រូវដើរ កំណត់យន្តការស្ថាប័ន និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព និងភាពប្រទាក់ក្រឡាគ្នា។ យន្តការស្ថាប័នគឺបានប្រគល់ការតាក់តែង ការអនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ PPP ទៅឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយក្រសួងបានបង្កើត គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ PPP បង្កើតឲ្យមានអង្គភាព PPP នៅក្រោម អគ្គនាយកដ្ឋានថវិការបស់ក្រសួង។ ក្រៅពីការបែងចែកឲ្យមានស្ថាប័នច្បាស់លាស់ គឺនៅមានយន្តការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្សសំរាប់យន្តការ PPP។ នៅក្នុងយន្ត

ការស្ថាប័ននេះក្រុមប្រឹក្សាអភិវឌ្ឍន៍ក៏មានតួនាទីទាក់ទងនិង PPP ដែរ គឺស្ថាប័ននេះជា ច្រកចេញ-ចូលតែមួយក្នុងនីតិវិធីផ្តល់សិទ្ធ និងចេញនូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរដល់អ្នកស្នើសុំវិនិយោគនៅក្នុងប្រទេសកម្ពុជា ក្រៅពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្ថាប័នទទួលបន្ទុកតាមវិស័យក៏មានតួនាទីក្នុងយន្តការ PPP ដែរជាពិសេសជាអ្នកទទួលបន្ទុកចុះកិច្ចសន្យាសម្បទាន។ បន្ថែមពីយន្តការទាំងនេះរាជរដ្ឋាភិបាលបង្កើតឲ្យមានយន្តការគាំទ្រហិរញ្ញវត្ថុ ដើម្បីជាប្រភពថវិកាសម្រាប់គាំទ្រគម្រោង PPP។ យន្តការហិរញ្ញវត្ថុមានដូចជាមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility –PDF) និងមូលនិធិបំពេញផលហិរញ្ញវត្ថុ (Viability Gap Fund-VGF)។ ថ្មីៗនេះគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាច្រើនត្រូវបានអង្គភាពសាធារណៈ សិក្សាសមិទ្ធិលទ្ធភាពដើម្បីដាក់ឲ្យវិស័យឯកជនវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលគម្រោងទាំងនេះមានជាអាទិ៍ផ្លូវរថភ្លើងល្បឿនលឿនពីភ្នំពេញ-បាវិត, ភ្នំពេញ-សៀមរាប។

## ២.២ ស្ថាប័នទទួលបន្ទុកអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

ច្បាប់វិនិយោគនៃព្រះរាជរាណាចក្រកម្ពុជា ច្បាប់សម្បទាន និងឯកសារគោលនយោបាយការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ បានចង្អុលបង្ហាញក្រសួងស្ថាប័ននិងអង្គភាពសាធារណៈមួយចំនួនទាក់ទងនឹងការ វិស័យវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលស្ថាប័នទាំងនោះមានដូចបង្ហាញខាងក្រោម ៖

### ២.២.១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជុំវិញគោលនយោបាយ PPP ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្តរាល់វិធានការ ដែលបានដាក់ចេញក្នុងគោលនយោបាយ PPP ឲ្យមានប្រសិទ្ធភាពខ្ពស់។ ក្នុងការទទួលបន្ទុកជាស្ថាប័ននាំមុខនេះក្រសួង គឺជាអ្នកតាក់តែងគោលនយោបាយអនុវត្ត និងផ្សព្វផ្សាយគោលនយោបាយឲ្យបានទូលំទូលាយ និងជាអ្នកគាំទ្រហិរញ្ញវត្ថុដល់គោលនយោបាយ PPP ជាពិសេសជាអ្នកត្រួតពិនិត្យ វាយតម្លៃការអនុវត្តគម្រោង PPP។

#### ២.២.១.១ គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ PPP

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនបង្កើតឡើងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ដែលគណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២. ឯកឧត្តម **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | |

| | | |
|---|---|---|
| | នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤. ឯកឧត្តម **ថេង បញ្ញាធន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយក ផែនការនៃក្រសួងផែនការ | អនុប្រធាន |
| ៥. ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. លោកជំទាវ **ប៉ែន ឆដា** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧. ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨. លោកជំទាវ **តឹករ៉េក កំរង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. ឯកឧត្តម **គឹម ទូច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០. ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១១. ឯកឧត្តម **ទេព ធន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីកម្ម និង សំណង់ | សមាជិក |
| ១២. ឯកឧត្តម **សៅ សុភាព** | ទីប្រឹក្សាអមក្រសួង និងជានាយកខុទ្ទកាល័យក្រសួង បរិស្ថាន | សមាជិក |
| ១៣. ឯកឧត្តម **សុង គុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤. ឯកឧត្តម **ជិន ម៉ាលីន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៥. ឯកឧត្តម **ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦. ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ១៧. ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. ឯកឧត្តម **គុណ ញឹម** | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាកសហវ | សមាជិក |
| ១៩. ឯកឧត្តម **ហាវ រតនៈ** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ២០. ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** | អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ កសហវ | សមាជិក |
| ២១. ឯកឧត្តម **ប៉ែន ធីរុង្គ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិនិងគ្រប់គ្រងបំណុល កសហវ | សមាជិក |
| ២២. លោក **គីមទី កោមលី** | អគ្គនាយករងបច្ចេកទេសនៃធានាគារជាតិនៃកម្ពុជា | សមាជិក |
| ២៣. លោក **ស៊ីន ចាន់សេរីវុត្ថា** | អគ្គនាយករងនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ២៤. លោក **ចន ណារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ កសហវ | សមាជិក |
| ២៥. លោក **ស៊ាង ផល្លា** | ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម កសហវ | សមាជិក |

**មុខងារ និងភារកិច្ចរបស់គណកម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេស PPP**

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងរៀបចំ និងផ្តល់អនុសាសន៍ក្នុងការធ្វើវិសោធនកម្ម ឬធ្វើសំណើរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនតាមការចាំបាច់។

- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធភាពនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពរួមទាំងគម្រោងដែលនឹងដាក់ឲ្យអនុវត្តសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

- បូកសរុបរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាពត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[9]

គណៈកម្មការអន្តរក្រសួងដឹកនាំអនុវត្តគោលនយោបាយ PPP មានក៏មានក្រុមការងារបច្ចេកទេសផងដែរ ដែលមាន ឯកឧត្តម **ប៉ែន ធីរុង្គ** ជាប្រធាន។ ក្រុមការងារបច្ចេកទេសសម្រាប់សម្របសម្រួលការអនុវត្តគោលនយោបាយ PPP មានភារៈកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគតាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជន។

- ផ្តល់ការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចចុះកិច្ចសន្យាជាមួយដៃគូឯកជន ក្នុងការកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងការអនុវត្តគម្រោង។

- ពិនិត្យ និងតាមដានលើកិច្ចប្រតិបត្តិការនៅ គ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

- ផ្តល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងលើការអនុវត្ត និងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

[9] ប្រការ២. សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់គាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារសិក្សា និងការរៀបចំគម្រោងព្រមទាំងប្រតិបត្តិការនានា ដើម្បីឈានដល់ការប្រគល់កិច្ចសន្យាអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តជូន គណៈកម្មការអន្តរក្រសួង។

-បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការកំណត់របស់ប្រធានគណៈកម្មការអន្តរក្រសួង ។[10]

**២.២.១.២ ការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និងស្ថាប័ន**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់យកការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ គឺជាកិច្ចការអាទិភាពដ៏សំខាន់ក្នុងការរួមចំណែកជម្រុញការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនតាំងពីមិនទាន់មានគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនច្បាស់លាស់មកម្ល៉េះ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយកចិត្តទុកដាក់ជាប់ជាប្រចាំលើកិច្ចការពង្រឹងសមត្ថភាពស្ថាប័ន និងបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្តោតសំខាន់លើមុខងារគន្លឹះទាំងពីគឺៈ អង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល (Central PPP Unit) និងអង្គភាពគ្រប់គ្រងហានិភ័យ(Risk Management Unit )។ ទន្ទឹមនេះ វគ្គបណ្តុះបណ្តាលមួយចំនួន ក៏មានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធផងដែរ។ វឌ្ឍនភាពនៃការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស នៃមុខងារទាំងពីរនារយៈកាលកន្លងមកមានដូចខាងក្រោមៈ

- **ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស**

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនាពេលកន្លងមក កម្ពុជាទទួលបាននូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការខ្ពស់ ពីបណ្តាដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្នុងរូបភាពជាការផ្តល់ជំនួយទាំងបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងស្រុក និងការចូលរួមវគ្គបណ្តុះបណ្តាល, សិក្ខាសាលា, សន្និសីទ និងវេទិកាអន្តរជាតិ ក្រៅប្រទេសលើមុខជំនាញ និងប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោង និងការវិភាគហានិភ័យនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ទន្ទឹមនេះ កម្ពុជាក៏បានទទួលនូវកិច្ចសហការខ្ពស់ និងការស្វាគមន៍យ៉ាងកក់ក្តៅពីប្រទេសជាមិត្តក្នុងតំបន់មួយចំនួន រួមមានៈ ឥណ្ឌូនេស៊ី, ហ្វីលីពីន, ថៃ, សាធារណៈរដ្ឋកូរ៉េ, ចិន និងឥណ្ឌា លើ

[10] ប្រការ៤. សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍ ពីការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅក្នុងបណ្តាប្រទេសទាំងនោះផងដែរ។

ជាមួយ ការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ទាំងក្នុង និងក្រៅប្រទេស, សន្និសីទ និងវេទិកាអន្តរជាតិ ព្រមទាំងទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសនានាក្នុងតំបន់ នាពេលកន្លងមក គឺជាកាលានុវត្តភាពដ៏សំខាន់សម្រាប់មន្ត្រីពាក់ព័ន្ធ ក្នុងការអភិវឌ្ឍសមត្ថភាពជំនាញរបស់ខ្លួន តាមរយៈការក្រេបជញ្ជក់នូវចំណេះដឹងថ្មីៗបន្ថែម និងដកស្រង់បទពិសោធន៍ពីការអនុវត្តជាក់ស្តែងនៅតាមបណ្តាប្រទេសនានាលើសកលលោក។ ចំណេះដឹង និងបទពិសោធន៍ដែលទទួលបានទាំងនោះ គឺជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្រ្ត និងបទប្បញ្ញត្តិពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងប្រតិបត្តិការ ដូចជា៖ ១) ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ២) ឯកសារយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, ៣) គោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ, ៤)សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការធានារបស់រដ្ឋ និង ៥) សេចក្តីព្រាងគោលនយោបាយរួមសម្រាប់គ្រប់គ្រងការចំណាយវិនិយោគសាធារណៈ។ល។

- **ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន**

នៅក្នុងអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភានេះ រចនាសម្ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានកែសម្រួលតាមរយៈអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៩៤ មាត្រា៩៥ មាត្រា៩៦ និងមាត្រា៩៧ នៃអនុក្រឹត្យលេខ ៤៨៨ អនប្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។ គោលបំណងចម្បងនៃការកែសម្រួលរចនាសម្ព័ន្ធឡើងវិញនេះ គឺដើម្បីបន្តធានាគុណភាព និងប្រសិទ្ធភាពនៃ លទ្ធផលបំពេញការងារក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទន្ទឹមនេះរាជរដ្ឋាភិបាល បានចេញអនុក្រឹត្យលេខ១១៥ .អនក្រ.បក ស្តីពីការតម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ហើយការិយាល័យវិភាគបំណុល នៃនាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលបំពេញមុខងារជាអង្គភាពគ្រប់គ្រងហានិភ័យ ( Risk Management Unit ) តាមប្រកាសលេខ៦៦៦ សហវ.ប្រក ចុះថ្ងៃទី ០៨ ខែមិថុនាឆ្នាំ២០១៦។

អនុលោមតាមអនុក្រឹត្យលេខ ១៩ អនក្រ.បក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ១៥០០ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា។ ប្រកាសនេះបានកំណត់ឲ្យការិយាល័យសម្របសម្រួលការអភិវឌ្ឍន៍ វិស័យឯកជន នៃនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា បំពេញមុខងារជាអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល (Central PPP Unit)។

ក្នុងបរិការណ៍បច្ចុប្បន្នរបស់កម្ពុជា និងស្របតាមការអនុវត្តជាសកល អង្គភាពទាំង០២ នេះត្រូវបំពេញមុខងារ និងភារកិច្ចកម្មិតដូចខាងក្រោមៈ

**អង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល**

- ✓ សម្របសម្រួល និងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ✓ ផ្តល់នូវការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបានសិទ្ធិប្រទាន ក្នុងការចុះកិច្ចសន្យាជាមួយដៃគូឯកជន ដើម្បីកំណត់, វាយតម្លៃ, រៀបចំរចនាសម្ព័ន្ធ, ធ្វើកិច្ចលទ្ធកម្ម, ចុះកិច្ចសន្យា និងគ្រប់គ្រងគម្រោង។
- ✓ ពិនិត្យ និងតាមដានគម្រោងវិនិយោគ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅតាមដំណាក់កាលសំខាន់នីមួយៗ។
- ✓ ផ្តល់អនុសាសន៍ដល់គណៈកម្មាធិការបច្ចេកទេស និងគណៈកម្មាធិការប្រតិបត្តិពាក់ព័ន្ធនឹងការអនុវត្តគម្រោង។
- ✓ គ្រប់គ្រងមូលនិធិសម្រាប់ការអភិវឌ្ឍគម្រោង (PDF) ដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើការងារបច្ចេកទេស ដែលត្រូវការសម្រាប់ការធ្វើប្រតិបត្តិការគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ✓ ស្នើរៀបចំគណៈកម្មាធិការកិច្ចលទ្ធកម្ម និងគ្រប់គ្រងកិច្ចលទ្ធកម្មប្រមូលចំណូល និងទូទាត់ទៅឲ្យក្រុមទីប្រឹក្សា (Transaction Advisors) តាមរយៈមូលនិធិសម្រាប់ការអភិវឌ្ឍន៍គម្រោង។
- ✓ និងភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

**អង្គភាព គ្រប់គ្រងហានិភ័យ**

- ✓ វិភាគ, វាយតម្លៃ, ត្រួតពិនិត្យ និងតាមដានហានិភ័យពាក់ព័ន្ធនៃគម្រោងវិនិយោគ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេស គឺហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលកើតចេញពីការធានារបស់រដ្ឋ។

- ✓ ផ្តល់អនុសាសន៍លើការបែងចែកហានិភ័យនៃគម្រោងវិនិយោគ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ✓ គណនា និងវិភាគតាមគោលការណ៍តម្លៃនៃលុយ (Value for Money) សម្រាប់គម្រោងដែលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ✓ និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត។

ដោយយល់ឃើញពីសារៈសំខាន់នៃមុខងារ និងភារកិច្ចរបស់អង្គភាពគន្លឹះ ទាំងពីរខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការជ្រើសរើសមន្ត្រីថ្មីមួយចំនួនមក បំពេញការងារនៅការិយាល័យពាក់ព័ន្ធទាំងពីរ ដែលជាតួអង្គសំខាន់ក្នុងការចូលរួមអភិវឌ្ឍគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅកម្ពុជា គឺៈ ១) ការិយាល័យសម្របសម្រួលអភិវឌ្ឍផ្នែកឯកជន នៃនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា និង ២) ការិយាល័យវិភាគបំណុល នៃនាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ក្នុងគោលដៅអភិវឌ្ឍការិយាល័យទាំងពីរនេះ ឲ្យមានសមត្ថភាពគ្រប់គ្រាន់ និងបំពេញភារកិច្ចរបស់ខ្លួនបានពេញលេញក្នុងកម្រិតប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ និងសកលលោក។

**២.២.១.៣ យន្តការគាំទ្រហិរញ្ញវត្ថុជម្រុញការអនុវត្តគម្រោង** PPP

តាមគោលនយោបាយកម្ពុជា ក៏ដូចជាប្រទេសភាគច្រើនការគាំទ្រជម្រុញការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺបង្កើតមូលនិធិពិសេសចំនួន ០២ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមមានៈ

១. មូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility-PDF) មានគោលដៅគាំទ្រក្រសួងស្ថាប័នជំនាញ ក្នុងការរៀបចំគម្រោង ចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពបឋមរហូតដល់ការប្រគល់កិច្ចសន្យាសម្បទាន។ មូលនិធិនេះសម្រាប់ធ្វើការចំណាយ ការធ្វើអត្តសញ្ញាណកម្មគម្រោង សិក្សាសមិទ្ធិលទ្ធភាពគម្រោង ចំណាយកិច្ចលទ្ធកម្ម និងជាពិសេសចំណាយដើម្បីជួលទីប្រឹក្សាប្រតិបត្តិការសម្រាប់ធ្វើ (F/S)។

២. មូលនិធិបំពេញផលហិរញ្ញវត្ថុ (Viability Gap Fund-VGF) មានគោលដៅជួយឧបត្ថម្ភធនដល់គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួន ឬគម្រោងក្នុងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬគម្រោងក្នុងវិស័យសង្គមកិច្ច ឲ្យមានភាពទាក់ទាញពីវិស័យឯកជន និង ស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដាក់ឲ្យអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ បច្ចុប្បន្នកម្ពុជា បានកំពុងតែអនុវត្តមូលនិធិ PDF ដើម្បីគាំទ្រ និងជម្រុញឲ្យគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈអនុវត្តតាមយន្តការ PPP និងលើកទឹកចិត្តឲ្យវិស័យឯកជន វិនិយោគគម្រោងហេដ្ឋារចនា

សម្ព័ន្ធសាធារណៈដែលអាចប្រមូលថ្លៃសេវា ពីអ្នកប្រើប្រាស់គម្រោងវិនិយោគដែលឯកជនបានបណ្ដាក់ទុន និងឈានដល់ការដាក់គម្រោងវិនិយោគតាមយន្តការ PPP ដែលរដ្ឋជាអ្នកទូទាត់ថ្លៃសេវាជាមួយវិស័យឯកជនជំនួសប្រជាពលរដ្ឋ ឬអ្នកប្រើប្រាស់សេវានៅពេលអ្នកប្រើប្រាស់មិនអាចបង់ថ្លៃ ដូចដែលបានបង្ហាញក្នុងជំពូកទី១ ចំណុច (១.៣.៤.៣) រួចហើយ។

### ២.២.១.៤ តាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការធានាឲ្យបាននូវប្រសិទ្ធិភាព, វឌ្ឍនភាព និងសង្គតិភាពនៃការអនុវត្តវិធានការគោលនយោបាយ PPP។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការសម្របសម្រួលលើការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគោលនយោបាយដូចខាងក្រោម៖

**ប្រព័ន្ធរបាយការណ៍៖** ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវផ្ដល់របាយការណ៍ប្រចាំត្រីមាស, ឆមាសនិងឆ្នាំ ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តវិធានការគោលនយោបាយពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនជូនគណៈកម្មការអន្តរក្រសួង តាមរយៈអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណៈកម្មការអន្តរក្រសួងដែលមានអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ ត្រូវបូកសរុបរបាយការណ៍ប្រចាំ ឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**យន្តការដោះស្រាយបញ្ហាប្រឈម៖** គណៈកម្មការអន្តរក្រសួង មានភារកិច្ច និងសម្រេចដាក់ចេញវិធានការចាំបាច់នានាដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាពត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ៖** អង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈមដែលបានដាក់ចេញ ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាព នៃការអនុវត្តនេះជូន គណៈកម្មការអន្តរក្រសួង។ នៅប្រទេសមួយចំនួនក្នុងការអនុវត្តយន្តការ PPP នេះគេបានបែងចែកការទទួលខុសត្រូវ និងការវាយតម្លៃទៅឲ្យស្ថាប័នដទៃ ពីស្ថាប័នទទួលអនុវត្តគោលនយោបាយ ដើម្បីឲ្យមានតម្លាភាព សុក្រឹតភាពកាន់តែខ្លាំង ប៉ុន្តែដោយសារប្រទេសកម្ពុជា សមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅមានកម្រិតទើបរាជរដ្ឋាភិ-បាលផ្ដល់ការទទួលខុសត្រូវ និងវាយតម្លៃគោលនយោបាយ PPP ទៅឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយ។

### ២.២.២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បច្ចុប្បន្នដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា CDC ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាលហើយ ដែលមានភារៈកិច្ចដូចតទៅ៖

- ជាសេនាធិកា និងជាច្រកចេញ-ចូលតែមួយ របស់រាជរដ្ឋាភិបាលក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើអោយគេយល់ជ្រួតជ្រាបអំពីយុត្តិសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអោយមានប្រសិទ្ធិភាពស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។

- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។

- តម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា។

- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ។

- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍គម្រោងវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។[11]

ទាក់ទង ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

- បំពេញតួនាទីជាយន្តការ **"ច្រកចេញ-ចូលតែមួយ"** និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

- ធ្វើការវិភាគ ការប្រណាំងប្រជែងដណ្តើមឈ្មុះ លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិភាគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជាសាជីវកម្មកម្ពុជា។ សហការជាមួយនឹងក្រសួងស្ថប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោង

[11] មាត្រ១០ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៣

នានាសម្រាប់ការវិនិយោគឯកជន។

- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកវិនិយោគតាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( ក.អ.ក )។

- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទងនឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន។

- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិននឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។

- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។[12] ភារកិច្ចដែលបានពិពណ៌នាខាងលើនេះ គឺជាភារកិច្ចដែលក្រុមប្រឹក្សាអភិវឌ្ឍន៍ចូលរួមក្នុងកិច្ចវិនិយោគឯកជន ក៏ដូចជាកិច្ចវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលច្បាប់ដែលទាក់ទងនិង PPP របស់កម្ពុជាបានចង្អុលបង្ហាញ។

ក្រៅពីភារកិច្ចដែលមានចែង ក្នុងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៣ ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៣ និងច្បាប់សម្បទានឆ្នាំ២០០៧ ក៏បានចែងអំពីភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ទាក់ទងការ វិនិយោគរបស់ឯកជន និងភារកិច្ចដែលទាក់ទងនឹងសម្បទានផងដែរ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសម្រេចការងារនីតិសម្បទានិងអភិវឌ្ឍន៍ និងវិនិយោគនានា។[13] ចំណែកច្បាប់សម្បទានក៏បានចែងពិពណ៌នា ពីភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ ទាក់ទងនឹងការសម្របសម្រួល និងសេវាកម្មផ្នែករដ្ឋបាល ដែលភារកិច្ចនោះមានៈ

---

[12] មាត្រា១៧ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៣

[13] មត្រា៣ ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៣

ក្រុមប្រឹក្សាអភិវឌ្ឍន៍ គឺជាស្ថាប័នច្រកចេញ-ចូលតែមួយ សម្រាប់ទទួលការអនុញ្ញាតដែលជាតម្រូវការចាំបាច់ក្នុងការអនុវត្តគម្រោងវិនិយោគស្របតាមច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបានទទួលការស្នើសុំអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមកិច្ចសន្យាសម្បទានពីសម្បទានិក ដែលជ្រើសរើសឲ្យអនុវត្តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវៈ

- ផ្តល់ជូននូវការលើកទឹកចិត្តដល់សម្បទានិក ដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

- ធ្វើការបញ្ជាក់អំពីការអនុញ្ញាតទាំងឡាយ ដែលត្រូវទទួលបានសម្រាប់គម្រោងសម្បទានពីស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាត។

- ទទួលយកឲ្យទាន់ពេលវេលានូវរាល់លិខិតអនុញ្ញាត ពីស្ថាប័នពាក់ព័ន្ធជំនួសមុខឲ្យសម្បទានិកនៅពេលដែលពត៌មាននិងឯកសារចាំបាច់ទាំងឡាយត្រូវបានផ្តល់គ្រប់ចំនួនពីសម្បទានិក។[14]

បន្ថែមពីភារកិច្ចខាងលើនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍ក៏មានភារកិច្ចមួយចំនួនទៀត ក្នុងការគាំទ្រ និងធ្វើឲ្យសម្បទានមានភាពកាន់តែល្អប្រសើរភារកិច្ចនោះគឺៈ ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយសម្បទាន និងផ្តល់អនុសាសន៍ ដើម្បីកែលំអឲ្យកាន់តែប្រសើរនូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយសម្រាប់អនុវត្តគម្រោងសម្បទាន។ ក្រុមប្រឹក្សាអភិវឌ្ឍន៍ជួយដល់ក្រសួងស្ថាប័នមានសមត្ថកិច្ច ក្នុងការធ្វើអត្តសញ្ញាណកម្ម និងវាយតម្លៃលើកាលានុវត្តភាពនានាសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលឯកជនធ្វើហិរញ្ញប្បទាន ព្រមទាំងជួយផ្សព្វផ្សាយដល់សហគមន៍អ្នកវិនិយោគទាំងឡាយណាដែលអាចដំណើរការបាន។ លើសពីនេះក្រុមប្រឹក្សាអភិវឌ្ឍន៍មានភារកិច្ចជួយវាយតម្លៃពីខាងក្រៅដើម្បីជួយស្ថាប័នជាប់កិច្ចសន្យា ឬស្ថាប័នដែលផ្តល់សម្បទានក្នុងការរៀបចំការដេញថ្លៃ និងការត្រួតពិនិត្យគម្រោងសម្បទានដែលមានភាពស្មុគស្មាញ និងលើកការស្នើអំពីនីតិវិធីធ្វើការជ្រើសរើសគំរូ និងគំរូឯកសារសម្រាប់គម្រោងដើម្បីធ្វើសនិទានកម្មលើការធ្វើហិរញ្ញប្បទានការអនុវត្ត និងការត្រួតពិនិត្យគម្រោងសម្បទានផងដែរ បន្ថែមពីនេះ "CDC" ក៏ជាអ្នកសម្របសម្រួលក្នុងការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលមន្ត្រីរាជការដែលធ្វើការងារពាក់ព័ន្ធនិងការងារសម្បទានផងដែរ។

### ២.២.៣ ក្រសួង ស្ថាប័នទទួលបន្ទុកចុះកិច្ចសន្យាសម្បទាន ឬកិច្ចសន្យា PPP

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាមានច្រើន ប៉ុន្តែមានតែក្រសួងស្ថាប័នតាមវិស័យមួយចំនួនទេដែលមានសិទ្ធិចុះកិច្ចសន្យាសម្បទាន ឬកិច្ចសន្យា PPP បាន។ ក្រសួង ស្ថាប័នតាម វិស័យដែលមានសិទ្ធិធ្វើសម្បទាននិងទទួលបន្ទុកចុះកិច្ចសន្យាសម្បទានឬ PPP គឺជាក្រសួងស្ថាប័នមានសមត្ថកិច្ច

[14] មាត្រា៨ ច្បាប់ស្តីពីសម្បទាន ឆ្នាំ២០០៧

ឬ អាជ្ញាធរណាមួយដែលច្បាប់សម្បទាន និងឯកសារគោលនយោបាយអភិវឌ្ឍន៍ យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ បានផ្តល់សមត្ថកិច្ចឲ្យ ឬជាក្រសួងស្ថាប័នពិសេសដែលរាជរដ្ឋាភិបាលផ្តល់សមត្ថកិច្ចជូនអនុលោមតាមច្បាប់កំណត់។

ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលមានភារកិច្ចទទួលធ្វើគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់សម្បទានរួមមាន ក្រសួងស្ថាប័នសាធារណៈ នីតិបុគ្គលរបស់រដ្ឋ អាជ្ញាធរមូលដ្ឋាន ដែលបានទទួលប្រតិភូកម្មនូវអំណាចដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចុះកិច្ចសន្យាសម្បទានលើគម្រោង ហេដ្ឋារចនាសម្ព័ន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន និងមានសិទ្ធិចុះកិច្ចព្រមព្រៀងពាក់ព័ន្ធបន្ទាប់បន្សំ រួមទាំងកិច្ចព្រមព្រៀងដែលមានគោលបំណងសម្រួលការងារហិរញ្ញប្បទានដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃច្បាប់សម្បទាន និងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងអនុក្រឹត្យ។[15] កិច្ចសន្យាសម្បទានដែលមានទំនាក់ទំនងទៅនឹងសំណង់ ហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវាដោយផ្ទាល់ ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈត្រូវបានចូលរួមដោយស្ថាប័នពាក់ព័ន្ធលើវិស័យដូចតទៅៈ ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី, ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពុងផែ ផ្លូវដែក ព្រែកជីក, ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ, ហេដ្ឋារចនាសម្ព័ន្ធបម្រើឲ្យទូរគមនាគមន៍ និង បច្ចេកវិទ្យាពត៌មាន, ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈបម្រើឲ្យគម្រោងផ្នែកទេសចរណ៍មានជា អាទិ៍ រមណីដ្ឋានទេសចរណ៍ សារមន្ទីរ ,ហេដ្ឋារចនាសម្ព័ន្ធបម្រើឲ្យវិស័យឧស្ម័ននិងប្រេង មានជា អាទិ៍ បំពង់បង្ហូរប្រេង និងឧស្ម័ន, ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ, ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងសំណង់, ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និង វិស័យកីឡា, ហេដ្ឋារចនាសម្ព័ន្ធ បម្រើឲ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅដ្ឋានសង្គម, ហេដ្ឋារចនាសម្ព័ន្ធបម្រើឲ្យប្រព័ន្ធធារាសស្រ្ត និងការងារកសិកម្ម និងវិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឲ្យមានការផ្តល់នូវសម្បទាន។[16] ងាកមកមើលឯកសារគោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនវិញម្តងវិស័យអាទិភាពដែលកំណត់ក្នុងគោលនយោបាយដែលចង្អុលបង្ហាញពីស្ថាប័នមានសមត្ថកិច្ចក៏មិនខុសគ្នាពី វិស័យហេដ្ឋារចនាសម្ព័ន្ធដែលមានចែងក្នុងមាត្រា៥ នៃច្បាប់សម្បទានដែរ ដែលវិស័យទាំងនោះមានដូចជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដូចជាៈ ផ្លូវថ្នាល់ ស្ពាន ផ្លូវដែក ផែ និងអាកាសយានដ្ឋាន, ការផលិត ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី, ការផលិត, ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត, ការអភិវឌ្ឍន៍ ការធ្វើ

[15] មាត្រា៤ ច្បាប់សម្បទានឆ្នាំ ២០០៧

[16] មាត្រា៥ ច្បាប់ស្តីពីសម្បទានឆ្នាំ២០០៧

ទំនើបភាវូបនីយកម្មផ្សារ និងចំណតរថយន្តសាធារណៈ ឬមជ្ឈមណ្ឌលពាណិជ្ជកម្មសាធារណៈ, ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈតំបន់ឧស្សាហកម្ម, សេវាគ្រប់គ្រង និងសម្អាតកាកសំណល់, ប្រព័ន្ធចម្រោះ និងប្រព័ន្ធបង្ហូរទឹកស្អុយ, ការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ, ហេដ្ឋានរចនាសម្ព័ន្ធលំនៅដ្ឋានសង្គមកិច្ច, ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ដូចជារមណីដ្ឋានទេសចរណ៍, សារមន្ទី ជាដើម, ហេដ្ឋារចនាសម្ព័ន្ធវិស័យឧស្ម័ន និងប្រេងកាតដូចជាប្រព័ន្ធបណ្ដាញចែកចាយប្រេង និងឧស្ម័ន, វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន, ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធសេវាសុខភាពសាធារណៈ, ហេដ្ឋារចនាសម្ព័ន្ធអប់រំ និងកីឡា និងព្រមទាំងវិស័យអាទិភាពដទៃទៀត។

ក្រសួងស្ថាប័នមានសមត្ថកិច្ចតាមវិស័យដូចបានបង្ហាញខាងលើ ជ្រើសរើសគម្រោងអាទិភាពស្របតាមវិស័យដែលខ្លួនគ្រប់គ្រងដាក់សំណើគម្រោងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យនិងវាយតម្លៃ។ នៅពេលគណៈកម្មការដឹកនាំការងារ PPP របស់ក្រសួងសេដ្ឋកិច្ចបានពិនិត្យ និងសម្រេចឲ្យគម្រោងបន្តនីតិវិធីទៅសិក្សាសមិទ្ធិលទ្ធភាព F/S ដំណាក់កាលនេះក្រសួងសាមីនឹងសិក្សាសមិទ្ធិលទ្ធភាពគម្រោង (ពិនិត្យទាំងផលវិជ្ជមាន និងទាំងផលអវិជ្ជមាន) នៃគម្រោង។ ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោងនេះក្រសួងស្ថាប័នសាមីអាចជួលទីប្រឹក្សា (Transaction Advisors) មកផ្ដល់យោបល់ទីប្រឹក្សាដែលជួលមកអាចជាទីប្រឹក្សាច្បាប់, អាចទីប្រឹក្សាបច្ចេកទេស ឬអាចទីប្រឹក្សាហិរញ្ញវត្ថុ។ បន្ទាប់ពីបញ្ចប់ដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោងក្រសួងស្ថាប័នម្ចាស់សំណើបន្តនីតិវិធីដឹកនាំកិច្ចលទ្ធកម្ម ជ្រើសរើសដៃគូឯកជន ឬសម្បទានិកដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នូវពេលទទួលបាន សម្បទានិក ក្រសួង ស្ថាប័នម្ចាស់សំណើបន្តនីតិវិធីចុះកិច្ចសន្យាជាមួយដៃគូឯកជន ឬសម្បទានិក។ ក្រសួង ស្ថាប័នទទួលបន្ទុកចុះកិច្ចន្យា ក្លាយជាស្ថាប័នជាប់កិច្ចសន្យាហើយដើរតួជាចម្បងក្នុងកិច្ចគ្រប់គ្រងសម្បទាន ដែលបានផ្ដល់ឲ្យ សម្បទានិកក្នុងការត្រួតពិនិត្យសម្បទាន ពីការអនុវត្តកិច្ចសន្យារបស់សម្បទានិករហូតដល់បញ្ចប់កិច្ចសន្យាសម្បទាន ឬកិច្ចសន្យា PPP។

**២.២.៤ ទីប្រឹក្សាប្រតិបត្តិការ** (Transaction Advisors)

នៅប្រទេសមួយចំនួន ក៏ដូចជាប្រទេសកម្ពុជា ដើម្បីឲ្យមានថវិកាគ្រប់គ្រាន់សម្រាប់រៀបចំគម្រោងតាមយន្ត PPP គឺរដ្ឋាភិបាលបង្កើត "**មូលនិធិអភិវឌ្ឍន៍គម្រោង**"។ មូលនិធិនេះ រដ្ឋាភិបាលអាចជ្រើសរើសទីប្រឹក្សាដើម្បីទទួលបានមុខជំនាញ ដែលមិនមានក្នុងអង្គភាពទទួលអនុវត្ត យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ឬស្ថាប័នពាក់ព័ន្ធ។ ទីប្រឹក្សាដែលត្រូវជ្រើសរើសមក គឺអាចជាទីប្រឹក្សាច្បាប់ជួលមកដើម្បីរៀបចំសេចក្ដីព្រាងកិច្ចសន្យា PPP ទីប្រឹក្សាខាងបច្ចេកទេស ជួលមកដើម្បីរៀបចំគម្រោងយថាប្រភេទ ឬជាទីប្រឹក្សាខាងហិរញ្ញវត្ថុ ជួលមកដើម្បីវាយតម្លៃទៅលើសំណើហិរញ្ញវត្ថុពីអ្នកដេញ

ថ្លៃ។[17] ចំពោះការទូទាត់ថ្លៃសេវាទីប្រឹក្សាបណ្ដាប្រទេសមួយចំនួនមានប្រភពផ្សេងៗគ្នាតែសម្រាប់កម្ពុជាការទូទាត់ថ្លៃសេវាទីប្រឹក្សាគឺ យកចេញពីក្នុងមូលនិធិសម្រាប់អភិវឌ្ឍន៍គម្រោងនៃយន្តការគាំទ្រហិរញ្ញវត្ថុ PDF។ ទីប្រឹក្សាប្រតិបត្តិធ្វើរាល់កិច្ចការហិរញ្ញវត្ថុ និងបច្ចេកទេសលម្អិតដែលជាតម្រូវការរបស់ម្ចាស់គម្រោង ដើម្បីរៀបចំអនុវត្តគម្រោងដែលបានស្នើសុំឲ្យទទួលបានជោគជ័យ។ ទីប្រឹក្សាផ្នែកប្រតិបត្តិការនឹងបំពេញការសិក្សាដែលអាចធ្វើទៅបានដែល នឹងផ្ដល់លទ្ធភាពដល់ស្ថាប័នដើម្បីបង្កើតភាពទាក់ទាញផ្នែកពាណិជ្ជកម្ម និងលទ្ធភាពទទួលបានហិរញ្ញប្បទានពីធនាគាររបស់គម្រោងដែលបង្កើតឡើង។ ក្នុងដំណាក់កាលនៃការផ្គត់ផ្គង់ទីប្រឹក្សាប្រតិបត្តិ ទីប្រឹក្សានឹងផ្ដល់ការណែនាំដល់ម្ចាស់គម្រោងអំពីការបែងចែកហានិភ័យ និងរចនាសម្ព័ន្ធកិច្ចសន្យាដែលមានលទ្ធផលល្អរួមទាំង ការរៀបចំឯកសារចាំបាច់ទាំងអស់និងការអនុញ្ញាតចាំបាច់ផ្សេងៗ។ ភាគច្រើនក្នុងការអនុវត្តជា សកលទីប្រឹក្សាប្រតិបត្តិត្រូវបានជួលនៅពេលចាប់ផ្ដើមដំណើរការគម្រោង PPP ហើយអាចរក្សាទុករហូតដល់បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀង PPP ឬនៅចុងបញ្ចប់នៃដំណាក់កាលលទ្ធកម្ម។ ទីប្រឹក្សាប្រតិបត្តការក៏អាចជះឥទ្ធិពលអវិជ្ជមានផងដែរដល់គម្រោង និងរដ្ឋាភិបាលក្នុងគម្រោង PPP ដើម្បីភាពស្អាតស្អំ និងធានាបរិយាកាសល្អដល់គម្រោងសម្រាប់ការជួលសេវាកម្ម ទីប្រឹក្សាប្រតិបត្តិការត្រូវតែមានភាពត្រឹមត្រូវ, ស្មើភាព, តម្លាភាព, ប្រកួតប្រជែង និងមានប្រសិទ្ធភាពចំណាយ។[18]

### ២.២.៥ ទីប្រឹក្សាឯករាជ្យ (Independent Consultant)

ទីប្រឹក្សាឯករាជ្យ គឺជាបុគ្គលឯករាជ្យមិនលំអៀងដែលជួលមកក្នុងដំណាក់កាលគ្រប់គ្រងកិច្ចសន្យាសម្បទាន ឬកិច្ចសន្យា PPP ដើម្បីត្រួតពិនិត្យទៅលើការសាងសង់ ថាតើអនុឡោមតាមកិច្ចសន្យាដែលឬទេ។ ទីប្រឹក្សាឯករាជ្យមានតួនាទីត្រួតពិនិត្យការអនុវត្តកិច្ចសន្យារបស់គូភាគី មិនឲ្យភាគីណាមួយរំលោភលើភាគីមួយទៀតបានទេ។ ឧទាហរណ៍៖ ប្រសិនខាងវិស័យឯកជនអនុវត្តការសាងសង់មិនដូចមានចែងក្នុកិច្ចសន្យា គាត់មានសិទ្ធិផ្ដល់ពត៌មានទៅខាងភាគីរដ្ឋឲ្យបានដឹង ដូចគ្នានេះដែរប្រសិនភាគីរដ្ឋបំពេញកិច្ចខុសពីមានចែងក្នុងកិច្ចសន្យា គាត់មានសិទ្ធិផ្ដល់ពត៌មានទៅខាងឯកជន។ និយាយជារួមទីប្រឹក្សាឯករាជ្យគាត់បំពេញការងារអព្យាក្រឹត្យ មិនលំអៀងទៅខាងភាគីណាមួយទេ និយាយឲ្យចំគាត់មាន តួនាទីត្រួតពិនិត្យការអនុវត្តរបស់គូភាគីអោយដូច "ខ" ដែលបានចែងក្នុងកិច្ចសន្យាដែលគូភាគីព្រមព្រៀងគ្នា និងធានាការអនុវត្តគម្រោងប្រកបដោយភាពត្រឹមត្រូវ។ បញ្ជាក់ផងដែរចំពោះសេវាទីប្រឹក្សា គឺភាគីទាំងសងខាងចេញស្មើគ្នា។

## ២.៣ នីតិវិធី និងដំណាក់កាលនៃគម្រោងវិនិយោគ PPP

[17] ម៉ូឌុល៣.ការបង្កើតបរិយាកាសសម្រួលដំណើរការ PPP របស់UNESCAP

[18] www.pppinindia.gov.in/toolkit

គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន អាចកើតឡើងតាមមធ្យោបាយ ០២ គឺទីមួយ វិស័យឯកជនជាអ្នកស្នើគម្រោង ការស្នើធ្វើឡើងតាម រយៈក្រសួងស្ថាប័នតាមវិស័យ ដើម្បីដាក់សំណើគម្រោងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមួយទៀត គម្រោងផ្តើមឡើងដោយក្រសួង ស្ថាប័នរដ្ឋស្នើដោយខ្លួនឯងផ្ទាល់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងវាយតម្លៃ។

ករណីវិស័យឯកជនជាអ្នកស្នើគម្រោង ការស្នើធ្វើឡើងតាមរយៈក្រសួងស្ថាប័នតាមវិស័យ ដើម្បីដាក់សំណើគម្រោងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គម្រោងប្រភេទនេះកើតឡើងនៅពេលដែលវិស័យឯកជនបានមើលឃើញ ពីសក្តានុពលនៃគម្រោងមួយក្នុងចំណោមគម្រោងវិនិយោគសាធារណៈជាច្រើន ហើយពួកអ្នកវិនិយោគទុនអាចទទួលបានប្រាក់ចំណេញពីការវិនិយោគរបស់ខ្លួន។ គម្រោងប្រភេទនេះ វិស័យឯកជនត្រូវដាក់ស្នើគម្រោងមកក្រសួង ស្ថាប័នតាមវិស័យដែលខ្លួនចង់វិនិយោគ រួចហើយក្រសួង ស្ថាប័នតាម វិស័យដាក់សំណើគម្រោងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យសម្រេច។ បន្ទាប់ពីក្រសួងសេដ្ឋកិច្ច យល់ព្រមហើយ ក្រសួង ស្ថាប័នតាម វិស័យចាប់ផ្តើមធ្វើលទ្ធកម្ម ឬចរចា តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងដំណើការដាក់ឲ្យធ្វើកិច្ចលទ្ធកម្ម មិនមែនធ្វើឡើងតែក្រុមហ៊ុនដែលស្នើគម្រោងម្នាក់ឯងនោះទេ គឺរដ្ឋត្រូវផ្សព្វផ្សាយជាសាធារណៈ និងអញ្ជើញភាគី ឬក្រុមហ៊ុនផ្សេងទៀតដើម្បីដាក់សំណើប្រកួតប្រជែង។ ទោះជាយ៉ាងនេះក៏ដោយអ្នកដាក់សំណើដំបូងនូវតែផ្តល់ឱកាស ដើម្បីធ្វើការប្រៀបធៀបសំណើរបស់គាត់ជាមួយសំណើរបស់អ្នកប្រកួតប្រជែងដទៃផងដែរ។ ប៉ុន្តែក្នុងយន្តការ PPPដែលផ្តួចផ្តើមឡើងដោយដៃគូអភិវឌ្ឍន៍ពហុភាគី ក៏ដូចជាឯកសារគោលនយោបាយ PPP របស់កម្ពុជាផ្តោតតែទៅលើគម្រោង PPP ដែលផ្តួចផ្តើមដោយវិស័យសាធារណៈតែប៉ុណ្ណោះតែក៏មាននីតិវិធីនៃផ្នែកខ្លះនឹងយកមកអនុវត្តក្នុងគម្រោងដែលស្នើដោយវិស័យឯកជនផងដែរ។

ករណីគម្រោងផ្តើមឡើងដោយក្រសួង ស្ថាប័នរដ្ឋ។ គោលនយោបាយ PPP កម្ពុជាបង្កើតមកគឺជម្រុញ និងតម្រូវឲ្យក្រសួង ស្ថាប័នរដ្ឋជាអ្នកផ្តួចផ្តើមគំនិតស្នើគម្រោង PPP ផ្ទាល់មកក្រសួងសេដ្ឋកិច្ច ប៉ុន្តែរដ្ឋក៏មិនបដិសេធគម្រោង PPP ដែលស្នើឡើងដោយវិស័យឯកជននោះដែរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលជម្រុញ និងលើកទឹកចិត្តឲ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើរតួនាទីជាយុទ្ធសាស្ត្រវិទូ, អ្នកសម្របសម្រួល, គាំទ្រ និងជាអ្នកផ្តួចផ្តើម ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព,តម្លាភាពនិង គណនេយ្យភាពក្នុងការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈការកំណត់យន្តការស្ថាប័ន ដោយត្រូវមានការបែងចែកមុខងារច្បាស់លាស់។ ទន្ទឹមនេះ ក្រសួង ស្ថាប័នសាមីត្រូវរៀបចំបញ្ជីគម្រោងវិនិយោគសាធារណៈរួមតាមវិស័យ ដោយត្រូវរួមបញ្ចូលនូវគម្រោងវិនិយោគផ្ទាល់ដោយរដ្ឋ, គម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និង

ឯកជន។ ក្នុងគម្រោងផ្តួចផ្តើមដោយវិស័យសាធារណៈ ក្រសួងស្ថាប័នរដ្ឋ ជាអ្នកដំណើការធ្វើអត្តសញ្ញាណកម្មគម្រោង, សិក្សា, រៀបចំនិងវាយតម្លៃគម្រោងព្រមទាំងជ្រើសរើសក្រុមហ៊ុនសម្បទានិកតាមរយៈការដេញថ្លៃដោយតម្លាភាពនិងយុត្តិធម៌។

បច្ចុប្បន្ន វិស័យវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែល ផ្តួចផ្តើមឡើងដោយក្រសួងស្ថាប័នរដ្ឋ លេចធ្លោជាងគេ គឺស្នើឡើងដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលដែលមានជាអាទិ៍ះគម្រោងផ្លូវរថភ្លើងល្បឿនលឿនភ្នំពេញ-បាវិត, គម្រោងផ្លូវរថភ្លើងល្បឿនលឿនភ្នំពេញ-សៀមរាប, ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ, ព្រលានយន្ត ហោះថ្មីខេត្តសៀមរាប និងគម្រោងព្រលានយន្តហោះថ្មីនៅខេត្តកណ្តាលក្នុងស្រុកកណ្តាលស្ទឹង។ មុនកម្ពុជាមានគោលនយោបាយ PPP ក្នុងឆ្នាំ២០១៦ កម្ពុជាធ្លាប់អនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលដាក់សំណើដោយវិស័យឯកជនផងដែរ គម្រោងទាំងនោះភាគច្រើនជាគម្រោងវិនិយោគក្នុងវិស័យអគ្គិសនី និងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវថ្នល់, ស្ពាននិងព្រលានយន្តហោះ ដែលប្រើប្រាស់ទម្រង់ **"សាងសង់-អាជីវកម្ម-ផ្ទេរ"**, **"សាងសង់-ធ្វើម្ចាស់-អាជីវកម្ម"** និង **"ថែទាំ-ប្រតិបត្តិ-ផ្ទេរ"**។ ផ្អែកលើសំណើរបស់វិស័យឯកជន ក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យលើសំណើគម្រោង ដោយបានសិក្សាវិភាគនិងវាយតម្លៃលើះ អត្ថប្រយោជន៍, តម្លៃគម្រោង, អត្រាតម្លៃត្រូវបង់ពីអ្នកប្រើប្រាស់និងអត្រាចំណូលផ្ទៃក្នុង, ផលប៉ះពាល់ និងហានិភ័យពាក់ព័ន្ធ ព្រមទាំងលក្ខខ័ណ្ឌផ្សេងទៀតនៃគម្រោងមុននឹងឈានដល់ការចរចា និងចុះកិច្ចសន្យាសម្បទាន។ ទម្រង់ដែលក្រសួង ស្ថាប័នរដ្ឋអនុវត្តខាងលើនេះក្រសួងស្ថាប័ននៅប្រើប្រាស់យន្តការចំពោះកិច្ច សម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនដែលមិនស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដែលបាននិងកំពុងអនុវត្តដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់នៅក្នុងបណ្តាប្រទេសជាច្រើន ក្នុងពិភពលោកពោលអនុវត្តអនុលោមតាមច្បាប់សម្បទាន។ មកដល់ពេលនេះកម្ពុជាមានគោលនយោបាយ PPP ប៉ុន្តែកម្ពុជាមិនទាន់អាចអនុវត្តពេញលេញនូវឡើយដោយនៅខ្វះធនធានមនុស្ស ហើយឯកសារច្បាប់ និងនីតិវិធីគ្រប់គ្រងគម្រោង PPP ស្ថិតក្នុងដំណាក់កាលសិក្សាព្រាងនូវឡើយ ពោលគឺកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាល កំពុងអនុវត្តអភិក្រម **"រៀនផង-ធ្វើផង"** ដោយមានការផ្តល់ជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ដៃគូអភិវឌ្ឍន៍ពហុភាគីនិងការធ្វើដំណើរទស្សនៈកិច្ចសិក្សាស្វែងយល់ពីបណ្តាប្រទេសជាមិត្ត ដែលអនុវត្តគម្រោង PPP ទទួលបានជោគជ័យដូចជាប្រទេសចិន និងឥណ្ឌា បូកផ្សំជាមួយកិច្ចនីតិវិធីដែលកម្ពុជាមានស្រាប់។ អង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងស្ថាប័នតាមវិស័យដែលស្នើគម្រោង PPP ដើម្បីគ្រប់គ្រងវដ្តគម្រោងPPPឲ្យទទួលបានជោគជ័យ។

បញ្ជាក់ផងដែរ កម្ពុជានឹងមានច្បាប់ និងនីតិវិធីដើម្បីគ្រប់គ្រងវដ្តគម្រោងតាមយន្តការ PPP ពេញលេញនៅឆ្នាំ២០២០។[19]

តាមការអនុវត្តជាអន្តរជាតិគម្រោង PPP មានវដ្តគម្រោងដូចជាៈ ដំណាក់កាលជ្រើសរើសគម្រោង(ការធ្វើអត្តសញ្ញាណកម្មគម្រោង), ដំណាក់កាលសិក្សាសមិទ្ធលទ្ធភាពគម្រោង, ដំណាក់កាលលទ្ធកម្មនិងចុះកិច្ចសន្យា, ដំណាក់កាលអនុវត្តកិច្ចសន្យា ហើយយើងនឹងបន្ថែមដំណាក់កាលមួយទៀតគឺដំណាក់កាលបញ្ចប់កិច្ចន្យាអោយស្របនឹងខ្លឹមសារច្បាប់កម្ពុជា ដែលដំណាក់កាលនីមួយៗយើងនឹងបង្ហាញចំណុចខាងក្រោមនេះ។

### ២.៣.១ ដំណាក់កាលជ្រើសរើសគម្រោង

ការធ្វើអត្តសញ្ញាណកម្មគម្រោង គឺជាការកំណត់គម្រោងហេដ្ឋារចនាសម្ព័ន្ធជាទូទៅជាលទ្ធផលនៃដំណើការរៀបចំផែនការ របស់រដ្ឋាភិបាលនៅពេលណាគម្រោង ត្រូវបានធ្វើអាទិភាពវូបនីយកម្មត្រូវតែកំណត់ ថាតើគម្រោងនោះ គួរតែអនុវត្តតាមយន្តការ PPP ឬ អនុវត្តតាមដំណើការលទ្ធកម្មបែបប្រពៃណី។ ដើម្បីធ្វើការកំណត់នេះ រដ្ឋាភិបាលបានពិចារណាពីវិធីសាស្ត្រលទ្ធកម្ម ដែលអាចនាំអតិសេដ្ឋភាពខ្ពស់បំផុត។ ដើម្បីធ្វើការសម្រេចចិត្តនេះ រដ្ឋត្រូវតែមានគោលការណ៍ជាក់លាក់ ដើម្បីសិក្សាវាយតម្លៃនៃភាពសមស្រប សម្រាប់អនុវត្តគម្រោងតាមយន្តការ PPP។ គោលការណ៍វិនិច្ឆ័យទាំងនេះរួមទាំងទំហំគម្រោង តើគម្រោងធំល្មមគ្រប់គ្រាន់ទេ? គម្រោង PPP គឺមានតម្លៃថ្លៃក្នុងការរៀបចំ ដោយសារភាពស្មុគស្មាញរបស់គម្រោង និងគម្រោងត្រូវតែធំល្មមដើម្បីឲ្យអាចទូទាត់នឹងកំណើនចំណាយប្រតិបត្តិការ។ កត្តាមួយទៀត គឺទាក់ទងនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធ។ PPP ធ្វើបានល្អបង្អស់ គឺនៅពេលដែលមានការសិក្សាប៉ាន់ស្មានតម្រូវការយូរអង្វែងនៃការប្រើប្រាស់ ហេដ្ឋារចនាសម្ព័ន្ធ។ រដ្ឋាភិបាលមិនចង់ចុះកិច្ចសន្យារយៈពេល២០ ឆ្នាំ គ្រាន់តែមិនបានប៉ុន្មានឆ្នាំក្រោយមកដឹងថាប្រជាជនលេងត្រូវការហេដ្ឋារចនាសម្ព័ន្ធនោះទៀត។ រដ្ឋក៏ត្រូវតែពិនិត្យមើលអំពីការអនុវត្តការងាររបស់វិស័យឯកជន មានន័យថាគម្រោងគួរតែមានបញ្ជាក់យ៉ាងច្បាស់លាស់អំពីលទ្ធផលដែលរដ្ឋត្រូវការពីវិស័យឯកជន។ ជាការងារសំខាន់បន្ថែមទៀត ដើម្បីសម្រេចចិត្ត ថាតើក្រុមហ៊ុនឯកជនមានសមត្ថភាពគ្រប់គ្រាន់អាចគ្រប់គ្រងគម្រោងដែលមានរយៈពេលយូរបែបនេះទេ។ ប្រសិនបើសមត្ថភាពក្រុមហ៊ុនក្នុងស្រុកនូវមានកម្រិត តើមានការចាប់អារម្មណ៍ពីអ្នកបណ្តាក់ទុនបរទេសដែរទេ?

មានកត្តាវិនិច្ឆ័យមួយចំនួនដែលរដ្ឋាភិបាល ឬ អ្នកពាក់ព័ន្ធគួរតែពិចារណា នៅពេលចាប់ផ្តើមធ្វើការសិក្សា "តម្លៃជាសាច់ប្រាក់" ជាការសិក្សាវាយតំលៃបែបគុណភាព។ សំណួរដែលកំពុងតែព្យាយាមបំភ្លឺ ថាតើគម្រោងនេះនឹងអាចបង្កើតឱ្យមានតំលៃបន្ថែម បើសិនណាយើងអភិវឌ្ឍតាមយន្តការ PPP ជា

[19] សម្រង់សម្តីលោក ឌឹម ម៉ាក់ជារិទ្ធ អនុប្រធានអង្គភាព PPP ថ្នាក់កណ្តាលពន្យល់ពីគោលនយោបាយ PPP

ជាងតាមការអនុវត្តលទ្ធកម្មតាមគម្រោងទូទៅ? សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធណាក៏ដោយគេត្រូវតែធ្វើការវិភាគ បុរេសមិទ្ធិលទ្ធភាព ក្នុងដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង។ ការសិក្សាវិភាគបែបនេះជាការប្រមូលព័ត៌មានមូលដ្ឋានទាក់ទងនឹងទំហំ និងគោលបំណងរបស់គម្រោង។ អ្នកសិក្សាគួរតែវាយតម្លៃលើកម្រិតបច្ចេកទេសច្បាប់ និងភាពចំណេញហិរញ្ញវត្ថុរបស់គម្រោង និងពិចារណាលើតម្រូវការសម្រាប់ការគាំទ្រហិរញ្ញវត្ថុសាធារណៈ។ ដោយផ្អែកលើការពិចារណានេះរដ្ឋអាចសម្រេចចិត្តថា តើគម្រោងដែលមានសក្តានុពល ដើម្បីអភិវឌ្ឍតាមយន្តការ PPP។ ក្នុងចំណុចនេះផងដែរការយល់ព្រមពីផ្ទៃក្នុង ឬ ថ្នាក់ដឹកនាំកំពូលៗដើម្បីបន្តការងារឈានទៅដំណាក់កាល ការរៀបចំគម្រោងក៏ជារឿងសំខាន់ផងដែរ។

តាមគោលនយោបាយ PPP របស់កម្ពុជាការវាយតម្លៃគម្រោងPPPតាមគោលការណ៍ណែនាំការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើស គឺបែងចែកជា០២ ដំណាក់កាល៖ **ដំណាក់កាលទី១៖** គឺជាដំណាក់កាល "ជាប់/ធ្លាក់" ដែលមានលក្ខខណ្ឌវិនិច្ឆ័យចំនួន ០៧។ និង **ដំណាក់កាលទី២៖** គឺជាដំណាក់កាលដាក់ពិន្ទុ និងចំណាត់ថ្នាក់គម្រោងទៅតាមលក្ខខណ្ឌវិនិច្ឆ័យចំនួន០៦។

❖ **ដំណាក់កាលទី១៖** "ជាប់/ធ្លាក់"

១. គម្រោងស្របតាមអាទិភាពជាយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

២. គម្រោងមានទំហំទុនវិនិយោគអប្បបរមា ១០ លានដុល្លាអាមេរិក

៣. គម្រោងមានការគាំទ្រពីបណ្តាភាគីពាក់ព័ន្ធ ដោយផ្អែកលើការធ្វើពិគ្រោះយោបល់បឋម

៤. ក្រសួងស្ថាប័នម្ចាស់សំណើគម្រោង មានឆន្ទៈក្នុងការអនុវត្តគម្រោង ដោយផ្តល់ការបញ្ជាក់ជាលាយលក្ខអក្សរ។

៥. គម្រោងមិនត្រូវការចំណាយខ្ពស់ លើការដោះស្រាយផលប៉ះពាល់ដីធ្លី បរិស្ថាន និងសង្គម

៦. លទ្ធផលយថាប្រភេទ (Output Specification)[20] និងយន្តការទូទាត់ត្រូវបានកំណត់ច្បាស់លាស់។

៧. គម្រោងប្រហាក់ប្រហែលនឹងសំណើគម្រោង ធ្លាប់បានធ្វើកិច្ចលទ្ធកម្មពីមុនមក ។

រាល់សំណើគម្រោងណាដែលមិនអនុលោម តាមលក្ខខណ្ឌវិនិច្ឆ័យណាមួយខាងលើ គឺត្រូវវាយតម្លៃឲ្យធ្លាក់ និងមិនអាចបន្តទៅដំណាក់កាលទី២ បានឡើយ។

❖ **ដំណាក់កាលទី២៖** "ការដាក់ពិន្ទុ"

---

[20] គម្រោង PPP គឺតម្រូវឲ្យគម្រោងដែលបង្កើតឡើងត្រូវបានកំណត់បញ្ជាក់សមិទ្ធិផលការងារ ជាជាងគិតពីធាតុចូលដូចគម្រោងទូទៅ ។ ឧទាហរណ៍៖ គម្រោងសាងសង់ផ្លូវ មានន័យថាលទ្ធផលយថាប្រភេទនៃគម្រោង PPP គឺ "គុណភាពនៃផ្លូវថ្នល់" ជាជាងបញ្ជាក់វាយលម្អិតនៃការសាងសង់ផ្លូវថ្នល់នោះ។

១. ការទទួលយករបស់ទីផ្សារ (Market Acceptability)

២. យន្តការប្រមូលចំណូលអាចប៉ាន់ស្មានបាន និងមានភាពទាក់ទាញផ្នែកហិរញ្ញវត្ថុ

៣. ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម (Economic and Social Desirability)

៤. ការបែងចែកហានិភ័យសមស្រប

៥. ចំណាយក្នុងមួយវដ្តគម្រោងចាប់ពីការវិនិយោគ ប្រតិបត្តិការ និងថែទាំអាចប៉ាន់ស្មាន

៦. អនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមាន

រាល់គម្រោងណាដែលទទួលបានពិន្ទុសរុបចាប់ពី ៧០% (ភាគរយ) ឡើងទៅត្រូវវាយតម្លៃឲ្យជាប់ និងបន្តធ្វើអាទិភាពរូបនីយកម្មគម្រោង ឬ ចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃការវាយតម្លៃ។[21]

**២.៣.២ ដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង** (F/S)

ការសិក្សាសមិទ្ធិលទ្ធភាព ពេញលេញដែលជាមូលដ្ឋាន នៃការសិក្សាសមិទ្ធិភាពបន្តពីដំណាក់កាលការធ្វើអត្តសញ្ញាណកម្មគម្រោងជាគោលការណ៍ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងចាប់ផ្តើមពិនិត្យខាងផ្នែកបច្ចេកទេស។ ដើម្បីកំណត់លទ្ធផលដែលគម្រោងត្រូវការ និងបញ្ជាក់អំពីសមិទ្ធិលទ្ធភាពបច្ចេកទេស។ យើងអាចដឹងពីបច្ចេកទេសក្នុងការសិក្សាសមិទ្ធិលទ្ធភាពបាន គឺត្រូវរកចម្លើយដើម្បីបំភ្លឺនូវសំណួរដូចជា៖ តើបច្ចេកវិទ្យាដែលបង្កើតមកអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចគោលបំណងគម្រោងទេ? រដ្ឋត្រូវតែធ្វើការប៉ាន់ស្មានពីដើមទុន និងចំណាយប្រតិបត្តិការគម្រោងនេះផងដែរ។ បន្ទាប់មកគឺរដ្ឋត្រូវតែវាយតម្លៃ ផលប្រយោជន៍សង្គម និងសេដ្ឋកិច្ចរបស់គម្រោង។ តើអ្វីជាឥទ្ធិពលទៅលើការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច? តើចំណេញសេដ្ឋកិច្ចច្រើនជាងចំណាយសេដ្ឋកិច្ចឬទេ? យ៉ាងណាមិញ តើគម្រោងនេះសមរម្យទេ បើគិតពីប្រយោជន៍សង្គមនិងសេដ្ឋកិច្ច? បន្ទាប់មករដ្ឋត្រូវតែពិចារណាពីកត្តាហិរញ្ញវត្ថុ។ តើមានអ្នកប្រើប្រាស់ប៉ុន្មានអ្នកដែលនឹងប្រើប្រាស់សេវាសាធារណៈនេះ? តើប្រាក់ចំណូលប៉ុន្មានដែល នឹងទទួលបានពីគម្រោង? តើអ្វីដែលរដ្ឋសង្ឃឹមថានឹងបានមកវិញ? តើគម្រោងនេះទទួលការចាប់អារម្មណ៍ពីធានាគារទេ(មានធានាគារណាចាប់អារម្មណ៍ផ្តល់កម្ចីដល់គម្រោងទេ)? ការកំណត់ទាំងអស់នេះទាមទារការបង្កើត គំរូហិរញ្ញវត្ថុដែលអាចឆ្លុះបញ្ចាំងឲ្យឃើញភាពខុសគ្នាដោយផ្អែកទៅលើមូលដ្ឋានការសន្និដ្ឋានខុសៗគ្នា។ ការវិភាគហិរញ្ញវត្ថុ គួរតែបញ្ចូលការពិនិត្យឡើងវិញអំពីនិរន្តរភាពហិរញ្ញវត្ថុគម្រោង។ តើគម្រោងនេះរដ្ឋាភិបាលអាចមានលទ្ធភាពទទួល បន្ទុកខាងហិរញ្ញវត្ថុបានទេ? តើមានជម្រើសផ្សេង ដើម្បីកាត់បន្ថយការទាមទារការគាំទ្រថវិកាពីរដ្ឋាភិបាលទេ? តើរដ្ឋាភិ-បាលមានលទ្ធភាពផ្តល់ការឧបត្ថម្ភធនតាមតម្រូវការគម្រោងទេ? កត្តាប្រឈមខាងច្បាប់ និងបទប្បញ្ញត្តិ

[21] បទបង្ហាញគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារ-ណៈ២០១៦-២០២០ ធ្វើនៅទីស្តីការគណៈរដ្ឋមន្ត្រី (រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧)

ក៏ទាមទាមឱ្យពិនិត្យឡើងវិញដែរ។ ឧទាហរណ៍៖ តើមានគោលការណ៍ ច្បាប់គ្រប់គ្រាន់ទេ ដើម្បីឲ្យរដ្ឋាភិបាលចូលរួម ក្នុងរចនាសម្ព័ន្ធគម្រោង PPP នេះ? រដ្ឋត្រូវតែវាយតម្លៃទៅលើហានិភ័យនៃការអូសបន្លាយគម្រោងបណ្ដាលមកពីឧបសគ្គខាងបទប្បញ្ញត្តិផងដែរ។

ក្រៅពីចំណុចខាងលើនេះ រដ្ឋត្រូវតែពិចារណាផលអវិជ្ជមានដែលប៉ះពាល់ដល់ សង្គម និងបរិស្ថាន។ តើគម្រោងទាមទារឲ្យមានការដោះស្រាយផលប៉ះពាល់របស់ប្រជាជនទេ? តើគម្រោងនឹងចូលរួមបង្កើនការបញ្ចេញឧស្ម័នកាបូនិចដែរឬទេ? តើគម្រោងអនុលោមតាមស្តង់ដារសង្គម និងបរិស្ថានទេ? ការរៀបចំផែនការអាជីវកម្ម ទាមទារបន្ថែមថាលោកអ្នកត្រូវតែបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ដៃគូនីមួយៗ។ តើអ្វីដែលជាការដាក់ស្នើចែករំលែកហានិភ័យ? ការចែករំលែកហានិភ័យគឺជាកត្តាសខាន់ ព្រោះវាជួយកំណត់ អំពីលទ្ធភាពនៃភាពជាគជ័យរបស់គម្រោង PPP និងភាពទាក់ទាញរបស់គម្រោងទៅវិនិយោគិនឯកជនដែរ។ រដ្ឋាភិបាលក៏អាចកំណត់ ថាតើវាមានការចាប់អារម្មណ៍មកលើគម្រោងដែលបានដាក់ស្នើពីភាគីឯកជនទេ តាមរយៈការស្ទាបស្ទង់ផ្សារដូចជាការធ្វើ Roadshows ជាដើម (ករណីគម្រោងស្នើឡើងដោយវិស័យឯកជន)។ បន្ថែមពីនេះលោកអ្នកគួរតែពិចារណាភាពជោគជ័យនៃគម្រោងដែលមាន លក្ខណៈប្រហាក់ប្រហែលគ្នា ដែលអាចទាក់ទាញចំណាប់អារម្មណ៍ពីវិនិយោគិនឯកជន។ ជាមួយពត៌មានទាំងអស់ដែលប្រមូលបានទាំងអស់នេះ រដ្ឋាភិបាលនឹងស្ថិតនៅចំណុចមួយដែលល្អ ដើម្បីបញ្ជាក់ឱ្យឃើញថា ការវិភាគ "តម្លៃជាសាច់ប្រាក់" និងបញ្ជាក់ ថាតើ PPP ជាវិធីសាស្ត្រលទ្ធកម្មដ៏សមស្របសម្រាប់គម្រោង នៅពេលអនាគតរបស់ប្រទេស។ ប្រទេសមួយចំនួនប្រើប្រាស់វិធីសាស្ត្រវាយតម្លៃបរិមាណដើម្បីសិក្សាប្រៀបធៀបចំណាយដើមទុនប៉ាន់ស្មាន របស់គម្រោងស្នើសុំតាមយន្តការ PPP ជាមួយនឹងវិធីសាស្ត្រដេញថ្លៃបែបទូទៅ។ នៅក្នុងការអនុវត្តជាសកល ក៏ដូចជាការអនុវត្តរបស់កម្ពុជា នៃដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព គឺជាដំណាក់កាលដែលបន្តសិក្សាលម្អិតពីដំណាក់កាល ធ្វើអត្តសញ្ញាណកម្មគម្រោងដើម្បីឲ្យការសិក្សាផលប៉ះពាល់គម្រោងកាន់តែសុក្រឹត្យ។ ក្នុងដំណាក់កាល "F/S" នេះក្រសួងស្ថាប័នម្ចាស់សំណើអាចជួលទីប្រឹក្សា (Transaction Advisors) ដើម្បីធ្វើការសិក្សា F/S ដោយស្នើសុំហិរញ្ញប្បទានពីមូលនិធិអភិវឌ្ឍន៍គម្រោង (PDF)។ ពេលដែលគម្រោងត្រូវបានសិក្សាសមិទ្ធិលទ្ធភាពរួចរាល់និងច្បាស់លាស់រួចមក ក្រសួងស្ថាប័នម្ចាស់សំណើគម្រោងនឹងរៀបចំនីតិវិធីដាក់អោយវិស័យឯកជនដេញថ្លៃ ដើម្បីទទួលបានអ្នកគ្រប់គ្រងគម្រោងសម្បទាន ឬគម្រោង PPP ដែលស្នើឡើងដើម្បីជ្រើសរើសសម្បទានិក។

### ២.៣.៣ ដំណាក់កាលលទ្ធកម្ម និងចុះកិច្ចសន្យា

ក្នុងការអនុវត្តជាសកលកិច្ចលទ្ធកម្មគម្រោងបែប PPP គឺត្រូវបង្កើតឲ្យមាននីតិវិធីលទ្ធកម្មដោយឡែកពីកិច្ចលទ្ធកម្មគម្រោងសាធារណៈទូទៅ ប៉ុន្តែប្រទេសកម្ពុជាវិញមកដល់ពេលនេះមិនទាន់មាននីតិ

វិធីលទ្ធកម្ម តាមភាពជាដៃគូរវាងរដ្ឋ និងឯកជននៅឡើយ គឺកម្ពុជានូវតែយកគម្រោង PPP មកអនុវត្ត តាមនីតិវិធីលទ្ធកម្មតាមគម្រោងសាធារណៈទូទៅ ប៉ុន្តែអនុលោមតាមនិយាម PPP។ ក្នុងនីតិវិធីលទ្ធកម្ម គម្រោង PPP ទោះបីកម្ពុជាអនុវត្តតាមកិច្ចលទ្ធកម្ម ទូទៅក៏ដោយក៏កម្ពុជានូវតែយកគោលការណ៍កិច្ច លទ្ធកម្ម PPP មកអនុវត្តផងដែរដោយមានការផ្តល់បច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី និងមានអង្គ ភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាលសហការជាមួយក្រសួងស្ថាប័នតាមវិស័យ និងមាន ជួលទីប្រឹក្សា ឬអ្នកជំនាញការមកជួយធ្វើ និងចង្អុលបង្ហាញផ្លូវដល់មន្ត្រី។ ការអនុវត្តជាសកល ក៏ដូចជា ការអនុវត្តរបស់កម្ពុជាក្នុងដំណើការកិច្ចលទ្ធកម្មទូទៅតាមនិយាម PPP ដូចខាងក្រោមៈ

ដំបូងគឺរៀបចំឯកសារការដេញថ្លៃ អ្វីដែលសំខាន់ជាងគេបង្អស់ គឺសេចក្តីព្រាងកិច្ចសន្យា PPP។ សេចក្តីព្រាងកិច្ចសន្យានឹងបង្ហាញយ៉ាងច្បាស់នូវសំណើសម្រាប់ដៃគូឯកជន និងបញ្ជាក់អំពីតួនាទី និង ការទទួលខុសត្រូវរបស់ភាគីដែលពាក់ព័ន្ធ។ ការរៀបចំប្រតិបត្តិការក៏ទាមទារការអភិវឌ្ឍន៍យុទ្ធសាស្ត្រ កិច្ចលទ្ធកម្ម។ តើអ្វីទៅដែលជាកត្តាវិនិច្ឆ័យប្រើប្រាស់ ដើម្បីវាយតម្លៃបេក្ខជនដេញថ្លៃ? តើទំនាក់ ទំនងជាមួយអ្នកដេញថ្លៃកម្រិតណាដែល នឹងត្រូវអនុញ្ញាតនៅពេលប្រតិបត្តិការគម្រោង? អន្តរកម្មបែប នេះអាចបង្កើនគុណភាពសំណើគម្រោង ដោយរួមបញ្ចូលនូវអនុសាសន៍ពីអ្នកដេញថ្លៃដែលអាចមាន ប្រយោជន៍ សម្រាប់គម្រោងដ៏ស្មុគស្មាញដូចជា PPP អន្តរកម្មនេះក៏អាចធ្វើឲ្យបាត់បង់តម្លាភាព និង ជំហានផ្សេងៗដែលត្រូវអនុវត្ត ដើម្បីកាត់បន្ថយហានិភ័យអំពើពុករលួយ។ កំឡុងពេលមុនពេលដេញ ថ្លៃក្រសួងស្ថាប័នធ្វើលទ្ធកម្មអាចផ្សព្វផ្សាយបន្ត អំពីគម្រោងដោយរៀបចំឲ្យមានកិច្ចប្រជុំមួយ មុនការ ដេញថ្លៃជាមួយនិងអ្នកដេញថ្លៃ និងផ្សាយដំណឹងលទ្ធកម្ម ដើម្បីជូនពត៌មានដល់បណ្តាវិនិយោគិនអំពី គម្រោងដែលនឹងកើតមានឡើង បន្ទាប់មកគឺការកំណត់បុរេលក្ខណៈវិនិច្ឆ័យមុនការដេញថ្លៃ។ ការគូស បញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យសំណើអំពីលក្ខណៈវិនិច្ឆ័យ RFQ ជាជំហានដំបូងនៃប្រតិបត្តិការគម្រោង។ កម្រងឯកសារនេះ គឺដើម្បីផ្តល់ព័ត៌មានទៅឲ្យវិនិយោគិនឲ្យបានជ្រាប អំពីលក្ខខ័ណ្ឌពាណិជ្ជកម្មសំខាន់ មួយចំនួនរបស់គម្រោង និងស្តីពីដំណើរការរួមនៃការដេញថ្លៃ និងកត្តាវិនិច្ឆ័យសម្រាប់ជ្រើសរើសគុណ សម្បត្តិ។ តាមរយៈការកំណត់បុរេលក្ខណៈវិនិច្ឆ័យរដ្ឋអាចជ្រើសរើសយកក្រុមហ៊ុនមួយចំនួនដែលមាន បទពិសោធន៍ សមត្ថភាព និងធនធាន ដើម្បីអនុវត្តគម្រោងបាន។ គោលបំណងនេះរដ្ឋមិនចង់ ជ្រើស រើសក្រុមហ៊ុនដែលពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងទេ គឺវិស័យសាធារណៈចង់ចុះកិច្ច សន្យាគ្រប់គ្រងគម្រោងជាមួយនឹងបណ្តាក្រុមហ៊ុនមួយចំនួនដែលជា អ្នកដេញថ្លៃដែលមានគុណភាព ល្អ។ ឧទាហរណ៍ៈ មាន ៣ ទៅ ៦ ក្រុមហ៊ុន ដែលចំនួននេះគ្រប់គ្រាន់សម្រាប់រក្សាសំពាធភាពប្រកួត ប្រជែង នៅពេលដែលសម្របសម្រួលទំនាក់ទំនងជាមួយនិងអ្នកដេញថ្លៃ។ នេះក៏ជាការបង្កើនឱកាស នៃភាពជោគជ័យដល់អ្នកដេញថ្លៃនីមួយៗ ហើយបើសិនអ្នកដេញថ្លៃមានឱកាសទទួលបានជោគជ័យ

ខ្ពស់ ពួកគេនឹងចង់ធ្វើការបណ្តាក់ទុនក្នុងដំណើរការដេញថ្លៃនេះ។ ដំណើរការដេញថ្លៃ គឺចាប់ផ្តើមនៅពេលបញ្ចប់នៃការសិក្សាគុណសម្បត្តិអ្នកដេញថ្លៃ។ ឯកសារដេញថ្លៃពេញលេញក្នុងនោះមានសេចក្តីព្រាងកិច្ចសន្យា PPP ត្រូវបានបញ្ជូនទៅអ្នកដេញថ្លៃដែលមានគុណសម្បត្តិគ្រប់គ្រាន់នៃជំហានចាប់ផ្តើមនៃការដេញថ្លៃ។ អ្នកដេញថ្លៃគឺនឹងមានឱកាស ដើម្បីបញ្ជាក់ពីចំណុចនៅក្នុងសេចក្តីព្រាងកិច្ចសន្យាដែលមិនទាន់ច្បាស់ជាមួយនិងស្ថាប័នចុះកិច្ចសន្យា។ ដើម្បីសម្របសម្រួលកិច្ចការនេះការធ្វើសិក្ខាសាលាគឺតែងតែរៀបចំនៅពេលដែលអ្នកដេញថ្លៃ មានគុណសម្បត្តិត្រឹមត្រូវអាចស្វែងរក ការបញ្ជាក់បំភ្លឺទៅលើឯកសារការដេញថ្លៃនោះ។ បន្ទាប់មកអ្នកដេញថ្លៃដែលមានគុណសម្បត្តិគ្រប់គ្រាន់អាចធ្វើការដាក់ស្នើគម្រោងរបស់ពួកគេ។ ប្រសិនបើរដ្ឋសម្រេចជ្រើសរើសឲ្យមានការដេញថ្លៃតែមួយដង អ្នកដេញថ្លៃគឺអាចដាក់ស្នើទាំងឯកសារបច្ចេកទេសនិងសំណើហិរញ្ញវត្ថុនៅពេលជាមួយគ្នា។ ប្រសិនបើរដ្ឋសម្រេចនឹងឲ្យមានទំនាក់ទំនងច្រើនជាងនេះ ជាមួយនឹងអ្នកដេញថ្លៃដោយប្រើដំណើរការ ០២ ជំហានអ្នកដេញថ្លៃត្រូវតែដាក់ស្នើអំពីគម្រោងបច្ចេកទេសជាមុនសិន។ ភាគីទាំងអស់អាចធ្វើការពិភាក្សាទៅលើគម្រោងផែនការដាក់ស្នើ និងអាចមានការកែសម្រួលឯកសារដេញថ្លៃ។ ឯកសារដេញថ្លៃដែលបានពិនិត្យឡើងវិញ ហើយនឹងត្រូវបញ្ជូនទៅឲ្យក្រុមអ្នកដេញថ្លៃ ដើម្បីចាប់ផ្តើមរៀបចំគម្រោងផែនការទាំងខាងបច្ចេកទេសនិងហិរញ្ញវត្ថុ។ ដំណាក់កាលវាយតម្លៃនឹងធ្វើបន្ទាប់ពីការបញ្ចប់ដំណើរការដេញថ្លៃ។ ប្រសិនបើរដ្ឋ រើសយកការសម្រេចចិត្តដោយផ្អែកទៅលើកត្តាហិរញ្ញវត្ថុជាមួយនឹងប្រព័ន្ធស្រោមសំបុត្រពីរ ដំបូងត្រូវបើកគម្រោងសំណើបច្ចេកទេស និងវាយតម្លៃទៅលើគោលការណ៍ ជាប់/ធ្លាក់ បើសិនគម្រោងសំណើបច្ចេកទេសជាប់លោកអ្នកត្រូវពិនិត្យអំពីសំណើហិរញ្ញវត្ថុដែលដាក់ស្នើ។ គម្រោងសំណើហិរញ្ញវត្ថុ គឺអាចវាយតម្លៃធៀបនឹងកត្តាវិនិច្ឆ័យដូចជាអត្រាតម្លៃទាបបំផុតសម្រាប់អ្នកប្រើប្រាស់ឬចំណាយតិចបំផុតសម្រាប់រដ្ឋាភិបាលទទួលបន្ទុក។ ក្រសួងស្ថាប័នសាធារណៈក៏អាចត្រូវធ្វើការសម្រេចចិត្តដោយផ្អែកទៅលើការបញ្ចូលគ្នាទាំងកត្តាហិរញ្ញវត្ថុនិងបច្ចេកទេស។ នៅពេលអភិក្រមនេះមានគុណសម្បត្តិ វាក៏អាចធ្វើឱ្យមានការកើនឱកាសជាច្រើន ពីការវាយតម្លៃអត្តនោម័តដូច្នេះវាបង្កើនហានិភ័យនៃអំពើពុករលួយផងដែរ។ យោងតាមលទ្ធផលការវាយតម្លៃអ្នកដេញថ្លៃដែលឈ្នះការដេញថ្លៃត្រូវបានជ្រើសរើសនិងធ្វើការចរចាចុងក្រោយនឹងចាប់ផ្តើម។ ការចរចាបែបនេះគឺមានគោលបំណងដើម្បីបញ្ជាក់អំពីបញ្ហាដែលនៅសេសសល់ និងធ្វើបច្ចុប្បន្នកម្មកិច្ចសន្យាស្របតាម ការស្នើជាក់លាក់ណាមួយរបស់អ្នកឈ្នះការដេញថ្លៃ។ ពុំមានការផ្លាស់ប្តូរខាងសម្ភារៈណាមួយត្រូវកែសម្រួលក្នុងកិច្ចសន្យា ដែលបានព្រមព្រៀងគ្នាក្នុងអំឡុងពេលការដេញថ្លៃទេ។ ការធ្វើបែបនេះគឺធានាថាដំណើរការប្រកបទៅដោយភាពយុត្តិធម៌ចំពោះអ្នកដេញថ្លៃផ្សេងៗទៀត ដែលបានដាក់សំណើគម្រោងខុសៗគ្នាបើសិនគេដឹងថា កិច្ចសន្យានឹងត្រូវមានការកែសម្រួល ក្រោយថ្ងៃប្រកាសចុងក្រោយវានឹងអាចមានបញ្ហា

ចោទឡើង។ ការកែសម្រួលកិច្ចសន្យាក៏អាចមកពី សម្ពាធពីក្រុមអ្នកផ្តល់ប្រាក់កម្ចីផងដែរនៅ កំឡុងពេលដែលដែលអ្នកដេញថ្លៃឈ្នះកំពុងតែបង្ហើយកិច្ចព្រមព្រៀងឥណទាន អ្នកផ្តល់កម្ចីឥណទានអាចដាក់សំពាធមកលើអ្នកឈ្នះការដេញថ្លៃ ថាខ្លួននឹងមិនគាំទ្រគម្រោងនេះឡើយ ប្រសិនបើមានការទាមទារឲ្យមានការ កែសម្រួលកិច្ចសន្យាដែលពុំបានយក ទៅពិចារណាដូច្នេះវាធ្វើឲ្យបរាជ័យការងារទាំងអស់របស់គម្រោង ប្រសិនបើគម្រោងត្រូវបរាជ័យរដ្ឋាភិបាល អាចធ្វើការជ្រើសរើសសម្បទានិកជាថ្មី ឬអាចបោះបង់គម្រោងចោលមិនអនុវត្ត។ នៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់វានឹងត្រូវធ្វើការដាក់ស្នើសុំការអនុម័តពីអាជ្ញាធរសាធារណៈ។ នៅពេលនោះ គឺគម្រោងអាចចាប់ផ្តើមដំណើរការនៅក្រោមលក្ខខណ្ឌថាកិច្ចព្រមព្រៀងហិរញ្ញវត្ថុត្រូវបានបញ្ចប់រួចរាល់ហើយដែរ "លក្ខខណ្ឌដែលត្រូវបំពេញ" គឺត្រូវបានបញ្ចូលក្នុងកិច្ចសន្យា (រួមបញ្ចូលទាំងការទទួលបានច្បាប់អនុញ្ញាត និងកន្លែងអនុវត្តគម្រោង) ។ ក្នុងកិច្ចលទ្ធកម្មនេះដែរ ផ្អែកតាមច្បាប់សម្បទានឆ្នាំ២០០៧ ស្ថាប័នជាប់កិច្ចសន្យាធ្វើការ ជ្រើសរើសសម្បទានិកតាមវិធីដេញថ្លៃជាលក្ខណៈជាតិ ឬ អន្តរជាតិឬតាមនីតិវិធីចរចាដោយផ្អែកទៅតាមកាលៈទេសៈ។ នៅពេលដំណើការជ្រើសរើសសម្បទានិកត្រូវបានបំពេញសព្វគ្រប់ ហើយស្ថាប័នជាប់កិច្ចសន្យាក៏បានត្រៀម ក្នុងការទទួលពាក្យដេញថ្លៃចុងក្រោយ ឬ ការស្នើចរចាហើយនោះស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួលបាន នូវការអនុម័តជាគោលការណ៍សម្រាប់លក្ខខណ្ឌចុងក្រោយនៃកិច្ចសន្យាសម្បទានតាមការតម្រូវ និងស្របតាមនីតិវិធីដែលនឹងមានចែងក្នុងអនុក្រឹត្យ។ អ្នកដេញថ្លៃអាចដកពាក្យដេញថ្លៃចេញ ប្រសិនបើការពិនិត្យឡើងវិញនូវ កិច្ចសន្យាសម្បទានដែលបានរៀបចំស្របតាមបទប្បញ្ញត្តិ នៃច្បាប់សម្បទានធ្វើឲ្យបេក្ខជនដែលបាន ជ្រើសរើសតាមនីតិវិធីត្រឹមត្រូវ ហើយរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដែលការដកពាក្យវិញនេះមិនបានបាត់បង់ប្រាក់តម្កល់សម្រាប់ការធានាការដេញថ្លៃឡើយ។ បន្ទាប់ពីអនុម័តយល់ព្រមស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា១២ នៃច្បាប់សម្បទាន ស្ថាប័នជាប់កិច្ចសន្យាត្រូវចេញសេចក្តីជូនដំណឹងពីការ ផ្តល់សម្បទានទៅបេក្ខជនដែលបានជ្រើសរើស មុននឹងអនុវត្តការចុះកិច្ចសន្យាសម្បទាន។ ក្នុងរយៈពេល០៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹងស្តីពីការផ្តល់សម្បទាន ស្ថាប័នជាប់សន្យា និងសម្បទានិក ត្រូវតែចុះហត្ថលេខាលើកិច្ចសន្យាសម្បទានក្នុងអំឡុងពេលដែលបានកំណត់រយៈពេលនេះអាចពន្យាបាន ប្រសិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីទាំងពីរ។ ការខកខានរបស់ស្ថាប័នជាប់កិច្ចសន្យា ដូចក្នុងរយៈពេលដែលបានកំណត់ខាងលើ សម្បទានិកមានសិទ្ធិដកពាក្យដេញថ្លៃ ឬដកការស្នើចរចាដោយ មិនបាត់បង់ប្រាក់តម្កល់ធានាការដេញថ្លៃឡើយ។ ដំណាក់កាលនេះដែរក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទាន សម្បទានិកត្រូវបង្កើតដោយរួសរាន់ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នូវនីតិបុគ្គលមួយដែលនឹងអនុវត្ត គម្រោង

សម្បទាន និងដាក់ពាក្យសុំជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ស្របតាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**បញ្ជាក់ផងដែរកិច្ចសន្យាសម្បទានត្រូវបានកំណត់នូវករណីដូចខាងក្រោម៖**

- ប្រភេទ វិសាលភាព បមណីការងារដែលត្រូវបំពេញ និងសេវាកម្មដែលត្រូវផ្តល់ដោយ សម្បទានិក។

- ការលើទឹកចិត្តដែលត្រូវផ្តល់ ដើម្បីលើកទឹកកម្ពស់ប្រសិទ្ធភាពនៃការចំណាយបង្កើនល្បឿននៃការសាងសង់ និងបង្កើនគុណភាពនៃកិច្ចដំណើការ និងការថែទាំដើម្បីជាប្រយោជន៍សាធារណៈ។

- រាល់កម្រៃថ្លៃបង់ការប្រើប្រាស់ថ្លៃឈ្នួលជួល ឬ ចំណាយផ្សេងៗ ដែលត្រូវដាក់ឲ្យសម្បទានិកអនុវត្ត ត្រូវតែបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

- ការព្រមព្រៀងលើការទទួលយកហានិភ័យរៀងៗខ្លួន ឬ ការព្រមព្រៀងពីការទទួលយកហានិភ័យរួមគ្នា។

- ការកម្រិតសេវាកម្ម និងបមាណីដែលតម្រូវឲ្យសម្បទានិកអនុវត្តនៅក្នុងប្រតិបត្តិការនិងការគ្រប់គ្រងសំណង់ហេដ្ឋារចនាសម្ព័ន្ធនិងផលវិបាកនៃការមិនអនុវត្តស្របតាមកម្រិតសេវាកម្មនិងបមាណីដែលបានកំណត់។

- យន្តការបង់ប្រាក់។

- ការប្តេជ្ញាចិត្ត និងកិច្ចសហប្រតិបត្តិការរបស់ស្ថាប័នជាប់កិច្ចសន្យា និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ក្នុងការគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងអំឡុងពេលសម្បទាន។

- ករណីផ្សេងៗទៀត ប្រសិនបើភាគីទាំងពីរយល់ថាសមស្រប។ ក្រៅពីករណីដែលកំណត់ទាំងនេះកិច្ចសន្យាសម្បទានក៏អាចមានចែងពីករណីផ្សេងៗ ដែលបទប្បញ្ញត្តិនៃច្បាប់សម្បទាន ឬច្បាប់ដទៃទៀតបានកំណត់ ។[22] កិច្ចសន្យាសម្បទានមានរយៈពេលមិនលើសពី ៣០ (សាមសិប) ឆ្នាំគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាសម្បទានដោយផ្អែកតាមមាត្រា១៣នៃច្បាប់សម្បទាន។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ យោងទៅលើប្រភេទនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាអាចកំណត់រយៈពេលសម្បទានវែងជាងនេះ។ បន្ថែមពីចំណុចខាងលើហើយជា ចំណុចដែលត្រូវតែកំណត់ឲ្យបានច្បាស់លាស់ អំពីច្បាប់គ្រប់គ្រងកិច្ចសន្យាសម្បទាន តាមច្បាប់សម្បទានកម្ពុជា កិច្ចសន្យាសម្បទានត្រូវគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ប្រសិនបើពុំមានច្បាប់ ឬបទប្បញ្ញត្តិរបស់កម្ពុជាចែងអំពីករណីដែលពាក់ព័ន្ធនោះទេ បទប្បញ្ញត្តិនៃកិច្ចសន្យាសម្បទានត្រូវគ្រប់គ្រងដោយ

[22] មាត្រា១១-មាត្រា១៥នៃច្បាប់សម្បទាន២០០៧

ច្បាប់ ដែលជ្រើសរើសដោយភាគីជាប់កិច្ចសន្យា ដោយមិនផ្ទុយនិងច្បាប់នៃប្រទេសកម្ពុជាឡើយ។ ចំណុចសំខាន់មួយទៀតនៃកិច្ចសន្យាសម្បទានដែលត្រូវតែចែងបញ្ជាក់ គឺយន្តការដោះស្រាយវិវាទ ដែលកើតចេញពីស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក ចំណុចនេះ ច្បាប់កម្ពុជាតម្រូវអោយមានចែងលម្អិតក្នុងកិច្ចសន្យាសម្បទាន។ តាមការអនុវត្តជាសកលយន្តការដោះស្រាយវិវាទគឺធ្វើឡើងតាមរយៈការចរចា ឬ មជ្ឈត្តករអន្តរជាតិ ឬតាមផ្លូវតុលាការ។

### ២.៣.៤ ដំណាក់កាលគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

ដំណាក់កាលគ្រប់គ្រងគម្រោង គឺជាដំណាក់កាលដែលគម្រោងសម្បទាន ឬ PPP បានមកដល់ដៃសម្បទានិក។ សម្បទានិកចាប់ផ្តើមអនុវត្តគម្រោងវិនិយោគដូចដែលបាន ចែងក្នុងកិច្ចសន្យាសម្បទានតាមដំណាក់កាលៗនៃគម្រោងវិនិយោគ។ ចំណុចនេះយើងមិនអាចធ្វើការពិពណ៌នាពីការអនុវត្ត និងការគ្រប់គ្រងគម្រោងរបស់សម្បទានិកបានទេ ពីព្រោះវាជាការអនុវត្តជាក់ស្តែងរបស់គម្រោង ប៉ុន្តែយើងអាចបង្ហាញពីសិទ្ធិ និងភារកិច្ចរបស់ស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិកមានក្នុងដំណាក់កាលនេះ ទៅតាមការចែងនៃច្បាប់សម្បទានឆ្នាំ២០០៧ និងការចង្អុលបង្ហាញរបស់ ឯកសារគោលនយោបាយ PPP របស់កម្ពុជាព្រមទាំងតាមនិយាម PPP ជាអន្តរជាតិ។

- **សិទ្ធិ និងកាតព្វកិច្ចដែលសម្បទានិកមាននឹងត្រូវបំពេញ**

ដំណាក់កាលគ្រប់គ្រងគម្រោង សម្បទានិកត្រូវតម្កល់ប្រាក់ធានាការអនុវត្តកិច្ចសន្យាឲ្យបានពេញលេញ សម្រាប់ដំណាក់កាលជាកំណត់នៃគម្រោងសម្បទាន ជូនដល់ស្ថាប័នជាប់កិច្ចសន្យា ទៅតាមទម្រង់ពេលវេលា និងបរិមាណដែលចែងក្នុងកិច្ចសន្យាសម្បទាន។ ក្នុងកិច្ចគ្រប់គ្រងកិច្ចសន្យាសម្បទានិកអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដោយសាមីខ្លួនត្រូវទទួលបន្ទុក ការចំណាយទាំងអស់និងជាអ្នករ៉ាប់រងហានិភ័យ ដោយមិនត្រូវពឹងផ្អែកលើការសុំឥណទាន ឬការធានាពីស្ថាប័នជាប់កិច្ចសន្យាឡើយ ប៉ុន្តែស្ថាប័នជាប់កិច្ចសន្យាក៏តម្រូវឲ្យធានាបានដែរក្នុងកាលៈទេសៈពិសេស។ សម្បទានិកមានសិទ្ធិបង្កើតសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ សិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនដែលទទួលបានពីការធ្វើសម្បទាន ដើម្បីធានានូវរាល់ហិរញ្ញប្បទានដែលត្រូវការ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ដើម្បីស្តារការចំណាយក្នុងការប្រតិបត្តិការគម្រោង និងរកប្រាក់ចំណេញពីគម្រោងសម្បទាន សម្បទានិកមានសិទ្ធិទទួល ឬប្រមូលថ្លៃប្រើប្រាស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ឬសេវាកម្មដែលខ្លួនបានផ្តល់ឲ្យ។ ក្រៅពីការចំណាយប្រតិបត្តិការគម្រោងសម្បទានិកក៏ត្រូវបង់សួយសារ ឬ កម្រៃសម្បទានតាមការកំណត់នៃកិច្ចសន្យាសម្បទាន ជូនរដ្ឋស្របតាមគោលការណ៍ នឹងលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យាសម្បទាន។

- **កិច្ចដែលវិស័យសាធារណៈត្រូវបំពេញ**

ស្ថាប័នផ្តល់សម្បទាន ឬ ស្ថាប័នមានសមត្ថកិច្ចដទៃទៀតដោយផ្អែកទៅតាមលក្ខខណ្ឌច្បាប់ត្រូវជួយសម្បទានិកឲ្យទទួលបានសមស្រប នូវសិទ្ធិប្រើប្រាស់ដី និងសិទ្ធិដទៃទៀតដែលពាក់ព័ន្ធទៅនឹងទីតាំងគម្រោងដែលមានភាពចាំបាច់ដើម្បីអនុវត្តគម្រោងសម្បទាន។ ស្ថាប័នជាប់កិច្ចសន្យាធ្វើការអង្កេត និងធ្វើអធិការកិច្ចលើការអនុវត្តគម្រោងសម្បទាន ដើម្បីធានាថាគម្រោងបានសាងសង់ធ្វើអាជីវកម្ម និងថែទាំស្របទៅតាមច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជណាចក្រកម្ពុជា និងលក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន។ ស្ថាប័នជាប់កិច្ចសន្យាមានសិទ្ធិចូលពិនិត្យកិច្ចការហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាការគូសប្លង់របាយការណ៍ និងទិន្នន័យផ្សេងៗ ដែលមានភាពចាំបាច់សម្រាប់ធ្វើការអង្កេត និងធ្វើអធិការកិច្ចដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន។ លើសពីនេះអាជ្ញាធរសាធារណៈត្រូវតែបង្កើតបរិយាកាសល្អ ដើម្បីជម្រុញឲ្យគម្រោងសម្បទានអនុវត្តទទួលបានជោគជ័យ និងជម្រុញលើកទឹកចិត្តអោយសម្បទានិកស្វែងរកនវានុវត្តថ្មីៗជុំវិញគម្រោងសម្បទាន។

### ២.៣.៥ ដំណាក់កាលបញ្ចប់គម្រោង PPP

គម្រោងសម្បទាន ឬកិច្ចសន្យាសម្បទានត្រូវបានបញ្ចប់នូវពេលការកំណត់បញ្ចប់មកដល់ ប៉ុន្តែកិច្ចសន្យាសម្បទាន ក៏អាចបញ្ចប់មុនពេលកំណត់បានដែរនៅ ពេលកិច្ចសន្យាសម្បទានបានទុកនូវករណីផ្សេងៗ។ តាមច្បាប់សម្បទានឆ្នាំ២០០៧ មាត្រា៣៨ បានកំណត់នូវការបញ្ចប់កិច្ចសន្យាសម្បទានដូចមានចែងក្នុងកិច្ចសន្យា គឺករណីប្រធានសក្តិ ឬ មានការរំលោភធ្ងន់ធ្ងរដោយស្ថាប័នជាប់កិច្ចសន្យា ឬស្ថាប័នមានសមត្ថកិច្ចដទៃទៀត លើកាតព្វកិច្ចទាក់ទងទៅនឹងគម្រោងសម្បទាន ឬ រំលោភដោយសម្បទានិក។ នៅក្នុងករណីបញ្ចប់កិច្ចសន្យាសម្បទាន មុនពេលកំណត់ដោយសារការរំលោភធ្ងន់ធ្ងរពីសំណាក់សម្បទានិក ស្ថាប័នជាប់កិច្ចសន្យាអាចយល់ព្រមជាមួយស្ថាប័ន ដែលផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដោយដាក់ជំនួស សម្បទានិកដោយបុគ្គលថ្មី ដើម្បីចាត់តាំងធ្វើកិច្ចការតាមកិច្ចសន្យាសម្បទានដែលមានស្រាប់។ ការរំលោភពីសម្បទានិកនេះយើងបានឃើញមកហើយនូវគម្រោងសម្បទានថែទាំ និងសេវាកម្មលើផ្លូវជាតិលេខ៤ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសលុបចោលកិច្ចសន្យាសម្បទាននេះនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ដោយដាក់ផ្លូវនេះមកក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋវិញ។

ដំណាក់កាលបញ្ចប់គម្រោង ប្រសិនបើកិច្ចសន្យាសម្បទានតម្រូវឲ្យសម្បទានិកផ្ទេរ នៅពេលបញ្ចប់គម្រោងសម្បទាននូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធជូនដល់ស្ថាប័នជាប់កិច្ចសន្យា ឬ អ្នកដែលបានតែងតាំងការផ្ទេរនោះត្រូវស្របទៅនឹងពេលវេលាដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។ សំណង់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវផ្ទេរត្រូវមានលក្ខណៈល្អ ស្របទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន និងត្រូវបានជម្រះឲ្យជ្រះស្រឡះ

នូវរាល់បំណុល បន្ទុក សិទ្ធិប្រាតិភោគ និងការតវ៉ាទាមទារនានានៃគម្រោង។ នៅពេលបញ្ចប់កិច្ចសន្យាសម្បទាន សម្បទានិកត្រូវផ្តល់នូវការបណ្តុះបណ្តាលជូនមន្ត្រី ឬ ប្រជាពលរដ្ឋកម្ពុជា ដើម្បីអ្នកទាំងនោះអាចទទួលរ៉ាប់រងជំនួសនៅគ្រប់កម្រិត ក្នុងការធ្វើអាជីវកម្ម និងថែទាំសំណង់ហេដ្ឋារចនាសម្ព័ន្ធនោះបន្ត។ កិច្ចការទាំងនេះត្រូវធ្វើនៅមុនពេលផុតកំណត់នៃរយៈពេលសម្បទាន ស្របទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងនៅក្នុងកិច្ចសន្យាសម្បទាន។ កិច្ចសន្យាសម្បទានក៏អាចពន្យារពេលបានក្នុងលទ្ធផលដែលចេញមកពីស្ថានភាពៈ

- ពន្យារដើម្បីបង្វើយការងារ ឬ ការបង្អាក់ដំណើរការដោយមូលហេតុនៃការរំលោភកិច្ចសន្យាដោយស្ថាប័នជាប់កិច្ចសន្យា ឬដោយទង្វើនៃស្ថាប័នមានសមត្ថកិច្ចដទៃទៀត។

- ពន្យារដើម្បីបង្វើយការងារ ឬការបង្អាក់ដំណើរការដោយហេតុការប្រធានសក្តិ ដូចដែលមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ហើយដែលនាំឲ្យសម្បទានិកមិនអាចមានលទ្ធភាពបំពេញបានមកវិញនូវការចំណាយ ឬ ការខូចបង់ដែលបានបណ្តាលមកពីស្ថានភាពខាងលើរួមទាំងការធានារ៉ាប់រងលើគម្រោងសម្រាប់រយៈពេលសម្បទានដំបូង។ រយៈពេលសម្បទានដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទានអាចត្រូវបន្តបាន ដើម្បីអនុញ្ញាតឲ្យសម្បទានិក អាចស្តារចំណាយបន្ថែមដែលកើតឡើងដោយសារមានលក្ខខណ្ឌថ្មីៗរបស់ស្ថាប័នជាប់កិច្ចសន្យា ដែលពុំបានគិតទុកជាមុននៅក្នុងកិច្ចសន្យាសម្បទាន ប្រសិនបើសម្បទានិកពុំអាចស្តារឡើងវិញបាន នូវចំណាយក្នុងរយៈពេលធ្វើសម្បទានដែលបានចែង។

## ២.៤ គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលមាននៅកម្ពុជា

### ២.៤.១ គម្រោងដែលធ្លាប់មានពីមុន

ស្ថិតក្រោមក្របខ័ណ្ឌច្បាប់សម្បទាន ប្រទេសកម្ពុជាបានប្រគល់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនធំៗចំនួន ០៣ គម្រោងដែលគម្រោងនេះទទួលបានភាពជោគជ័យគួជាទីពេញចិត្ត។ គម្រោងទាំងអស់នេះត្រូវបានស្នើឡើងដោយវិស័យឯកជនមកក្រសួង ស្ថាប័នរដ្ឋ ហើយរដ្ឋាភិបាលបានសម្រេចផ្តល់សម្បទានឲ្យទៅក្រុមហ៊ុនដែលធ្វើសំណើដោយអនុវត្តតាមយន្តការ PPP។

#### ២.៤.១.១ គម្រោងផ្លូវថ្នល់

គម្រោងផ្លូវថ្នល់ក៏ជាផ្នែកមួយនៃគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនផងដែរ គម្រោងប្រភេទនេះបានអនុវត្តយ៉ាងទូលំទូលាយជាច្រើនឆ្នាំមកហើយនៅអាស៊ី។ គម្រោងផ្លូវថ្នល់ដែលមាន ជាប្រភេទគម្រោងដឹកជញ្ជូន ត្រូវបានរដ្ឋាភិបាលកម្ពុជាបានផ្តល់ជាសម្បទានឲ្យក្រុមហ៊ុនឯកជនមួយឈ្មោះក្រុមហ៊ុន អេ.ហ្សិតឌីស្រ្ទីប្យូហ្សិន (AZ Distribution Co.) នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១ សម្រាប់ការថែទាំ និងសេវាកម្មលើផ្លូវជាតិលេខ៤។ សម្រាប់ការសម្បទាននេះ គឺធ្វើឡើងតាមទម្រង់ **"ថែទាំ-ប្រតិបត្តិការ-ផ្ទេរ"**

ដោយក្រុមហ៊ុនត្រូវផ្តល់សេវាកម្ម និងថែទាំផ្លូវជាតិលេខ៤ នឹងជាថ្នូរនៃការថែទាំនេះរដ្ឋាភិបាលផ្តល់សិទ្ធ ឲ្យក្រុមហ៊ុនគិតថ្លៃសេវាពីប្រជាពលរដ្ឋ ឬអ្នកដែលបានប្រើប្រាស់ផ្លូវជាតិលេខ៤។ ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាអ្នកដែលធ្លាប់បានប្រើប្រាស់ផ្លូវជាតិលេខ៤ គឺពិតជាបានឃើញនិងស្តាប់ឮពីការយកថ្លៃសេវា ក្នុងការធ្វើដំណើរលើផ្លូវជាតិលេខ៤ ពីក្រុមហ៊ុនខាងលើនេះ។ កិច្ចសន្យាសម្បទានលើផ្លូវជាតិលេខ៤ ត្រូវបានលុបចោលចាប់ពីម៉ោង១២:០០ នាទីយប់ថ្ងៃទី១៣ ឈានចូលថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដោយប្រមុខរាជរដ្ឋាភិបាល កម្ពុជាក្នុងកិច្ចប្រជុំសភានាព្រឹកទី១៣ ខែមករា ឆ្នាំ២០១៦ ដោយមានការស្នើសុំ និងការមិនពេញចិត្តពីប្រជាពលរដ្ឋខ្មែរ ទាក់ទងការយកសេវាពីការប្រើប្រាស់ផ្លូវនេះ និងមួយទៀតគឺមកពីខាងក្រុមហ៊ុនអនុវត្តល្មើសនឹងការណែនាំរបស់រាជរដ្ឋាភិបាល។ ផលប្រយោជន៍នៃគម្រោងសម្បទាននេះធ្វើឲ្យផ្លូវជាតិលេខ៤ ស្អាតមានស្តង់ដារធ្វើឲ្យប្រជាពលរដ្ឋងាយស្រួលធ្វើដំណើរទៅមក និងជាពិសេសបម្រើឲ្យការដឹកជញ្ជូនទំនិញពីភ្នំពេញទៅក្រុងព្រះសីហនុឆាប់រហ័ស។

### ២.៤.១.២ គម្រោងផ្នែកថាមពល

លើមាត្រដ្ឋានដ៏ធំអ្នកផលិតថាមពលឯករាជ្យ (IPP) គឺកំពុងផ្គត់ផ្គង់អគ្គីសនីដល់ អគ្គិសនីកម្ពុជា (EDC) ស្ថិតនៅក្រោមកិច្ចព្រមព្រៀងទិញថាមពល (PPA) ដើម្បីបំពេញតាមតម្រូវការផ្គត់ផ្គង់ថាមពល។ គម្រោងភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈទាំងនេះ គឺរាប់បញ្ចូលទាំងការ ដាំដុះរុក្ខជាតិដែលមានឥទ្ធិពលដោយប្រើប្រាស់ទឹកដូចជាគម្រោងដោយប្រើប្រាស់ទឹកនៅកំចាយ (១៩៤ មេហ្គាវ៉ាត់) និងគម្រោងវារីអគ្គីសនី នៅស្ទឹងឬស្សីជ្រុំ (៣៣៨ មេហ្គាវ៉ាត់) ក៏ដូចជាស្ថានីយថាមពលដើរដោយចំហេះធ្យូងថ្ម (១០០ មេហ្គាវ៉ាត់) រោងចក្រថាមពលដើរដោយចំហេះធ្យូងថ្ម នៅខេត្តព្រះសីហនុ របស់ក្រុមហ៊ុន (Cambodia Energy Limited)។

គម្រោងខាងលើកើតឡើង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឲ្យប្រជាពលរដ្ឋកម្ពុជាទទួលបានអគ្គិសនីប្រើប្រាស់គ្រប់ៗគ្នានិងក៏កើតឡើង នៃគោលបំណងរបស់អគ្គីសនីកម្ពុ-ជា (EDC) គឺផ្តល់សេវាកម្មអគ្គីសនីអោយបាន ១០០% (ភាគរយ) នៅគ្រប់ភូមិទាំងអស់ក្នុងអំឡុងឆ្នាំ ២០២០ និងអោយបាន ៧០% (ភាគរយ) ទៅគ្រប់ផ្ទះនៅតំបន់ជនបទទាំងអស់នៅឆ្នាំ ២០៣០ និងការដាំបង្គោលរុក្ខជាតិចំនួន៨ ដើម ដែលដាំដោយប្រើប្រាស់ថាមពលវារី និងដោយការដុតធ្យូងថ្ម នឹងត្រូវបានបញ្ចប់ដោយស្ថាពរនៅឆ្នាំ២០២០ រួមបញ្ចូលទាំងការនាំចូលថាមពលអគ្គិសនីប្រហែល ៣,៥៧៦ មេហ្គាវ៉ាត់ ជាអតិប្បរមានឹងត្រូវកើនឡើងបន្ថែមទៀតនៅឆ្នាំ ២០២០។

### ២.៤.១.៣ សម្បទានក្រុមហ៊ុន

ក្រោមកិច្ចសម្បទានរយៈពេលវែង ក្រុមហ៊ុនឯកជនមួយគឺ Cambodia Airport ដែលគ្រប់គ្រងអាកាសយានដ្ឋាន ចំនួន៣ កន្លែងនៅប្រទេសកម្ពុជា។ មួយកន្លែងនៅរាជធានីភ្នំពេញ មួយកន្លែងទៀត

នៅទីក្រុងសៀមរាបក្បែរប្រាសាទអង្គរវត្ត និងកន្លែងទីបីនៅរមនីយដ្ឋានឆ្នេរសមុទ្រ ក្រុងព្រះសីហនុ។ សមិទ្ធិផលនៃកិច្ចសម្បទាន គឺអ្នកដំណើរចំនួន ៥.១ លាននាក់៖ នេះជាកំណត់ត្រាអំពីចំនួនអ្នកដំណើរ ដែលដកស្រងចេញពីអាកាសយានដ្ឋានទាំងបីកន្លែងក្នុងឆ្នាំ២០១៣ មានកំណើន ១៨.៦% (ភាគរយ) ក្នុងរយៈពេលត្រឹមតែមួយឆ្នាំ។ ចាប់តាំងពីឆ្នាំ១៩៩៥ មកដល់សព្វថ្ងៃចំនួនអ្នកដំណើរតាមអាកាសយាន ដ្ឋានភ្នំពេញ បានកើនឡើងពី៦ សែននាក់ ទៅ ២.៤ លាននាក់ ក្នុងមួយឆ្នាំខណៈពេលនៅអាកាសយាន ដ្ឋាន ទីក្រុងសៀមរាប បានកើនឡើងពី ២ សែននាក់ ទៅ២.៧ លាននាក់។[23] ទឹកប្រាក់ចំនួន១៨០ លាន ដុល្លានឹងត្រូវវិនិយោគនៅភ្នំពេញ និងសៀមរាបគិតពីពេលបច្ចុប្បន្ន និងឆ្នាំ២០១៥ ដើម្បីផ្តល់អោយ អាកាសយានដ្ឋាននីមួយៗនូវស្ថានីយ៍ អន្តរជាតិថ្មីមួយ ដែលនឹងបង្កើនការដឹកជញ្ជូនអ្នកដំណើរទ្វេដង។ អាកាសយានដ្ឋានក្រុងព្រះសីហនុ គឺជាគោលដៅកម្មវិធីវិនិយោគក្នុងទឹកប្រាក់ ២០០ លានដុល្លាដើម្បី សាងសង់ស្ថានីយ៍ និងកន្លែងរង់ចាំថ្មីមួយ ដែលនឹងបញ្ចប់នៅក្នុងឆ្នាំ២០២៥។

សូមបញ្ជាក់ថា ក្រុមហ៊ុន Cambodia Airport បានវិនិយោគទឹកប្រាក់ចំនួន២០០ លានដុល្លា តាំង ពីឆ្នាំ១៩៩៥ ដើម្បីនាំអោយអាកាសយានដ្ឋានទាំងបី ឈានដល់ស្តង់ដាអន្តរជាតិ និងតម្រូវការដែលអ្នក ដំណើរចង់បាន។

### ២.៤.២ គម្រោងដែលមានក្នុងពេលបច្ចុប្បន្ន

ចាប់តាំងពីមានឯកសារគោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ មករាជរដ្ឋាភិបាលកម្ពុជាបានបន្ថែមការ ខិតខំទាក់ទាញនិងកៀងគរវិស័យឯកជនឲ្យមកវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជា យ៉ាងពេញទំហឹង ក្នុងគោលបំណងបំពេញតម្រូវការរបស់សង្គម និងសេដ្ឋកិច្ចប្រទេសកម្ពុជាដែលកំពុង រីកចម្រើនគ្រប់វិស័យ ជាពិសេសដើម្បីផ្តល់ជូននូវ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈបែបទំនើបដល់ប្រជា ពលរដ្ឋកម្ពុជា។ ក្នុងដំណាក់កាលអនុវត្តនេះមានគម្រោង PPP មួយចំនួនបានលេចរូបរាងឡើងដូចជា៖ គម្រោងផ្លូវរថភ្លើងល្បឿនលឿន ភ្នំពេញ-សៀមរាប-ប៉ោយប៉ែត និងភ្នំពេញ-បាវិត របស់ក្រសួង សាធារណការ និងដឹកជញ្ជូនបានសិក្សារួចហើយ រង់ចាំតែវិស័យឯកជនចូលមកវិនិយោគតែប៉ុណ្ណោះ ហើយក្រសួងក៏បានបញ្ជាក់ផងដែរថាគម្រោងនេះនឹងដាក់ឲ្យអនុវត្តតាមទម្រង់ “BOT”។[24] បន្ថែមពី គម្រោងដែលកំពុងរង់ចាំវិស័យឯកជនមកវិនិយោគខាងលើនេះ ក៏មានគម្រោងដែលវិស័យឯកជនចាប់ អារម្មណ៍និងបានបណ្តាក់ទុនផងដែរគឺ គម្រោងសាងសង់ប្រតិបត្តិការ និងធ្វើអាជីវកម្មផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុតាមរូបភាព សាងសង់-អាជីវកម្ម-ផ្ទេរ “ BOT ” ដែលវិនិយោគដោយក្រុមហ៊ុន

[23] www.ppp.mef.gov.kh

[24] ចុះផ្សាយដោយ សារពត៌មាន Fresh News & www. Khmerload.com

“CAMBODIAN PPSHV EXPRESSWAY CO., LTD” មានទុនវិនិយោគប្រមាណ១,៨៧ ប៊ីលានដុល្លាអាមេរិក និងបង្កើតការងារបាន៩.៥១៥ កន្លែង។[25] និងមានគម្រោងធំមួយទៀត ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានបញ្ចេញគឺគម្រោងសាងសង់យន្តហោះថ្មីមួយនៅ ខេត្តកណ្ដាលដែលគម្រោងសាងសង់អាកាសយានដ្ឋានថ្មីមួយនេះមានទឹកប្រាក់ជាង១ ពាន់លានដុល្លា ដោយការចុះហត្ថលេខាវិនិយោគរួមគ្នារវាងតំណាងក្រុមហ៊ុនវិនិយោគកម្ពុជា និងក្រុមហ៊ុនចិន។ ក្នុងចំណោមទឹកប្រាក់វិនិយោគនោះ មួយភាគធំគឺជាកម្ចីពីធានាគារចិន (China Development Bank) និងមួយផ្នែកតូចគឺជារបស់ក្រុមហ៊ុន អូស៊ីអាយស៊ី (OCIC) របស់លោកឧញ្ញ៉ា **ពុង ឃាវសែ**។ ដើម្បីអនុវត្តគម្រោងនេះរាជរដ្ឋាភិបាលកម្ពុជាបានឯកភាពបង្កើតឲ្យមានក្រុមហ៊ុន ខេមបូឌា អ៊ែរផត អ៊ិនធិវេសមិនខូអិលធីឌី (Cambodia Airport Investment Co., Ltd) ដើម្បីសាងសង់អាកាសយានដ្ឋានថ្មីនេះ លើផ្ទៃដីពីពាន់ប្រាំមួយរយហិកតា (២,៦០០)ដែលមានទីតាំងស្ថិតនៅក្នុងក្រុងតាខ្មៅ និងស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ គម្រោងខ្នាតធំមួយនេះ មានទុនវិនិយោគ១,៥០០ លានដុល្លាអាមេរិក ក្នុងនោះ១,១០០ លាន គឺជាកម្ចីពីធានាគារចិន ២៨០ លានដុល្លា គឺជាកម្ចីពីភាគទុនក្រុមហ៊ុន អូស៊ីអាយស៊ី និង១២០ លានដុល្លាទៀតជាដើមទុនចុះបញ្ជី ដែល៩០% (ភាគរយ) ជារបស់ក្រុមហ៊ុនអូស៊ីអាយស៊ី និង១០% (ភាគរយ) ជារបស់រាជរដ្ឋាភិបាលកម្ពុជា។ អាកាសយានដ្ឋានថ្មីនេះជាប្រភេទ 4F នឹងអាចអនុញ្ញាតឲ្យយន្តហោះ ហោះឆ្លងទ្វីបចុះចតបានដូចជា Airbus, A380-800 ,Boeing747-800។[26] ក្នុងដំណាក់កាលដំបូងនៃការអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាវិស័យអាទិភាពដោយទុកវិស័យផ្សេងៗទៀតឲ្យអនុវត្តតាម គម្រោងសាធារណៈធម្មតាពីព្រោះកម្ពុជាត្រូវការវិស័យហេដ្ឋារចនាសម្ព័ន្ធខ្លាំងណាស់ដើម្បីជម្រុញការអភិវឌ្ឍន៍ប្រទេស។ ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដូច្នោះវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈដើរតួនាទីយ៉ាងសំខាន់ និងជាសរសៃឈាមនៃប្រទេសជាពិសេសវិស័យដឹកជញ្ជូនទាំងផ្លូវទឹក, ផ្លូវគោក និងផ្លូវអាកាស ហេតុដូចនេះហើយទើបបច្ចុប្បន្នគម្រោង ដែលរាជរដ្ឋាភិបាលបានផ្សព្វផ្សាយ និងដាក់ឲ្យវិស័យឯកជនវិនិយោគភាគច្រើនជាវិស័យដឹកជញ្ជូន។ បន្ថែមពីគម្រោងដែលលេចចេញជារូបរាងខាងលើនេះក៏មានគម្រោង PPP មួយដែលកំពុងតែធ្វើការសិក្សាសមិទ្ធិលទ្ធភាពដាក់ឲ្យឯកជនវិនិយោគ គឺគម្រោងសាងសង់កំពង់ផែក្រុងព្រះសីហនុ ដែលគម្រោងនេះរដ្ឋ និងធ្វើការអនុវត្តសាកល្បងយកបទពិសោធន៍ដើម្បីឈានទៅយកគម្រោងវិនិយោគសាធារណៈដ៏ទៃទៀតមកអនុវត្តតាមយន្តការ PPP មានប្រសិទ្ធភាព។[27]

---

[25] ផែកFacebook ផ្លូវការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (១៩.០៦.២០១៨)

[26] ចុះផ្សាយដោយ Fresh News TV (05/February/2018) & វិទ្យុអាស៊ីសេរី RFA (2018-01-17)

[27] បង្ហាញដោយលោក សំ វង្សី ប្រធានអង្គភាពPPPថ្នាក់កណ្ដាល

# ជំពូកទី៣
# វិចារណកម្ម គោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនកម្ពុជា

ច្បាប់ បទប្បញ្ញត្តិ ឬ គោលនយោបាយដែលបង្កើតឡើងមកតែងតែមានចំណុចវិជ្ជមាន និងអវិជ្ជមានដល់សង្គមជាតិទាំងក្នុងបច្ចុប្បន្ន និងអនាគតហើយរាល់ចំណុចអវិជ្ជមាន រដ្ឋក៏ដូចជាសង្គមទាំងមូលនឹងស្វែងរកដំណោះស្រាយ ដើម្បីដោះស្រាយចំណុចអវិជ្ជមានទាំងនោះឲ្យមានស្ថានភាពល្អប្រសើរ និងអនុវត្តបានជោគជ័យ។ ជាក់ស្តែងគោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ:២០១៦-២០២០ បង្កើតឡើងមកមានទាំងចំណុចខ្លាំង និងចំណុចខ្សោយ ប៉ុន្តែរាល់ចំណុចខ្សោយ ឬចំណុចអវិជ្ជមាន រាជរដ្ឋាភិបាលកម្ពុជាបានកំពុងរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយ ដើម្បីឲ្យគោលនយោបាយនេះទទួលបានជោគជ័យក្នុងការអនុវត្ត។ ខាងក្រោមនេះនិងបង្ហាញចំណុចខ្លាំងនិងចំណុចខ្សោយនៃគោលនយោបាយ PPP ព្រមនិងដំណោះស្រាយដែលរាជរដ្ឋាភិបាល ព្រមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញឲ្យការអនុវត្តគោលនយោបាយទទួលបានជោគជ័យ និងធានាថាគោលនយោបាយ ដាក់ចេញមកបម្រើផលប្រយោជន៍សង្គម និងសេដ្ឋកិច្ចជាតិ ជាពិសេសតម្រូវការជាក់ស្តែងរបស់សង្គម។

## ៣.១ ចំណុចខ្លាំង

គោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ:២០១៦-២០២០ មានចំណុចខ្លាំងជាច្រើនទាំងគោលនយោបាយ និងទាំងការអនុវត្តដែលធ្វើឲ្យប្រជាពលរដ្ឋ និងសង្គម-សេដ្ឋកិច្ចជាតិទទួលផលពីគោលនយោបាយនេះដែលចំណុចទាំងនោះ រួមមាន៖

- **បន្តជម្រុញ និងលើកកម្ពស់វិស័យឯកជនក្នុងការចូលរួមវិនិយោគសាធារណៈ**

គោលនយោបាយ PPP នេះនិងបន្ថែមការទាក់ទាញវិស័យឯកជនឲ្យមកវិនិយោគវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការ PPP ក្នុងប្រទេសកម្ពុជា ស្របតាមការចង់បានរបស់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣និងផែនការអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥។ គោលនយោបាយនេះនឹងជួយកែលម្អ និងលើកកម្ពស់បរិស្ថានអំណោយផលសម្រាប់បន្តជម្រុញការចូលរួមរបស់វិស័យឯកជន លើវិស័យវិនិយោគសាធារណៈ, បង្កើតជាប្រភពហិរញ្ញប្បទានថ្មី សម្រាប់បំពេញបន្ថែមលើប្រភពទុន វិនិយោគសាធារណៈជាប្រពៃណីរបស់រដ្ឋ និងរួមចំណែកដល់ការពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុរបស់កម្ពុជា។

- **ជាផែនទីបង្ហាញផ្លូវការអភិវឌ្ឍន៍តាមយន្តការ PPP**

អនុលោមតាមច្បាប់វិនិយោគ និងច្បាប់សម្បទាន២០០៧ កម្ពុជាបើកផ្លូវឲ្យវិស័យឯកជនចូលមកគ្រប់គ្រងគម្រោងសម្បទានមួយចំនួនដូចបានបង្ហាញនៅក្នុងចំណុច (២.៤.១) នៃជំពូក ២។

ក្នុងដំណាក់កាលនេះកម្ពុជា អនុវត្តយន្តការចំពោះកិច្ច ដោយមិនស្របតាមឧត្តមានុវត្តជាអន្តរជាតិតាមយន្តការ PPP ដែលសកលលោកកំពុងអនុវត្តនាពេលបច្ចុប្បន្ននោះទេ។ ក្នុងដំណាក់កាលបច្ចុប្បន្ននេះគោលនយោបាយ PPP នឹងធ្វើឲ្យគម្រោងសម្បទានរបស់កម្ពុជា ស្របតាមការអនុវត្តជា សកលដោយគោលនយោបាយ PPP និងបង្ហាញផ្លូវសម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីរាជការអាចកំណត់ពីវិស័យអាទិភាព ដើម្បីយកមកអនុវត្តតាមយន្តការ PPP ព្រមទាំងធ្វើឲ្យវិស័យសាធារណៈសិក្សាគម្រោង និងជ្រើសរើសសម្បទានិក, និងគ្រប់គ្រងគម្រោងសម្បទានប្រកបដោយ តម្លាភាព, ប្រសិទ្ធភាព, គណនេយ្យភាព, ភាពគ្រប់ជ្រុងជ្រោយ និងទទួលបានជោគជ័យ។

❖ **ធ្វើអោយវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាន់សម័យ និងបំពេញតម្រូវការសង្គម**

ការចូលរួមវិនិយោគពីវិស័យឯកជន មិនត្រឹមតែនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែមប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវ ចំណេះដឹង-ចំណោះធ្វើ ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យ សាធារណៈក្នុងការរៀបចំនិងគ្រប់គ្រងប្រតិបត្តិការ គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុនទៀតផង។ ក្នុងន័យនេះវិស័យឯកជននិងនាំមកនូវបច្ចេកវិទ្យាទំនើប នវានុវត្តភាព បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិដែលសង្គមកម្ពុជាកំពុងត្រូវការ។ លើសពីនេះកម្ពុជានឹងទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាន់សម័យពីវិស័យឯកជន។ទាន់សម័យយ៉ាងមិច? ឧទាហរណ៍គម្រោងសម្បទានឲ្យឯកជន គ្រប់គ្រងព្រលានយន្តហោះអន្តរជាតិភ្នំពេញ យើងសង្កេតឃើញថាព្រលានយន្តហោះភ្នំពេញ អ្នកដំណើឆ្លងកាត់ពី មួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ ជាក់ស្តែងគិតរយៈពេល៩ខែក្នុងឆ្នាំ២០១៧ អ្នកដំណើជាង៣,០០០,០០០ នាក់បានឆ្លងកាត់ព្រលានយន្តហោះអន្តរជាតិភ្នំពេញស្មើនឹង២៤% (ភាគរយ) បើធៀបពីរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។[28] ការកើនឡើងនេះដោយសារភាពទាន់សម័យនៃអាកាសយានដ្ឋានពីលក្ខណៈជាតិមកជាលក្ខណៈអន្តរជាតិ។

❖ **បង្កើតការងារដល់ប្រជាពលរដ្ឋកម្ពុជា និងអាចប្រមូលពន្ធដារបានច្រើន**

យើងដឹងហើយថាគម្រោង PPP មានរយៈពេលយូរ និងប្រើប្រាស់ធានធានច្រើន។ គម្រោងPPP នឹងបង្កើតការងារដល់ប្រជាពលរដ្ឋច្រើននិងយូរអង្វែងដែលអាចឲ្យប្រជាពលរដ្ឋធ្វើការងារបានយូរ និងទទួលបានចំណូលសមរម្យហើយអនុញ្ញាតឲ្យរដ្ឋដកពន្ធលើប្រាក់ចំណូលថែមទៀតផង។ លើសពីនេះ

[28] ចេញផ្សាយដោយ BTVNews ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧

រដ្ឋអាចប្រមូលពន្ធដារបានច្រើន ពីប្រាក់ចំណេញ សួយសារ និងពន្ធលើប្រាក់ចំណូលនៃគម្រោងវិនិយោគនេះ។

- **ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមានភាពទំនើប និងបំពេញតម្រូវការសង្គម**

យន្តការ PPP បានធ្វើឲ្យវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្ពុជាមានភាពទំនើបទាន់សម័យបំពេញតម្រូវការសង្គមដែល និងជម្រុញការអភិវឌ្ឍន៍ដែលរដ្ឋចង់ធ្វើតែមិនមានលទ្ធភាពនឹងធ្វើបាន។ ឧទាហរណ៍៖ សម្បទានឲ្យក្រុមហ៊ុនឯកជនគ្រប់គ្រងព្រលានយន្តហោះភ្នំពេញវិស័យឯកជនបានធ្វើឲ្យព្រលានយន្តហោះភ្នំពេញដែលមានលក្ខណៈជាតិ ទៅជាមានលក្ខណៈអន្តរជាតិនៃសម័យទំនើប។

## ៣.២ ចំណុចខ្សោយ

- **ក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីប្រតិបត្តិការ**

គម្រោង PPP មានលក្ខណៈស្មុគស្មាញ និងត្រូវការធនធានច្រើន ជាពិសេសមានការចែករំលែកហានិភ័យរវាងរដ្ឋ និងឯកជនដូចនេះវាត្រូវការច្បាប់ បទប្បញ្ញត្តិគ្រប់គ្រងនីតិវិធីប្រតិបត្តិការវដ្តគម្រោងច្បាស់លាស់ជាពិសេសកិច្ចលទ្ធកម្ម។ ដូចបានរៀបរាប់ខាងដើមគម្រោង PPP តម្រូវឲ្យមាននីតិវិធីដោយឡែក ពីនីតិវិធីគម្រោងវិនិយោគសាធារណៈទូទៅ ប៉ុន្តែរហូតមកដល់ពេលនេះច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការវដ្តគម្រោង PPP ស្ថិតនូវក្នុងសេចក្តីព្រាងនៅឡើយ។ បញ្ហានេះធ្វើឲ្យអ្នកវិនិយោគទុនមានភាពភ័យខ្លាច និងមានការបារម្មណ៍ ក្នុងការបណ្តាក់ទុនរបស់ខ្លួននិយាយឲ្យចំគឺខ្លាចខាតបង់ដើមទុនវិនិយោគ។ ហេតុផលមួយទៀតនៃការមិនទាន់មាន ក្របខណ្ឌគតិយុត្តច្បាស់លាស់នេះ គឺធ្វើឲ្យការអនុវត្ត និងគ្រប់គ្រងគម្រោង PPP មិនទាន់ស្របតាមយន្តការ PPP ជា អន្តរជាតិនៅឡើយ។

- **សមត្ថភាពជំនាញ និងបច្ចេកទេស**

- ក្រសួងស្ថាប័នជំនាញ ឬតាមវិស័យសមត្ថភាពនូវមានកម្រិតក្នុងការជ្រើសរើសគម្រោងដើម្បីស្នើសុំអនុវត្តតាមយន្តការ PPP ។ ត្រង់ចំណុចនេះក្រសួងស្ថាប័នខ្វះពត៌មាន និងការវិភាគឲ្យបានច្បាស់លាស់នូវតម្រូវការសង្គមជាក់ស្តែង ដែលជាហេតុមិនបំពេញតម្រូវការ ឬបញ្ហាសង្គម។

- សមត្ថភាពក្រសួងស្ថាប័ន ក្នុងការសិក្សាសមិទ្ធិលទ្ធភាពគម្រោងគឺមិនទាន់មានភាពគ្រប់ជ្រុងជ្រោយដែលធ្វើឲ្យគម្រោងបាត់បង់ភាពទាក់ទាញវិស័យឯកជនឲ្យបណ្តាក់ទុន និងធានាគារ ឬស្ថាប័នហិរញ្ញវត្ថុនានាក្នុងការផ្តល់កម្ចីដល់គម្រោង។

- ការវិភាគការសិក្សាសមិទ្ធិភាពគម្រោងរបស់ក្រសួងទទួលបន្ទុកអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជននូវមានកម្រិត។

- ការវិភាគលំហូរសាច់ប្រាក់នៃគម្រោងមិនទាន់ឆ្លើយតបនឹងការវិភាគបែបសេដ្ឋកិច្ច។

- មន្ត្រីស្ថាប័នខ្លះ ក្នុងការគ្រប់គ្រងប្រតិបត្តិការវដ្តគម្រោង PPP គឺមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដែលស្របតាមការអនុវត្តជាសកលនៃយន្តការ PPP នោះទេ ប៉ុន្តែក៏មានស្ថាប័នរដ្ឋមួយចំនួនអាចអនុវត្តបានល្អផងដែរ។

❖ **ហិរញ្ញវត្ថុគាំទ្រគម្រោងPPP**

- ចំពោះមូលនិធិអភិវឌ្ឍន៍គម្រោង (PDF) មានតែគោលនយោបាយប៉ុន្តែឥតមានកញ្ចប់ថវិកាសម្រាប់ដាក់ឲ្យដំណើរការមូលនិធិទេ ដែលជាហេតុធ្វើឲ្យការធ្វើអត្តសញ្ញាណកម្ម និងការសិក្សាសមិទ្ធិលទ្ធភាពមិនទាន់ឆ្លើយតបតម្រូវការជាក់ស្តែង។

- មិនទាន់មានមូលនិធិបំពេញផលហិរញ្ញវត្ថុ (VGF) ជួយដល់គម្រោងPPPដែលត្រូវការធានា ឬឧបត្ថម្ភធនពីរដ្ឋ។

## ៣.៣.ដំណោះស្រាយ

❖ **ក្របខ័ណ្ឌគតិយុត្ត និងនីតិវិធិប្រតិបត្តិការ**

ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ នៃក្របខ័ណ្ឌគតិយុត្តនិងនីតិវិធីប្រតិបត្តិការរាជរដ្ឋាភិបាល-កម្ពុជា រួមជាមួយការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសពីធានាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតឲ្យមានឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ឡើងដើម្បីគ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតមានក្នុងយន្តការ PPP និងជាបទប្បញ្ញត្តិចង្អុលបង្ហាញផ្លូវដល់ក្រសួងស្ថាប័នរដ្ឋក្នុងការបង្កើតច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីដើម្បីគ្រប់គ្រងវដ្តគម្រោង PPP ឲ្យបានរឹងមាំស្របតាមឧត្តមានុវត្តជាអន្តរជាតិនៃយន្តការ PPP ។ ជាពិសេសក្នុងពេលបច្ចុប្បន្ននេះដើម្បីឲ្យគោលនយោបាយ PPPកម្ពុជាស្របតាមយន្តការ PPP ជាអន្តរជាតិក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើសេចក្តីព្រាងនីតិវិធីគ្រប់គ្រងនិងប្រតិបត្តិការគម្រោង PPP ឲ្យស្របតាមការអនុវត្តជាអន្តរជាតិ ហើយបច្ចុប្បន្ននេះសេចក្តីព្រាងនេះបានធ្វើរួចរាល់ហើយរង់ចាំតែការអនុម័តពីថ្នាក់ដឹកនាំកំពូលតែប៉ុណ្ណោះ។[29]

❖ **សមត្ថភាពជំនាញ និងបច្ចេកទេស**

គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការ PPP មានភាពស្មុគស្មាញទាមទារសមត្ថភាពជំនាញនិងបច្ចេកទេសរបស់មន្ត្រីដែលទទួលអនុវត្តមានកម្រិតខ្ពស់និងគ្រប់ជ្រុងជ្រោយ។ ដើម្បីដោះស្រាយបញ្ហាសមត្ថភាពមន្ត្រី រាជរដ្ឋាភិបាលក៏ជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតឲ្យមានផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់គ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ

[29] កិច្ចសម្ភាសជាមួយលោក សំ វង្សី ប្រធានអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល

តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ក្នុងផែនការនេះដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តនូវផែនការសកម្មភាពដូចខាងក្រោម៖

**១. បន្តយកចិត្តទុកដាក់កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន លើមុខជំនាញសំខាន់ៗ ដូចជា៖**

- ការពិនិត្យ និងជ្រើសរើសគម្រោង ( Project Screening/Selection)
- ការកំណត់ចរិតលក្ខណៈនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Defining Project Characteristics)
- ការកំណត់យថាប្រភេទនៃលទ្ធផល( Output Specification)
- ការរៀបចំរចនាសម្ព័ន្ធគម្រោង ( Project Structuring)
- ការរៀបចំកិច្ចសន្យាគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP Contract)
- ការរៀបចំផែនការការគ្រប់គ្រងកិច្ចសន្យា ( Contract Management Plan)
- ការរៀបចំផែនការកិច្ចលទ្ធកម្ម( Procurement Plan) ដោយរួមបញ្ចូលទាំងការរៀបចំឯកសារដេញថ្លៃ និងការវាយតម្លៃសំណើដេញថ្លៃផងដែរ
- ការបែងចែកហានិភ័យក្នុងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ( Risk Allocation)
- ការវិភាគ និងវាយតម្លៃគម្រោងតាមវិធីសាស្ត្រតម្លៃនៃលុយ ( Value for Money)
- ការវិភាគគំរូហិរញ្ញវត្ថុ ( Financial Model for Optimization of Project Life Cycle Cost )
- ការគ្រប់គ្រងហានិភ័យនៃគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP
- ការគណនាកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liability Calculation)
- និងមុខជំនាញពាក់ព័ន្ធផ្សេងទៀត ។

**២. បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖**

- **ការបណ្តុះបណ្តាលក្នុងស្រុក** ដែលរួមមាន៖ ១) ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញដែលបង្ហាត់បង្ហាញដោយជំនាញការអន្តរជាតិ ឬមន្ត្រីស្ថាប័នជំនាញអន្តរជាតិនានា, ២) ការរៀបចំសិក្ខាសាលា ឬវេទិកា ឬសន្និសីទ ដោយមានការចូលរួមពីជំនាញការជាតិ អន្តរជាតិ ឬ មន្ត្រីជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ, និង ៣) ការសិក្សាតាមប្រព័ន្ធអ៊ីនធើណែត។

- **ការបណ្តុះបណ្តាលក្រៅប្រទេស** ដែលរួមមាន៖ ១) ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ ស្ថាប័នក្នុងតំបន់ ឬ អន្តរជាតិនានា, ២) ការចូលរួមសិក្ខាសាលា វេទិកា ឬ សន្និសីទក្នុងតំបន់ ឬអន្តរជាតិ លើប្រធានបទជំនាញពាក់ព័ន្ធ, ៣) ការធ្វើទសន្សកិច្ចសិក្សានៅតាមក្រសួង ស្ថាប័នជំនាញនៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក ។[30]

ទាក់ទងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធ យើងឃើញថាមិនមែនមានតែចែងក្នុងគោលនយោបាយឲ្យល្អមើលនោះទេ ប៉ុន្តែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានរៀបចំធ្វើសិក្ខាសាលា, វេទិកា, សន្និសីទដើម្បីសិក្សាស្វែងយល់អំពីយន្តការ PPPជាច្រើនលើកច្រើនសារ ដោយមានការចូលរួមពីជំនាញការជាតិ និងអន្តរជាតិជាច្រើនចាប់តាំងពីឆ្នាំ២០១៤មកដល់បច្ចុប្បន្ន។ លើសពីនេះក្រសួងសេដ្ឋកិច្ចបានបញ្ជូនមន្ត្រីពាក់ព័ន្ធឲ្យទៅធ្វើទសន្សកិច្ចសិក្សាយន្តការ PPP និងគម្រោងវិនិយោគតាមយន្តការ PPP នៅក្រៅប្រទេសក្នុងតំបន់និងអន្តរជាតិជាច្រើនដង និងច្រើនប្រទេស ជាក់ស្តែងទៅទសន្សកិច្ចនៅសាធារណៈរដ្ឋប្រជាមានិតចិន ។[31]

លើសពីនេះ ដំណោះស្រាយជាក់លាក់នូវបញ្ហាប្រឈមការ ខ្វះពត៌មាន និងការវិភាគតម្រូវការចាំបាច់របស់សង្គមរបស់ក្រសួងស្ថាប័នជំនាញ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈអង្គភាពPPP ថ្នាក់កណ្តាលបានចង្អុលបង្ហាញផ្លូវ និងធ្វើការពន្យល់អំពីការជ្រើសរើសគម្រោងឲ្យត្រូវ នឹងតម្រូវការសង្គម ហើយបដិសេធចោលនូវគម្រោង ដែលស្នើមកមិនឆ្លើយតបតម្រូវការសង្គមជាក់ស្តែង។ ត្រង់ចំណុចការសិក្សាសមិទ្ធិលទ្ធភាពគម្រោងក្រសួងស្ថាប័នជំនាញគាត់អាចជួលទីប្រឹក្សា ឬអ្នកជំនាញការមកជួយសិក្សាសមិទ្ធិលទ្ធភាពគម្រោង ដែលក្រសួងស្ថាប័នមិនមានសមត្ថភាពធ្វើ ឬអាចទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ដើម្បីមកជួយសិក្សាគម្រោងបន្ថែមផងដែរ។ ទាក់ទងនឹងការវិភាគលំហូរសាច់ប្រាក់ និងការវិភាគការសិក្សាសមិទ្ធិលទ្ធភាពគម្រោងគឺបច្ចុប្បន្នក្រសួងសេដ្ឋកិច្ចមានមន្ត្រីជំនាញ និងមានអមដោយទីប្រឹក្សា ឬជំនាញការដើម្បីឲ្យមកបង្ហាញផ្លូវនិងជួយវិភាគ និយាយអោយចំគឺមន្ត្រីកំពុងតែ "**រៀនផង-ធ្វើផង**" ចំពោះគម្រោងPPP។ សរុបមក រាល់បញ្ហាប្រឈមនៃសមត្ថភាព និងបច្ចេកទេសមន្ត្រីរាជរដ្ឋាភិបាលអនុញ្ញាតអោយ ក្រសួងស្ថាប័នជួលអ្នកជំនាញការ ឬទាក់ទងសុំជំនួយពីដៃគូអភិវឌ្ឍន៍នានាដើម្បីជួយជ្រុំជ្រែងផ្តល់បច្ចេកទេស។

❖ **ហិរញ្ញវត្ថុគាំទ្រគម្រោង PPP**

[30] ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តកាPPPសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០

[31] www.ppp.mef.gov.kh & www.mef.gov.kh និងវេបសាយស្ថាប័នក្រោមឪវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ចំពោះមូលនិធិអភិវឌ្ឍន៍គម្រោង រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងកៀគរថវិកាពីដៃគូអភិវឌ្ឍន៍ ឬត្រៀមថវិកាជាតិមួយចំនួនដើម្បីដាក់ឲ្យដំណើការមូលនិធិនេះ។

- ចំពោះមូលនិធិបំពេញផលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងរៀបចំក្របខណ្ឌច្បាប់ និងថវិកាដើម្បីដាក់ឲ្យដំណើការនៅពេលណាប្រទេសកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការគាំទ្រឬឧបត្ថមធនដល់គម្រោង PPP ដែលអ្នកប្រើប្រាស់មិនមានលទ្ធភាពបង់។ ហើយពេលបច្ចុប្បន្ននេះកម្ពុជានឹងដាក់តែគម្រោងណាដែលវិស័យឯកជនអាចប្រមូលថ្លៃសេវាពីអ្នកប្រើប្រាស់ឲ្យតែប៉ុណ្ណោះ លើកលែងតែវិស័យអគ្គិសនីដែលជាវិស័យអាទិភាពខ្ពស់។[32]

[32] កិច្ចសម្ភាសជាមួយលោក **សំ វង្សី** ប្រធានអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល

# សេចក្តីសន្និដ្ឋាន

យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺជាយន្តការមួយដែលសកលលោកកំពុងតែប្រើប្រាស់ដ៏ពេញនិយមនាសតវត្សន៍ទី២១ ជាពិសេសប៉ុន្មានឆ្នាំចុងក្រោយនេះ ពីព្រោះយន្តការនេះជាយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មីដែលបំពេញបន្ថែមចំពោះកង្វះហិរញ្ញប្បទាន សម្រាប់ការវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, កាត់បន្ថយសម្ពាធលើថវិកាជាតិ និងសម្រាលបន្ទុកសេវាបំណុលសាធារណៈព្រមទាំងផ្តល់ឪកាសអភិវឌ្ឍ និងផ្ទេរចំណេះដឹង-ចំណេះធ្វើ, បច្ចេកវិទ្យាទំនើប, ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ព្រមទាំងនវានុវត្តភាពដល់វិស័យសាធារណៈទៀតផង។ យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានយកទៅអនុវត្តក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការទំហំទុនធំ និងមានរយៈពេលវែង ពីព្រោះយន្តការនេះមានភាពស្មុគស្មាញ និងប្រើប្រាស់ធនធានច្រើន។ ភាគច្រើនគម្រោង PPP គឺអនុវត្តលើវិស័យដូចជាៈ ផ្លូវថ្នល់, ផ្លូវរថភ្លើង, ទឹក, ថាមពល, អាកាសយានដ្ឋាន, អប់រំ, សុខាភិបាលនិងវិស័យមួយចំនួនទៀតផងដែរ។ យើងអាចយល់ដឹងបានថាគម្រោងណាមួយជាគម្រោង PPP គឺយើងមើលទៅលើរយៈពេលនៃកិច្ចសន្យាគឺចាប់ពី ២០-៣០ ឬច្រើនជាងនេះ ឬទម្រង់សម្បទានដែលរដ្ឋបានផ្តល់ទៅឲ្យឯកជនធ្វើ (ឧទាហរណ៍: BOT, BOOT, BOO...), នីតិវិធីគ្រប់គ្រង និងប្រតិបត្តិការវដ្តគម្រោងវិនិយោគ។ យន្តការ PPP បានចាប់កំណើតនៅអឺរ៉ុបខាងលិចតាំងពីដើមឆ្នាំ១៨៣៨ ជាពិសេសការចូលរួមយ៉ាងទូលំទូលាយនៃដើមទុនឯកជននៅក្នុងការវិនិយោគសាធារណៈ បានរកឃើញការប្រើប្រាស់ជាទូទៅក្នុងកំឡុងពេលចាប់ពីសតវត្សទីដប់ប្រាំពីរ ដល់ចុងសតវត្សទីដប់ប្រាំបួននៅពេលដែលការកសាងហេដ្ឋារចនាសម្ព័ន្ធ ( បណ្តាញទឹក, ផ្លូវថ្នល់ និងផ្លូវដែក) នៅទ្វីបអឺរ៉ុបនិងក្រោយមកនៅអាមេរិក, ចិន និងជប៉ុនត្រូវបានផ្តល់មូលនិធិដោយប្រភពឯកជនក្រោមកិច្ចសន្យាសម្បទាន។ នៅឆ្នាំ២០១៤ យន្តការ PPP បានបង្ហាញខ្លួន ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងសកលលោកក្រោមការផ្តួចផ្តើមដោយដៃគូអភិវឌ្ឍន៍ពហុភាគីសំខាន់ៗ ដោយបានបង្ហាញការប្តេជ្ញាចិត្តខ្ពស់ក្នុងការជួយអភិវឌ្ឍន៍យន្តការ PPP សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដល់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងក្នុងក្របខ័ណ្ឌបច្ចេកទេសនិងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ ក្នុងនោះដៃគូអភិវឌ្ឍន៍ក៏បានជួយជម្រុញប្រទេសកម្ពុជាឲ្យទទួលអនុវត្តយន្តការ PPP ផងដែរ។ ស្ថាប័នសំខាន់ៗក្នុងការផ្តួចផ្តើមយន្តការ PPP មាន WB, ADB, UNESCAP និងIMF ចំណែកប្រទេសដែលអនុវត្តយន្តការ PPPទទួលបានជោគជ័យដែលប្រទេសកំពុងអភិវឌ្ឍន៍គួរយកគំរូតាមមានប្រទេសក្នុងទ្វីបអឺរ៉ុប,ចិន,ឥណ្ឌា និងប្រទេសក្បែរខាងកម្ពុជាដូចជាប្រទេសថៃជាដើម។ គម្រោងវិនិយោគតាមយន្តការ PPP មានច្រើនទម្រង់នឹងមានរូបរាងអាស្រ័យនឹងច្បាប់ ឬស្ថានភាពរបស់ប្រទេសដែលទទួលយកយន្តការ PPP មកអនុវត្ត ប៉ុន្តែស្ថិតក្នុងន័យសម្បទានទាំងអស់។ ដើម្បីឲ្យគម្រោង PPP ទទួលបានជោគជ័យរដ្ឋដែលយកយន្តការ PPP មកអនុវត្តត្រូវតែបង្កើតគោល

នយោបាយ PPP ស្របទៅនឹងគោលនយោបាយ PPP ជាអន្តរជាតិ ។ ការអនុវត្តជាអន្តរជាតិទាមទារឲ្យមានក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, យន្តការគាំទ្រហិរញ្ញវត្ថុ, ព្រមទាំងវិធាន,នីតិវិធីប្រតិបត្តិការ, គោលការណ៍ណែនាំប្រកបដោយភាពរឹងមាំ,ច្បាស់លាស់, ប្រយ័ត្នប្រយែងខ្ពស់ និងគ្រប់ជ្រុងជ្រោយក្នុងការរៀបចំគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ។

សម្រាប់គោលនយោបាយ PPP របស់កម្ពុជាគឺកំពុងអភិវឌ្ឍន៍ខ្លួនឲ្យស្របទៅនឹងការអនុវត្តជាសកលនៃយន្តការ PPP ដោយពេលនេះកម្ពុជាកំពុងតែដុតដៃដុតជើងរៀបចំនីតិវិធី, ច្បាប់, បទប្បញ្ញត្តិដើម្បីគាំទ្រយន្តការ PPP អោយអនុវត្តទៅរលូន និងទទួលបានជោគជ័យដូចបណ្តាប្រទេស លើសកលលោក។ ហើយក្នុងដំណាក់កាលបច្ចុប្បន្នកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាល "រៀនផង-ធ្វើផង" នៃយន្តការ និងគម្រោង PPP ដោយកម្ពុជានូវតែបន្តអនុវត្តយន្តការចំពោះកិច្ចសម្រាប់គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការ PPP ឬគម្រោងសម្បទានស្របទៅនឹងច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងយន្តការ PPP ជាធរមាន និងធ្វើឲ្យស្របតាមការអនុវត្តជាអន្តរជាតិ។ ក្នុងការធ្វើឲ្យស្របតាមការអនុវត្តជាអន្តរជាតិ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រសួងទទួលបន្ទុកដឹកនាំការអនុវត្តនាំមុខនិងក្រសួងស្ថាប័នជំនាញជួលទីប្រឹក្សា ឬអ្នកជំនាញមកចង្អុលបង្ហាញ ឬធ្វើការអមមន្ត្រីដែលទទួលបន្ទុកយន្តការឬគម្រោង PPP។ ទោះបីក្នុងដំណាក់កាលកំពុងកសាងច្បាប់ បទប្បញ្ញត្តិ PPP ប៉ុន្តែកម្ពុជាបានដាក់ឲ្យអនុវត្តគម្រោងPPPធំៗ ដូចបានបង្ហាញក្នុងចំណុច(២.៤.២) នៃជំពូកទី២រួចមកហើយ ដែលនេះស្តែងបង្ហាញថាក្រសួងស្ថាប័នសាធារណៈមានសមត្ថភាពអាចអនុវត្តគម្រោង PPP ធំៗបាន។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវលើប្រធានបទ " **ភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងគម្រោងវិនិយោគសាធារណៈកម្ពុជា** " អស់មួយរយៈពេលកន្លងមកយើងឃើញថាគោលនយោបាយអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈកម្ពុជាមានភាពល្អប្រសើរជាច្រើនក្នុងការជម្រុញ និងទាក់ទាញវិស័យឯកជនឲ្យមកវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការPPP។ ទន្ទឹមនេះក៏មានបញ្ហាមួយចំនួនធ្វើឲ្យរាំងស្ទះដល់ដំណើការអនុវត្តយន្តការ PPP និងធ្វើឲ្យគម្រោង PPP របស់កម្ពុជាបាត់បង់ភាពទាក់ទាញវិស័យឯកជន។ ហើយដើម្បីដោះស្រាយនូវបញ្ហារាំងស្ទះ និងចូលរួមចំណែកធ្វើឲ្យការអនុវត្តយន្តការ PPP ទៅដោយរលូនព្រមទាំងទទួលបានជោគជ័យ ក្រុមយើងខ្ញុំមានជាអនុសាសន៍មួយចំនួនដើម្បីចូលរួមកែលម្អក្នុងការអនុវត្ត។

គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនមានរយៈពេលវែង និងត្រូវការដើមទុនច្រើនដូចនេះគឺត្រូវការច្បាប់គាំទ្ររឹងមាំ និងមិនអាចកែប្រែតាមតែចិត្តរបស់វិស័យសាធារណៈចង់បាន។ ត្រង់ចំណុចនេះគឺរាជរដ្ឋាភិបាលគួតែបង្កើតច្បាប់ពិសេសមួយដើម្បីការពារដល់គម្រោង PPP ការពារនៅពេលមានការប្តូររាជរដ្ឋាភិបាល ឬផ្លាស់អ្នកដឹកនាំ ហេតុផលនេះធ្វើឲ្យវិស័យឯកជនជឿទុកចិត្តក្នុងការវិនិយោគរបស់ខ្លួនថាមិនមានការខាតបង់។

រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែតែពង្រឹងស្ថានភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានស្ថេរភាព និងកាន់តែល្អប្រសើរជាងពេលបច្ចុប្បន្ន ដើម្បីទាក់ទាញវិនិយោគទុនពីបរទេសមកធ្វើការវិនិយោគនៅកម្ពុជា និងធ្វើឲ្យវិនិយោគទុនទាំងនោះមានការទុកចិត្តថា លុយដ៏ច្រើនរបស់ពួកគេដែលបានបណ្តាក់ទុន នឹងមិនត្រូវទទួលរងហានិភ័យពីស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជានោះឡើយ។

ធ្វើបច្ចុប្បន្នភាព និងពង្រឹងប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធក្នុងការអនុវត្តយន្តការភាពជាដៃគូ រវាងរដ្ឋនិងឯកជនបន្ថែមទៀត។

ពង្រឹងប្រព័ន្ធយុត្តាធិការ ឲ្យមានភាពឯករាជ្យ ដោយធ្វើការជំរះក្តីដោយអនុលោមទៅតាមច្បាប់ដែលជាធរមាន ប្រកបទៅដោយភាពសុក្រិត្យ និងយុត្តិធម៌ មិនថាវិនិយោគទុនបរទេស ឬ ក្នុងប្រទេសដែលមកចុះកិច្ចសន្យាជាមួយ រដ្ឋាភិបាលកម្ពុជានោះទេត្រូវតែទទួលបានយុត្តិធម៌ដូចគ្នា។

ត្រូវតែលុបបំបាត់អំពើពុករលួយក្នុងវដ្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ពង្រឹង និងបង្កើនធនធានមនុស្សក្នុងវិស័យវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមយន្តការភាពជាដៃគូរវងរដ្ឋ និងឯកជនឲ្យបានច្រើន និងមានសមត្ថភាព។

កាត់បន្ថយការអនុវត្តយន្តការចំពោះកិច្ច ចំពោះគម្រោងសម្បទាន ឬគម្រោងភាពជាដៃគូ រវាងរដ្ឋ និងឯកជនឲ្យបានជាអតិបរមា។

ពន្លឿនការចេញច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការវដ្តគម្រោងភាពជាដៃគូ រវាងរដ្ឋ និងឯកជន ពីព្រោះការធ្វើបែបនេះធ្វើឲ្យគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់កម្ពុជាមានភាពទាក់ទាញដល់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ។

គួតែបង្កើតវែបសាយមួយដែលធ្វើសារណៈជន, វិស័យឯកជន,ធានាគារឬស្ថាប័នហិរញ្ញវត្ថុអាចយល់ដឹងពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនទាំងបញ្ហាប្រឈមនិងទាំងកាលានុវត្តភាពជាពិសេសឲ្យសាធារណៈជន ឬវិស័យឯកជនអាចមើលឃើញពីទិន្នន័យគម្រោង PPP ក្នុងប្រទេសកម្ពុជា។

និងជាចុងក្រោយបង្កលក្ខណៈងាយស្រួល ដល់វិស័យឯកជនដែលមកវិនិយោគក្នុងប្រទេសកម្ពុជាទាំងក្របខណ្ឌច្បាប់ នីតិវិធីរដ្ឋបាល និងជាពិសេសសន្តិសុខផ្ទាល់ខ្លួនរបស់អ្នកវិនិយោគទុន។

# គន្ថនិទ្ទេស


❖ ច្បាប់ និងបទប្បញ្ញត្តិជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៣
- ច្បាប់សម្បទានឆ្នាំ២០០៧
- ឯកសារគោលនយោបាយស្តីពីការអភិឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ:២០១៦-២០២០

❖ ឯកសារគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជនអន្តរជាតិ

- កូនសៀវភៅជាភាសាខ្មែរ ម៉ូឌុលបណ្តុះបណ្តាលយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់គណកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក។
- សៀវភៅអេឡិចត្រូនិក PPP Handbook និងសៀវភៅ PPP Monitor ចេញផ្សាយដោយ ធានាគារអភិវឌ្ឍន៍អាស៊ី

❖ គេហទំព័រពាក់ព័ន្ធនិងភាពជាដៃគូរវាងរដ្ឋ និងឯកជន

- www.ppp.mef.gov.kh
- www.mef.gov.kh
- www.cambodiainvestment.gov.kh
- www.mpwt.gov.kh
- www.adb.org
- www.wb.org
- www.unescap.org
- www.ppp4krakow.net

❖ សារពត៌មាន

- Fresh News
- www.rfa.org
- www.khmerload.com
- BTVNews

# ច្បាប់

# ស្តីពី

# វិនិយោគ
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១១ ជំពូកទី ២ ស្តីអំពី ព្រះមហាក្សត្រ នៃ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

## បង្គាប់

មាត្រា ១. ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤ ។

មាត្រា ២. ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង ដោយព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

# ច្បាប់

## ស្តីពី

## វិនិយោគ

## នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង / ឬ ជនបរទេស ។

មាត្រា ២.-

អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានីតិបុគ្គល ។

:

## ជំពូកទី ២

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មាត្រា ៣.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងសំរេចការងារនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

មាត្រា ៤._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសំរាប់ជំនួយការគឺ ៖

១_ គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២_ គណៈកម្មាធិការវិនិយោគកម្ពុជា ។

មាត្រា ៥._

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិយោគ

មាត្រា ៦._

អ្នកវិនិយោគត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច ។

មាត្រា ៧._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យនិងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ៤
## ការធានាលើការវិនិយោគ

មាត្រា ៨._

អ្នកវិនិយោគត្រូវបានទទួលស្គាល់និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩._

រាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា ១០._

រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ ។

មាត្រា ១១._

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សំរាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន ។

ការទូទាត់ខាងលើនេះរួមមាន ៖

១_ ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការប្រាក់ចងការ ។

២_ ការទូទាត់ចំណាយសួយសារ និង ថ្លៃសេវាគ្រប់គ្រង ។

៣_ ការផ្ទេរប្រាក់ចំណេញ ។

៤_ ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី ៨ ។

## ជំពូកទី ៥
## ការលើកទឹកចិត្តវិនិយោគ

មាត្រា ១២._

រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ ៖

១_ ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២_ ការបង្កើតការងារ

៣_ ការបង្កើនការនាំចេញ

៤_ ឧស្សាហកម្មទេសចរណ៍

៥_ ការផលិតទំនិញកសិ_ឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧_ អភិវឌ្ឍន៍ខេត្ត និងជនបទ

៨_ ការការពារបរិដ្ឋាន

៩_ ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់ ។

មាត្រា ១៣._

ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ ។

មាត្រា ១៤._

ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ ៖

១_ អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និង អាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត ប៉ៃ មាស ត្បូងថ្មមានតម្លៃ ។ ល ។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក ។

២_ ពន្ធលើប្រាក់ចំណេញអាចលើកលែងបានរហូតដល់រយៈពេល ៨ ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់ការវិនិយោគនីមួយៗនិងអាទិភាព ដែលរាជរដ្ឋាភិបាលនឹងកំណត់ដោយអនុក្រឹត្យ ។ ការលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលបានទទួលប្រាក់ចំណេញលើកទីមួយ ។ ការខាតបង់រយៈពេល ៥ ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឱ្យយកមកទូទាត់នឹងប្រាក់ចំណេញ ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឱ្យរួចពន្ធទាំងស្រុង ។

៣_ មិនយកអាករលើការបែងចែកប្រាក់ចំណេញនៃការវិនិយោគ ទោះជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី ។

៤_ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សំរាប់ប្រើប្រាស់ ត្រូវមានលក្ខខណ្ឌណាមួយដូចតទៅ ៖

ក_ ការវិនិយោគដែលមានទិសដៅសំរាប់បំរើឱ្យការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប ។

ខ_ មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសំរាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

គ_ ឧស្សាហកម្មទេសចរណ៍

ឃ_ ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ_ឧស្សាហកម្ម ។

ង_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការផលិតថាមពល ។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជាបន្ត ហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬ សៀវភៅបន្ទុក សំរាប់ការវិនិ_ យោគដែលផលិតទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមាន ចែងក្នុងចំណុច (៤)ក ខាងលើ និងសំរាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់ អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច (៤)ខ ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច(៤)ក និងចំណុច (៤)ខ ខាងលើនេះ ការលើកលែងពន្ធគយ និង ពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតឱ្យ សំរាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារនិងការ ចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ ។

៥_ ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស ។

៦_ ការអនុញ្ញាតឱ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា ៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ទ្ធនិងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាមច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ ។

មាត្រា ១៥._

ការអនុញ្ញាតនិងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនអាច ផ្ទេរ ឬ លក់បានឡើយ ។

## ជំពូកទី ៦

## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

មាត្រា ១៦._

អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅនឹង កម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី ៖

១- កម្មសិទ្ធិដីធ្លីសំរាប់បំរើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។ នីតិបុគ្គលមានសញ្ជាតិជាខ្មែរ គឺជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅនៃដើមទុនសរុបជាកម្មសិទ្ធិនៃរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

២- អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈការជួលសំរាប់រយៈពេលវែងរហូតដល់ ៧០ ឆ្នាំ ហើយអាចស្នើសុំជួលបន្ត ។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មសិទ្ធិទាំងឡាយនៅលើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

## ជំពូកទី ៧
## ការប្រើប្រាស់កំលាំងពលកម្ម

មាត្រា ១៧.-

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោជិតខ្មែរ និង បរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍ ។

មាត្រា ១៨.-

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា១៤ (៦) ក្នុងលក្ខខ័ណ្ឌដូចតទៅ ៖

១- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ ។

២- អ្នកវិនិយោគមានកាតព្វកិច្ចធ្វើការបណ្តុះបណ្តាលជាប្រចាំ និងសមស្របជូននិយោជិតខ្មែរ ។

៣- ការជំរុញលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ ។

មាត្រា ១៩.-

និយោជិតបរទេស ត្រូវបានអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេសនូវប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបានបង់ពន្ធរួចហើយ ។

## ជំពូកទី ៨
## វិវាទ និង ការរំលាយ

មាត្រា ២០.-

វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិយោគ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងភាតព្វកិច្ចដែលមានចែងក្នុងច្បាប់នេះអាច ៖

១- ដោះស្រាយដោយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នារវាងភាគីជំលោះទាំងម្ខាង ។

២- ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ វិវាទនេះអាច :

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្តល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀងនៃភាគី ។

មាត្រា ២១.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ ។ លិខិតខាងលើនេះ ត្រូវចុះហត្ថលេខាដោយអ្នកវិនិយោគ ឬអ្នកតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុនហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះផង ។

មាត្រា ២២.-

ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬ សហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២៣.-

ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះគ្រឿងម៉ាស៊ីន និង

សម្ភារៈបរិក្ខារដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ ( ៥ឆ្នាំ)អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

**មាត្រា ២៤.-**

ការវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រឹត្យស្តីពីការវិនិយោគរបស់បរទេសនៅរដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះពុំមានអានុភាពប្រតិសកម្មទេ ។

**មាត្រា ២៥.-**

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមលក្ខខ័ណ្ឌទាំងឡាយដែលបានកំណត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១
ភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

ជា ស៊ីម

# ច្បាប់
# ស្តីពី
# វិសោធនកម្ម
# នៃច្បាប់ស្តីពីវិនិយោគ
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៩

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

**មាត្រា៖តែមួយ ៖-**

ត្រូវបានកែប្រែមាត្រា ១, មាត្រា ២, មាត្រា ៦, មាត្រា ៧, មាត្រា ៨, មាត្រា ១០, មាត្រា ១២, មាត្រា ១៤, មាត្រា ១៥, មាត្រា ១៦, មាត្រា ១៨, មាត្រា ២០, មាត្រា ២១, មាត្រា ២២, មាត្រា ២៣ ជំពូកទី ៩ មាត្រា ២៤ និងជំពូកទី ១០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដូចតទៅ :

**មាត្រា ១.-ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ ។

មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

**មាត្រា ២.-ថ្មី**

ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម :

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ហៅកាត់ គ.ល.គ មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** មានន័យថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់គម្រោងត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រឹត្យ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** មានន័យថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់ខ្លួន ១០០% (មួយរយភាគរយ) ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញជានូវវត្ថុធាតុដើម ឬសម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល

**ថ្ងៃធ្វើការ** មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា

**នីតិបុគ្គលសញ្ជាតិខ្មែរ** មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបាន
ធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន ៥១% (ហាសិប
មួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមាន
សញ្ជាតិជាខ្មែរ

**បុគ្គល** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល

**វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិ-
វឌ្ឍន៍កម្ពុជាដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍
កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**សំណើវិនិយោគ** មានន័យថា សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបុ-
គ្គលណាមួយក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិ
គ្រប់គ្រាន់

**អ្នកដាក់ពាក្យសុំ** មានន័យថា បុគ្គលឬក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សា
អភិវឌ្ឍន៍កម្ពុជា

**អ្នកវិនិយោគ** មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់
គ្រាន់ ។

## មាត្រា ៦.-ថ្មី

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះនិងអនុក្រឹត្យ ។

## មាត្រា ៧.-ថ្មី

ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធទៅឱ្យអ្នកស្នើសុំ ។

ប្រសិនបើសំណើវិនិយោគផ្តល់ជូននូវពត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលបានស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីការយល់ព្រម ការអនុញ្ញាត ការជិះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមការជិះបញ្ជី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតឬបញ្ជិកាទាំងនោះផង ។ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធក្នុងរយៈពេល ៣ថ្ងៃ(បី) នៃថ្ងៃធ្វើការទេ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិ តាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជំនួសមុខឱ្យអ្នកស្នើសុំ ។

រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជិះបញ្ជី អាជ្ញាប័ណ្ណ លិខិតយល់ព្រមឬបញ្ជិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតអោយបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។

មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានា ។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគរួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌបាន ។

**មាត្រា ៨.-ថ្មី**

អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ។

**មាត្រា ១០.-ថ្មី**

រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

**មាត្រា ១២.-ថ្មី**

រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ១៤.—ថ្មី**

ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម :

១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ។ រយៈពេលលើកលែងពន្ធរួមមាន : រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។

២-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្នែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។

៤-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្នែកតាមកថាខណ្ឌ ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកយន្តការ ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដទៃទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាង

សង់ វត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិត-កម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៧-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សា-ហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨-បុគ្គលណាដែលបានទិញឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនីតិវិធីនៃការទិញឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០%(មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការនិងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរ-ទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេសនិងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្ដីពីអន្តោប្រវេសន៍និងច្បាប់ស្ដីពីការងារ ។

## មាត្រា ១៥.–ថ្មី

សិទ្ធិ បុព្វសិទ្ធិនិងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួល មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា ១៤ ថ្មី ។

## មាត្រា ១៦.–ថ្មី

កម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគសម្រាប់មម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទានឬការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ភូមិបាល ។

អ្នកវិនិយោគមានសិទ្ធិកាន់កាប់និងដាក់បញ្ចាំសម្រាប់ធានានិងផ្ទេរនូវចលនទ្រព្យនិងអចលនទ្រព្យដែលស្ថិតនៅលើដីនិងដីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ តាមរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួល ដូចដែលបានអនុញ្ញាតដោយច្បាប់ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

## មាត្រា ១៨.–ថ្មី

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ :

- គុណភាព សមត្ថភាពនិងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះ ត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវឯកសាររួមមាន សេចក្ដីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រនិងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ

- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស ។ អ្នកវិនិយោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- មុននឹងចូលបម្រើការងារឱ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ :

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ

- ជំរុញលើកកំពស់ដល់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

## មាត្រា ២០.–ថ្មី

វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។

ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅ :

- សុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ

- សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុង ឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់គូភាគី ឬ

សុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២១.–ថ្មី**

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

**មាត្រា ២២.–ថ្មី**

ប្រសិនបើអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវភ័ស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹងឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

**មាត្រា ២៣.–ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពរបស់ខ្លួន ទោះតាមផ្លូវតុលាការក្តីឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេសឬមួយប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានប្រើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាដែលបាននាំចូលដោយរួចពន្ធ ក្នុងអំឡុងពេលតិចជាង ៥(ប្រាំ)ឆ្នាំ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ពន្ធលើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាទាំងនោះ យោងតាមការកំណត់របស់អនុក្រឹត្យ ។

# ជំពូកទី ៩ ថ្មី
# អន្តរប្បញ្ញត្តិ

**មាត្រា ២៤.-ថ្មី**

ការវិនិយោគទាំងឡាយដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិ-យោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ៩% (ប្រាំបួនភាគរយ) មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ និងដែលបានចាប់ផ្តើមសកម្មភាពវិនិយោគដោយទទួលបានការយល់ព្រមអនុម័ត មានសិទ្ធិទទួលបានអត្រាពន្ធ ៩% (ប្រាំបួនភាគរយ)នេះ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធ បន្ទាប់ពីការប្រកាសឱ្យប្រើនូវច្បាប់នេះ លុះត្រាតែអ្នកវិនិយោគនោះបានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកា-តព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មីបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិត្រូវបានការលើកលែងពន្ធលើប្រាក់ចំណេញ តាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុនពេលប្រកាសឱ្យប្រើច្បាប់នេះ មានសិទ្ធិទទួលបន្តការលើកលែងពន្ធលើប្រាក់ចំណេញ លុះត្រាតែអ្នកវិនិយោគនោះ បានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មី បន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

## ជំពូកទី ១០ថ្មី

## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រំលោភឬមិនអនុវត្តតាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦.-ថ្មី**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧.-ថ្មី**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នស.០៣.០៣.១៣៤

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ:១០៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី គាន់**